**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

Université Royale de Droit et des Sciences Economiques

Royal University of Law and Economics

## សារណាបញ្ចប់ការសិក្សា

# មជ្ឈត្តការផ្នែកពាណិជ្ជកម្ម៖

# សិក្សាពី ស្ថាប័ន និង នីតិវិធីដោះស្រាយវិវាទពាណិជ្ជកម្មក្រៅប្រព័ន្ធតុលាការនៅកម្ពុជា

ស្រាវជ្រាវពីថ្ងៃទី០១ ខែមេសា ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៤

| | |
|---|---|
| ស្រាវជ្រាវដោយ | សាស្ត្រាចារ្យណែនាំ |
| និស្សិតឈ្មោះ៖ **ឈុន ដារិទ្ធ** | បណ្ឌិត **សន សោភ័ណ** |
| **ឡេង សុវណ្ណារ៉ូត** | |

| | | | |
|---|---|---|---|
| ថ្នាក់បរិញ្ញាបត្រ | នីតិសាស្ត្រ | ឆ្នាំចូលសិក្សា | ២០១០ |
| ជំនាន់ទី | ១៤ | ឆ្នាំសរសេរសារណា | ២០១៤ |

# អារម្ភកថា

ខ្ញុំបាទឈ្មោះ ឈុន ដារិទ្ធ និងខ្ញុំបាទឈ្មោះ ឡេង សុវណ្ណារ៉ូត ជានិស្សិតថ្នាក់បរិញ្ញាប័ត្រផ្នែក នីតិសាស្ត្រ ឆ្នាំទី៤ ជំនាន់ទី១៤ នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច មានកិត្តិយស និងនៅក្នុងឱកាសដ៏វិសេសវិសាលនេះ ក្នុងការតាក់តែង និងចងក្រងប្រធានបទមួយនៃសារណាបញ្ចប់ការសិក្សាស្តីពី "មជ្ឈត្តការផ្នែកពាណិជ្ជកម្ម(សិក្សាពីស្ថាប័ន និងនីតិវិធីដោះស្រាយវិវាទពាណិជ្ជកម្មក្រៅប្រព័ន្ធតុលាការនៅកម្ពុជា)" ដែលទាក់ទងនឹង ការសិក្សាលើមុខវិជ្ជា នីតិពាណិជ្ជកម្ម ដែលបានសិក្សា កន្លងមកដើម្បីយកទ្រឹស្តីនៃមុខវិជ្ជាទាំងអស់នេះមកធ្វើការអនុវត្តផ្ទាល់។

យើងខ្ញុំបានធ្វើការបែងចែកមាតិកាជាផ្នែកតូចៗ ដើម្បីឲ្យមានភាពងាយស្រួលក្នុងការស្រាវជ្រាវស្វែងរកនូវឯកសារបន្ថែម ក៏ដូចជាងាយស្រួលក្នុងការពន្យល់ និងលើកយកមកពិភាក្សាក្នុងគោលបំណងចងក្រងឲ្យបាននូវស្នាដៃដ៏ល្អមួយ។ យើងខ្ញុំបានប្រមូលផ្តុំនូវឯកសារស្រាវជ្រាវតាមប្រភពផ្សេងៗ និងបានចូលរួមមហាសន្និបាតលើកទី១ របស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្មដោយផ្ទាល់ ជាពិសេសយើងខ្ញុំបានសុំធ្វើ បទសម្ភាសជាមួយមជ្ឈត្តករពីពត៌មានបន្ថែមផ្សេងៗដែលខ្វះខាត ដើម្បីលើកយកមកធ្វើការចងក្រងជាសៀវភៅមួយក្បាលនេះ។ ជាលទ្ធផលយើងខ្ញុំទទួលបាននូវស្នាដៃមួយនេះដើម្បីប្រគល់ ជូនការិយាល័យស្រាវជ្រាវបានទាន់ពេលវេលាដែលបានកំណត់ក្នុងការត្រួតពិនិត្យ និងវាយតម្លៃ ព្រមទាំងដាក់ពិន្ទុពីសំណាក់ លោក លោកស្រីសាស្ត្រាចារ្យដែលជាគណៈកម្មាការ។

ជាមួយគ្នានេះផងដែរ យើងខ្ញុំសង្ឃឹមយ៉ាងមុតមាំថា ស្នាដៃមួយនេះអាចចូលរួមចំណែកធ្វើឲ្យជនរួមជាតិទាំងឡាយមានការយល់ដឹងបន្ថែមអំពីស្ថាប័នមជ្ឈត្តការនៅកម្ពុជា ដែលហៅកាត់ថា ម.ជ.ម. ក៏ដូចជានីតិវិធីនៃដំណើរការមជ្ឈត្តការ និងភាពខុសគ្នារវាងស្ថាប័នតុលាការ និងមជ្ឈត្តកម្ម ជាពិសេសដើម្បីឲ្យនិស្សិតខ្មែរ និងប្រជាពលរដ្ឋគ្រប់ស្រទាប់បានយល់អំពីផ្នែកនេះកាន់តែស៊ីជម្រៅ និងអាចយកមកធ្វើ ការអនុវត្តនៅក្នុងសង្គមរស់នៅផងដែរ។

ជាចុងក្រោយនេះ ទោះបីជាយើងខ្ញុំបានខិតខំប្រឹងប្រែង និងព្យាយាមពិនិត្យយ៉ាងណាក៏ដោយ ក៏កិច្ចការមួយនេះពិតជាអាចមាននូវកំហុសឆ្គងខ្លះៗ ទាំងចេតនាក្តី ឬអចេតនាក្តី នៅត្រង់ចំណុចណាមួយជាមិនខាន។ អាស្រ័យហេតុនេះហើយ ក្នុងនាមយើងខ្ញុំជាអ្នកតាក់តែង សូមធ្វើការអភ័យទោសជា មុននូវរាល់កំហុសឆ្គង និងការខ្វះខាត ក៏ដូចជាទទួលការរិះគន់ផ្សេងៗ ក្នុងគោលបំណងស្ថាបនាស្នាដៃ មួយនេះឲ្យមានលក្ខណៈកាន់តែល្អប្រសើរឡើងបន្ថែមទៀត។

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំដែលជានិស្សិតក្រុមដែលមានឈ្មោះ **ឈុន ដារិទ្ធ** និង **ឡេង សុវណ្ណារ៉ូត** ដែលជានិស្សិតឆ្នាំទី៤ ថ្នាក់បរិញ្ញាបត្រនីតិសាស្រ្ត នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច ។

សូមគោរពប្រតិបត្តិ និងសូមសំដែងនូវកត្តញ្ញូតាធម៌យ៉ាងជ្រាលជ្រៅជូនចំពោះ ៖

លោក **ឪពុក អ្នកម្តាយ** ដែលអ្នកមានគុណទាំងទ្វេដែលបានផ្តល់កំណើតដល់កូន និងបានខិតខំអស់ទាំងកំលាំងកាយចិត្តដោយពុំខ្លាចនឿយហត់ ក្នុងការចិញ្ចឹមបីបាច់ថែរក្សារអប់រំ ទូន្មានប្រៀនប្រដៅអោយយើងខ្ញុំខិតខំរៀនសូត្រ និងប្រព្រឹត្តតែអំពើល្អ។ មិនតែប៉ុណ្ណោះ លោកឪពុក អ្នកម្តាយបានធ្វើការឧបត្ថម្ភគាំទ្រយើងខ្ញុំទាំងផ្នែកស្មារតី ធនធាន និង សម្ភារតាំងពីយើងខ្ញុំនៅតូចរហូតពេញវ័យ ហើយថែមទាំងជំរុញឲ្យយើងខ្ញុំមានឧកាសចូលសិក្សាក្រេបចិញ្ចក់ចំណេះដឹង តាំងពីកម្រិតមូលដ្ឋានរហូតមកដល់ពេលបច្ចុប្បន្ននេះ ។

យើងខ្ញុំក៏សូមសំដែងនូវការដឹងគុណយ៉ាងជ្រាលជ្រៅផងដែរចំពោះ ៖

ឯកឧត្តម **លុច វណ្ណា** សាកលវិទ្យាធិការ នៃសកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និង វិទ្យាសាស្រ្តសេដ្ឋកិច្ច ដែលបានផ្តល់ឧកាសឲ្យយើងខ្ញុំពង្រីកនូវចំនេះដឹង និង បង្កើតនូវជំនាញតាមរយៈការចងក្រងកិច្ចការស្រាវជ្រាវនេះឡើង។

ជាពិសេសលោកសាស្រ្តាចារ្យ **សន សោភ័ណ** ដែលបានចំណាយពេលវេលាដ៏មានតម្លៃ ការប្រឹងប្រែង មិនក្លាចនឿយហត់ក្នុងការចង្អុលបង្ហាញនូវការណែនាំ និងការកែប្រែកំហុសឆ្គងរបស់យើងខ្ញុំដើម្បីធានានូវសមិទ្ធផលមួយដែលប្រកបដោយគុណភាព ។

លោក និង លោកស្រីសាស្រ្តាចារ្យ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច ដែលបានបង្ហាត់បង្រៀនអប់រំ ណែនាំផ្តល់ឱវាទល្អៗ និងបទពិសោធន៍ល្អៗគ្រប់បែបយ៉ាងដល់យើងខ្ញុំតាំងពីថ្នាក់មូលដ្ឋានរហូតមកដល់ពេលបច្ចុប្បន្ននេះ ។

សិស្សច្បង និង មិត្តនិស្សិត ដែលបានណែនាំពីការស្រាវជ្រាវឯកសារ និងបានជួយរកឯកសារដល់យើងខ្ញុំទាំងអស់គ្នា ព្រមទាំងបានជួយពិនិត្យលើអក្ខរាវិរុទ្ធ កែសំរួលលើកំហុសឆ្គងថែមទៀតដែលជាកំលាំងចិត្តជំរុញឲ្យយើងខ្ញុំខិតខំបន្តរការស្រាវជ្រាវនេះរហូតដល់ការស្រាវជ្រាវនេះបានសំរេច ។

យើងខ្ញុំទាំងអស់គ្នាសូមគោរពជូនពរ និងសូមលើកហត្ថាទាំងទ្វេបួងសួងដល់ទេវតា ដែលតាមថែរក្សាព្រះរាជាណាចក្រកម្ពុជាទាំងឡាយសូមជួយថែរក្សា លោកអ្នកមានគុណទាំងទ្វេ ឯកឧត្តមសកលវិទ្យាធិការ ឯកឧត្តមសាស្រ្តាចារ្យ លោក លោកស្រីសាស្រ្តាចារ្យ និង អ្នកដែលបានជួយទំនុកបំរុងក្នុងកិច្ចការស្រាវជ្រាវនេះឲ្យជួបប្រទះនូវពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ និង ពលៈកុំបីឃ្លៀងឃ្លាតឡើយនិងសូមឲ្យទទួលជោគជ័យគ្រប់ភារកិច្ច។

# មាតិកា


**សេចក្ដីផ្ដើម** ........................................ ១

**ជំពូកទី ១ ការរៀបចំ និងការប្រព្រឹត្តទៅរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម** ........................................ ៤

**១. គោលការណ៍នៃមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម** ........................................ ៤

១.១. គោលបំណងនៃមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ........................................ ៤

១.២. តួនាទី និងភារៈកិច្ចរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ........................................ ៥

**២. រចនាសម្ព័ន្ធ និងការគ្រប់គ្រងមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការ** ........................................ ៦

២.១. ការគ្រប់គ្រងរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ........................................ ៦

២.១.១. មហាសន្និបាត ........................................ ៦

២.១.២. ក្រុមប្រឹក្សាប្រតិបត្តិ ........................................ ៨

ក. ប្រធាន និងអនុប្រធាននៃក្រុមប្រឹក្សាប្រតិបត្តិ ........................................ ៩

ខ. ហិរញ្ញិក និងសមាជិកនៃក្រុមប្រឹក្សាប្រតិបត្តិ ........................................ ១០

២.១.៣. អគ្គលេខាធិការដ្ឋាន ........................................ ១០

២.១.៤. សវនកម្ម ........................................ ១១

២.២. សមាជិកនៃមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ........................................ ១២

២.២.១. លក្ខខណ្ឌចូលជាសមាជិកនៃ ម.ជ.ម ........................................ ១២

២.២.២. ការបាត់បង់សមាជិកភាពរបស់សមាជិកនៃ ម.ជ.ម ........................................ ១៣

២.២.៣. ការជ្រើសរើសមជ្ឈត្តករ ........................................ ១៤

ក. លក្ខខណ្ឌនៃការជ្រើសរើសមជ្ឈត្តករលើកដំបូង ........................................ ១៤

ខ. វគ្គបណ្ដុះបណ្ដាលមជ្ឈត្តករដំបូង ........................................ ១៦

គ. ការប្រលងជ្រើសរើសបញ្ចប់វគ្គបណ្ដុះបណ្ដាលមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ........................................ ១៧

២.៣. សាខារបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ........................................ ១៩

**៣. ប្រភពធនធាន** ........................................ ១៩

**ជំពូកទី ២ នីតិវិធីដោះស្រាយវិវាទពាណិជ្ជកម្មក្រៅប្រព័ន្ធតុលាការនៅកម្ពុជា** ....................................................................................................................២១

**១. គោលការណ៍ទូទៅនៃការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ** ................២១

១.១. ការចរចា .......................................................................................................២១

១.២. មជ្ឈត្តកម្ម .....................................................................................................២២

**២. កិច្ចព្រមព្រៀងមជ្ឈត្តកម្ម** ..........................................................................២២

២.១. គោលការណ៍ទូទៅនៃកិច្ចព្រមព្រៀងមជ្ឈត្តកម្ម ........................................២២

២.២. លក្ខខណ្ឌសុពលភាព ......................................................................................២៣

២.២.១. ការព្រមព្រៀង ..........................................................................................២៣

២.២.២. ការធ្វើឡើងជាលាយលក្ខណអក្សរ ............................................................២៣

២.២.៣. សមត្ថភាពរបស់ភាគី ...................................................................................២៤

២.២.៤. ទំនាក់ទំនងគតិយុត្តិ ...................................................................................២៤

២.២.៥. កម្មវត្ថុនៃវិវាទ .........................................................................................២៥

**៣. នីតិវិធីនៃមជ្ឈត្តកម្ម** ....................................................................................២៥

៣.១. ការជ្រើសរើសស្ថាប័នមជ្ឈត្តការ ......................................................................២៥

៣.១.១. ការជ្រើសរើសស្ថាប័នមជ្ឈត្តកម្មតាមកិច្ចព្រមព្រៀងមជ្ឈត្តការ .....២៥

ក. ការព្រមព្រៀងគ្នាទៅស្ថាប័នមជ្ឈត្តកម្មតាមកិច្ចសន្យា ............២៥

ខ. ការបង្គាប់របស់តុលាការឲ្យទៅស្ថាប័នមជ្ឈត្តកម្ម .................២៦

៣.១.២. ការជ្រើសរើសស្ថាប័នមជ្ឈត្តកម្មតាមការព្រមព្រៀងក្រោយពេលមានវិវាទកើតឡើង ..........................................................................................២៦

៣.២. ដំណើរការនៃមជ្ឈត្តការ ......................................................................................២៦

៣.២.១. ការចាប់ផ្ដើមមជ្ឈត្តកម្ម ..........................................................................២៦

៣.២.២. ការជ្រើសរើសមជ្ឈត្តករ ..........................................................................២៧

ក. ចំនួនមជ្ឈត្តករ ......................................................................................២៧

ខ. ការតែងតាំងមជ្ឈត្តករ .............................................................................២៨

គ. ការជំទាស់ក្នុងការតែងតាំងមជ្ឈត្តករ ..................................២៩

ឃ. អំណាច និងភារកិច្ចរបស់មជ្ឈត្តករ ..................................៣០

៣.២.៣. ដំណើរការមជ្ឈត្តការ ..................................៣១

ក. ទីកន្លែងធ្វើមជ្ឈត្តការ ..................................៣១

ខ. វិធានច្បាប់អនុវត្ត ..................................៣១

គ. ភាសា ..................................៣៣

៣.២.៤. ការបោះបង់សិទ្ធិ ..................................៣២

៣.៣. នីតិវិធីក្នុងការដោះស្រាយវិវាទ ..................................៣២

៣.៣.១. សេចក្តីថ្លែងហេតុបើករបស់មជ្ឈត្តករ ..................................៣៣

៣.៣.២. សេចក្តីថ្លែងហេតុបើករបស់ភាគី ..................................៣៣

៣.៣.៣. ការប្រើប្រាស់ភស្តុតាង ..................................៣៣

៣.៣.៤. ការសាកសួរសាក្សី ..................................៣៤

៣.៣.៥. ការឆ្លើយ និងឆ្លើយតប ..................................៣៤

៣.៣.៦. សេចក្តីថ្លែងការបិទ ..................................៣៤

៣.៤. នីតិវិធីក្រោយការដោះស្រាយវិវាទ ..................................៣៥

៣.៤.១. ការចេញសេចក្តីសម្រេចមជ្ឈត្តវិនិច្ឆ័យ ..................................៣៥

៣.៤.២. ការសុំកែតម្រូវ បកស្រាយមជ្ឈត្តវិនិច្ឆ័យ និងការចេញសេចក្តីសម្រេចបន្ថែម ..................................៣៧

**៤. អានុភាពនៃសេចក្តីសម្រេចមជ្ឈត្តវិនិច្ឆ័យ និងការប្តឹងឧបាស្រ័យ** ..................................៣៨

៤.១. អានុភាពនៃសេចក្តីសម្រេចមជ្ឈត្តវិនិច្ឆ័យ ..................................៣៨

៤.២. ការប្តឹងឧបាស្រ័យនឹងសេចក្តីសម្រេចមជ្ឈត្តវិនិច្ឆ័យ ..................................៣៩

**ជំពូកទី ៣ លក្ខណៈដូច និងលក្ខណៈខុសគ្នានៃមជ្ឈត្តការ និងតុលាការ** ..................................៤១

**១. លក្ខណៈដូចគ្នា** ..................................៤១

១.១. ការដោះស្រាយវិវាទផ្តោតលើភស្តុតាង និងច្បាប់ ..................................៤១

១.២. អ្នកតំណាង ........................................................................................៤១
១.៣. ការចេញនូវសេចក្តីសម្រេច និងការសុំឲ្យអនុវត្តនៃសេចក្តីសម្រេច .............៤១
**២. លក្ខណៈខុសគ្នា** .......................................................................................៤២
១.១. ជម្រើសរបស់ភាគីវិវាទ.......................................................................៤២
១.២. ភាពឆាប់រហ័ស ចំណាយតិច និងការសម្ងាត់នៃរឿង ................................៤២
១.៣. ជំនាញក្នុងការដោះស្រាយវិវាទ និងអ្នកតំណាង .....................................៤៣
១.៤. សេចក្តីសម្រេចចុងក្រោយ ...................................................................៤៣
**សេចក្តីសន្និដ្ឋាន** .........................................................................................៤៥
**អនុសាសន៍** ..................................................................................................៤៨
**ឧបសម្ព័ន្ធ**
**គន្ថនិទ្ទេស**

# សេចក្តីផ្តើម

នៅក្នុងដំនើរការនៃការប្រព្រឹត្តិទៅនៃទំនាក់ទំនងពាណិជ្ជកម្ម ការកើតឡើងនូវវិវាទតែងតែកើតមានឡើង គ្រាន់តែវិវាទខ្លះតូចដែលមានភាពងាយស្រួលដោះស្រាយ ឬភាគីបំភ្លេចចោលនូវវិវាទនោះតែម្តង ចំនែកឯវិវាទខ្លះទៀតជាវិវាទធំដែលនាំឲ្យភាគីវិវាទមិនអាចធ្វើការចរចាគ្នាបានរហូតដល់មានការប្តឹងផ្តល់គ្នា។ វិវាទអាចកើតមានឡើងដោយសារភាគីណាមួយមិនបានអនុវត្តទៅតាមកិច្ចសន្យាដែលខ្លួនបានព្រមព្រៀងគ្នា ឬការមិនអនុវត្តនូវកាតព្វកិច្ចមួយផ្នែក ឬទាំងស្រុងរបស់ភាគីណាមួយ។

ដើម្បីឲ្យយល់ច្បាស់ពីទំនាក់ទំនងពាណិជ្ជកម្ម យើងគប្បីយល់នូវពាក្យពាណិជ្ជកម្មជាមុនសិន។ តើពាណិជ្ជកម្មគឺជាអ្វី?

ពាក្យថា "ពាណិជ្ជកម្ម" គឺសំដៅដល់រាល់ការងារធុរកិច្ចដែលធ្វើឡើងរវាងពាណិជ្ជករ និងពាណិជ្ជករ ឬអ្នកទិញ និងអ្នកលក់ ទោះបីស្ថិតនៅក្រោមកិច្ចសន្យា ឬមិនស្ថិតនៅក្រោមកិច្ចសន្យាក៏ដោយ។

ទន្ទឹមនឹងគ្នាបញ្ហាវិវាទកើតមាន ការដោះស្រាយវិវាទអាចធ្វើការដោះស្រាយតាមរយៈ ២ ប្រព័ន្ធ គឺតាមប្រព័ន្ធតុលាការ និងប្រព័ន្ធក្រៅតុលាការ។ ចំពោះការដោះស្រាយវិវាទតាមរយៈតុលាការ គឺជាការស្វែងរកនូវយុត្តាធិការតុលាការ និងច្បាប់មកធ្វើការដោះស្រាយ។ ចំនែកឯការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការវិញ ជាយន្តការធ្វើការដោះស្រាយវិវាទដោយការផ្សះផ្សាពោលគឺការស្វែងរកភាគីទីបី ដើម្បីនាំគូវិវាទឲ្យជួបគ្នាក្នុងការដោះស្រាយបញ្ហាវិវាទនោះ។ នៅក្នុងការដោះស្រាយវិវាទនៅក្នុងពិភពលោកបច្ចុប្បន្ន គេសង្កេតឃើញមានយន្តការទាំងពីរនេះ ចំនែកឯប្រព័ន្ធយុត្តាធិការរបស់ប្រទេសកម្ពុជា ក៏អនុវត្តនូវប្រព័ន្ធទាំងពីរនេះដែរ។

ដោយឡែកការអនុវត្តនូវយុត្តាធិការក្រៅប្រព័ន្ធតុលាការ គឺជាប្រព័ន្ធមួយសំរាប់ពាណិជ្ជករធំៗ។ គេនិយមប្រើប្រាស់ហើយដែលសព្វថ្ងៃគេឲ្យឈ្មោះថា "មជ្ឈត្តការពាណិជ្ជកម្ម"។ ការប្រើប្រាស់នូវប្រព័ន្ធមជ្ឈត្តការនេះ គឺជាប្រព័ន្ធមួយដែលគេនិយមប្រើប្រាស់ដោយហេតុផលថាការដោះស្រាយតាមរយៈមជ្ឈត្តការនេះ គឺបានជួយសំរួលឲ្យរួចផុតអំពីការប្រើប្រាស់នូវប្រព័ន្ធតុលាការដែលមានលក្ខណៈស្មុគស្មាញ និងនីតិវិធីសាំញ៉ាំដែលធ្វើឲ្យខាតបង់នូវពេលវេលា និងប្រាក់កាក់របស់ពួកគេ។ ក្នុងនោះយើងសង្កេតឃើញថាមជ្ឈត្តការមានសន្ទុះក្នុងការប្រើប្រាស់យ៉ាងច្រើន រហូតដល់មានការបង្កើតនូវស្ថាប័នមជ្ឈត្តការជាច្រើននៅជុំវិញពិភពលោក។ ជាក់ស្តែងមជ្ឈត្តការល្បីៗជុំវិញ

ពិភពលោកដែលរួមមានដូចជាៈ សមាគមន៏មជ្ឈត្តការអាមេរិចទីក្រុងញូវយ៉ក (American Arbitration Association) តុលាការមជ្ឈត្តការអន្តជាតិទីក្រុងឡុង (London Court of International Arbitration) និងតុលាការអន្តរជាតិទីក្រុងប៉ារីស (International Chamber of Commerce)។ ដោយឡែកចំពោះទិដ្ឋភាពនៅក្នុងទ្វីបអាស៊ីវិញម្តង យើងសង្កេតឃើញថាមានមជ្ឈត្តការធំៗនៅទ្វីបអាស៊ីធំៗចំនួន ៣ ដែលក្នុងនោះរួមមានដូចជា គណៈកម្មការផ្នែកសេដ្ឋកិច្ច និងពាណិជ្ជកម្មអន្តរជាតិប្រទេសចិន (China International Economic and Trade Arbitration Commission ) មជ្ឈមណ្ឌលមជ្ឈត្តការអន្តរជាតិទីក្រុងហុងកុង (Hong Kong International Arbitration Center) និងមជ្ឈមណ្ឌលមជ្ឈត្តការអន្តរជាតិសឹង្ហបុរី (Singapore International Arbitration Center) ។

ដោយឡែកចំពោះបរិបទនៅក្នុងប្រទេសកម្ពុជាវិញ យើងសង្កេតឃើញថាស្ថាប័នដោះស្រាយវិវាទដំបូងត្រូវបង្កើតឡើងនៅឆ្នាំ២០០៣ ដោយធ្វើការផ្តល់សិទ្ធដល់ក្រុមអាជ្ញាកណ្តាល ក្នុងការដោះស្រាយវិវាទការងារ។ ដោយសង្កេតឃើញពីភាពជោគជ័យនៃការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល រដ្ឋាភិបាលក៏បានធ្វើការពិនិត្យលើការបង្កើតនូវមជ្ឈមណ្ឌលជាតិមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ដើម្បីធ្វើការជួយសំរួលដល់ការដោះស្រាយវិវាទរបស់ពាណិជ្ជករដែលកំពុងធ្វើពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា ដើម្បីជាការសំរួលដល់ពួកគាត់ក្នុងការដោះស្រាយវិវាទដែលអាចជួយកាត់បន្ថយក្នុងការប្រើប្រាស់ពេលវេលាយូរ និងប្រាក់កាក់ច្រើនក្នុងការដោះ ស្រាយ។

ដោយសារសំលឹងមើលឃើញនូវការរីវឌ្ឍន៏យ៉ាងសម្បើមរបស់វិស័យពាណិជ្ជកម្ម និងការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនេះហើយ ជាពិសេសគឺមជ្ឈមណ្ឌលជាតិមជ្ឈត្តការផ្នែកពាណិជ្ជកម្មនេះតែម្តង ដែលធ្វើអោយយើងសំរេចជ្រើសរើសយកប្រធានបទស្តីពី "មជ្ឈត្តការផ្នែកពាណិជ្ជកម្ម" យកមកធ្វើការសិក្សាស្រាវជ្រាវ។

មុននឹងឈានទៅដល់ការបកស្រាយប្រធានបទ យើងគួរតែយល់ជាមុនសិនថាអ្វីទៅជាមជ្ឈត្តការផ្នែកពាណិជ្ជកម្ម?

បើយោងតាមមាត្រា២ វាក្យខណ្ឌ ក នៃច្បាប់ស្តីពី មជ្ឈត្តការផ្នែកពាណិជ្ជកម្ម បានឲ្យនិយមន័យពាក្យ "មជ្ឈត្តការ" ថាជាការផ្សះផ្សាវិវាទដោយប្រើប្រាស់វេទិកាមជ្ឈត្តកម្ម ហើយអាចស្ថិតនៅក្នុង ឬនៅក្រៅក្របខ័ណ្ឌនៃការគ្រប់គ្រងរបស់ស្ថាប័នផ្សះផ្សាអចិន្ត្រៃយ៍មួយ។ ដូច្នេះមជ្ឈត្តការផ្នែកពាណិជ្ជកម្ម គឺសំដៅទៅដល់ការផ្សះផ្សាវិវាទទាក់ទងទៅនឹងរឿងពាណិជ្ជកម្ម ដោយប្រើប្រាស់

វេទិកាមជ្ឈត្តកម្មមកធ្វើការដោះស្រាយ។ ជារួមគឺជាការដោះស្រាយវិវាទផ្នែកពាណិជ្ជកម្មដោយមានភាគីទី៣ ចូលរួមធ្វើការដោះស្រាយ និងមានអនុភាពចាប់បង្ខំ។

តើមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្មមានរចនាសម្ព័ន្ធដូចម្តេច? ហើយនីតិវិធីក្នុងការដោះស្រាយវិវាទពាណិជ្ជកម្មមានអ្វីខ្លះ? តើដំណើរការមជ្ឈត្តការមាននីតិវិធីអ្វីខ្លះ? ហើយរវាងស្ថាប័នតុលាការ និងមជ្ឈត្តការមានលក្ខណៈខុសគ្នា និងដូចគ្នាអ្វីខ្លះ?

តទៅនេះប្រធានបទរបស់យើងនឹងធ្វើការពិភាក្សាអំពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្មនៅជំពូកទី១ នីតិវិធីដោះស្រាយវិវាទពាណិជ្ជកម្មក្រៅប្រព័ន្ធតុលាការនៅកម្ពុជានៅជំពូកទី២ និងលក្ខណៈដូចគ្នា និងខុសគ្នារវាងតុលាការ និងមជ្ឈត្តការនៅជំពូកទី៣។

# ជំពូកទី ១

# ការរៀបចំ និងការប្រព្រឹត្តទៅរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម

មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការពាណិជ្ជកម្ម (**ម.ជ.ម**) ជាអង្គភាពឯករាជ្យមួយ ដែលមិនស្វែងរកប្រាក់ចំនេញ និងមានទីស្នាក់ការនៅក្នុងរាជធានីភ្នំពេញ ដែលបានបង្កើតឡើងសំរាប់ធ្វើការដោះស្រាយវិវាទផ្នែកពាណិជ្ជកម្មក្រៅប្រព័ន្ធតុលាការនៅកម្ពុជា។[1] មជ្ឈមណ្ឌលនេះត្រូវបានបង្កើតឡើងតាមបញ្ញត្តិនៃមាត្រា ១០នៃច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម។ ទន្ទឹមនឹងច្បាប់បានចែងអំពីការបង្កើតនេះនៅឆ្នាំ២០០៦ មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្មត្រូវបានបង្កើតឡើងនៅថ្ងៃទី០៩ ខែមិនា ឆ្នាំ២០១៣ ដែលរាល់ការគ្រប់គ្រងនានារបស់ **ម.ជ.ម** គឺអនុលោមតាមអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០០៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម។[2]

## ១. គោលការណ៍នៃមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម

### ១.១. គោលបំណងនៃមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម

មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្មត្រូវបានបង្កើតឡើងក្នុងគោលបំណងដូចជា:

- ជម្រុញការដោះស្រាយវិវាទពាណិជ្ជកម្ម តាមរយៈការផ្សះផ្សានៅកម្ពុជា។
- បង្កើតរចនាសម្ព័ន្ធ និងវិធានចាំបាច់មួយចំនួន ដើម្បីងាយស្រួលក្នុងការគ្រប់គ្រងវិវាទមជ្ឈត្តការនៅពេលដែលមានកិច្ចព្រមព្រៀងមជ្ឈត្តការរួចហើយ។
- ធានាដល់គុណភាព និងស្តង់ដានៃលក្ខណៈសម្បត្តិរបស់មជ្ឈត្តករនៃមជ្ឈត្តការនៅកម្ពុជា។[3]

ដោយសារការដោះស្រាយវិវាទតាមប្រព័ន្ធតុលាការមានភាពស្មុគស្មាញ និងខាតពេលវេលា ព្រមទាំងថវិកា ជាហេតុធ្វើឲ្យពាណិជ្ជកម្មមួយចំនួនត្រូវយកបញ្ហានេះទៅដោះស្រាយតាមរយៈប្រព័ន្ធ មជ្ឈត្តការបរទេស ដូច្នេះហើយទើប **ម.ជ.ម** ត្រូវបានបង្កើតឡើងដើម្បីជម្រុញឲ្យបញ្ហាវិវាទ

[1] មាត្រា ១០ នៃច្បាប់ស្តីពី មជ្ឈត្តការផ្នែកពាណិជ្ជកម្ម និងមាត្រា ១នៃអនុក្រឹត្យស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម (ឧបសម្ព័ន្ធទី១)

[2] http://chnchannel.com/?p=18197

[3] មាត្រា ១០ នៃច្បាប់ស្តីពី មជ្ឈត្តការផ្នែកពាណិជ្ជកម្ម

ពាណិជ្ជកម្មអាចដោះស្រាយបានឆាប់រហ័ស និងសន្សំសំចៃ ព្រោះពាណិជ្ជករ មានគោលដៅក្នុងការស្វែងរកប្រាក់ចំនេញ និងភាពងាយស្រួល ព្រមទាំងរក្សាបាននូវការសម្ងាត់។ ម្យ៉ាងទៀតតាមការកំណត់នៃការដោះស្រាយវិវាទតាមមជ្ឈត្តកា ជាសេរីភាពរបស់ភាគី ដូច្នេះហើយ**ម.ជ.ម**ចាំបាច់ត្រូវបង្កើតនូវវិធានមួយចំនួនដើម្បីគ្រប់គ្រងទៅលើវិវាទ ដែលមានកិច្ចព្រមព្រៀងមជ្ឈត្តការព្រោះថាការព្រមព្រៀងខ្លះរបស់ភាគីគឺមានភាពផ្ទុយទៅនឹងគោលការណ៍របស់មជ្ឈត្តការ ឬសណ្តាប់ធ្នាប់សាធារណៈ។

ឧទាហរណ៍: ប្រសិនបើភាគីនៃវិវាទបានព្រមព្រៀងគ្នានៅក្នុងកិច្ចព្រមព្រៀងមជ្ឈត្តការ ក្នុងការជ្រើសរើសនូវមជ្ឈត្តករចំនួន២នាក់សំរាប់ធ្វើការដោះស្រាយវិវាទរបស់ពួកគេ។ ជាគោលការណ៍នៃមជ្ឈត្តការ មជ្ឈត្តករត្រូវមានចំនួនសេសអាច ១ ឬ ៣នាក់។ ប៉ុន្តែនៅក្នុងច្បាប់មិនបានកំណត់ចំពោះករណីដែលភាគីព្រមព្រៀងគ្នាចំពោះមជ្ឈត្តករដែលមានចំនួនគូទេ គឺកំណត់ត្រឹមតែក្នុងករណីណាដែលមិនមានកំណត់ដោយភាគី មជ្ឈត្តករត្រូវមានចំនួន ៣នាក់។[4] ដូច្នេះវាបង្កើតមានទំនាស់កើតឡើងចំពោះសេរីភាពក្នុងការកំណត់របស់ភាគី និងការកំណត់របស់ច្បាប់ ដែលជាហេតុទាមទារឲ្យ **ម.ជ.ម** ត្រូវធ្វើការបង្កើតនូវវិធានមួយដើម្បីកំណត់ពីបញ្ហានេះ។

## ១.២. តួនាទី និងភារៈកិច្ចរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម

មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម មានតួនាទី និងភារៈកិច្ចដូចតទៅ:

- ជម្រុញវិស័យមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ផ្តល់ការបណ្តុះបណ្តាល និងហ្វឹកហ្វឺនបុគ្គលដែលកំពុងអនុវត្ត និងបុគ្គលដែលមានបំណងអនុវត្តវិជ្ជាជីវៈជាមជ្ឈត្តករ ដើម្បីធានាឲ្យមជ្ឈត្តការផ្នែកពាណិជ្ជកម្មនៅកម្ពុជាមានគុណភាពខ្ពស់
- ការកំណត់ពីលក្ខណៈសម្បត្តិនៃបុគ្គល ដែលមានបំណងចូលជាសមាជិក **ម.ជ.ម** រៀបចំសន្និសីទថ្នាក់ជាតិ និងអន្តរជាតិ រួមទាំងរៀបចំចូលរួមសក្ខាសិលា និងវគ្គសិក្សាលើប្រធានបទទាក់ទងនឹងមជ្ឈត្តការផ្នែកពាណិជ្ជកម្ម និងគ្រប់គ្រងចាត់ចែងទ្រព្យសម្បត្តិ **ម.ជ.ម** ក៏ដូចជាផ្តល់សេវាដោះស្រាយវិវាទផ្នែកពាណិជ្ជកម្មក្រៅប្រព័ន្ធតុលាការ
- ប្រមូល បោះពុម្ព និងផ្សព្វផ្សាយព័ត៌មាន អត្ថបទនិពន្ធ សៀវភៅ និងឯកសារ សោតទស្សន៍ ឬហ្វូណូក្រាម ដែលទាក់ទងនឹងមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ព្រមទាំងរៀបចំបណ្ណាល័យ និងបន្ទប់ផ្សេងៗ សម្រាប់បម្រើសេវាទាក់ទងនឹងមជ្ឈត្តការផ្នែក

[4] មាត្រា ១៨ នៃច្បាប់ស្តីពី មជ្ឈត្តការផ្នែកពាណិជ្ជកម្ម

ពាណិជ្ជកម្ម និងបំពេញភារកិច្ចផ្សេងៗទៀតតាមការកំណត់របស់ **ម.ជ.ម** ជាមួយនឹងការចុះកិច្ចព្រមព្រៀងនានាដែលចាំបាច់ក្នុងការបំពេញមុខងាររបស់ខ្លួន។"[5]

ក្នុងការជម្រុញនូវវិស័យមជ្ឈត្តការ និងបំពេញឲ្យបានល្អនូវតួនាទី និងភារកិច្ច **ម.ជ.ម** ត្រូវធានាឲ្យបាននូវគុណភាពរបស់មជ្ឈត្តការ ដើម្បីឲ្យពាណិជ្ជករក៏ដូចជាភាគីដទៃទៀតដែលមានវិវាទផ្នែកពាណិជ្ជកម្មមានភាពទុកចិត្ត និងជឿជាក់ទៅលើមជ្ឈត្តការថាមានយុត្តិធម៌ ឯករាជ្យភាព និងមានភាពឆាប់រហ័សពិតប្រាកដ។ ការប្រមូលបោះពុម្ពនូវឯកសារផ្សេងៗ វាមានសារៈសំខាន់ណាស់សំរាប់សិស្ស និស្សិតក៏ដូចជាសមាជិក និងមជ្ឈត្តករនៃមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្មធ្វើការស្រាវជ្រាវ និងស្វែងរកនូវឯកសារបន្ថែមដែលទាក់ទងនឹងវិស័យនេះ។

# ២. រចនាសម្ព័ន្ធ និងការគ្រប់គ្រងមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការ

## ២.១. ការគ្រប់គ្រងរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម

មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្មត្រូវបានគ្រប់គ្រងដោយ មហាសន្និបាត និងក្រុមប្រឹក្សាប្រតិបត្តិ។[6]

### ២.១.១. មហាសន្និបាត

សិទ្ធិអំណាចកំពូលរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការពាណិជ្ជកម្ម គឺស្ថិតនៅក្រោមសមត្ថកិច្ចរបស់មហាសន្និបាត មានន័យថារាល់ការសម្រេចដែលបានធ្វើឡើងដោយមហាសន្និបាតគឺ **ម.ជ.ម** ត្រូវតែគោរព និងអនុវត្តតាម។[7] មហាសន្និបាត ត្រូវរួមប្រជុំដោយសមាជិកជារូបវន្តបុគ្គល និងតំណាងរបស់សមាជិកជានីតិបុគ្គលនីមួយៗ ហើយមហាសន្និបាតនេះត្រូវធ្វើឡើងតាមការកំណត់របស់ក្រុមប្រឹក្សាប្រតិបត្តិ។ មហាសន្និបាតប្រចាំឆ្នាំត្រូវបានធ្វើការជូនដំណឹងមុនថ្ងៃប្រជុំយ៉ាងតិចចំនួន ៣០ថ្ងៃ។[8] មហាសន្និបាតអាចប្រព្រឹត្តទៅបានលុះត្រាតែមានវត្តមាន២/៣ នៃសមាជិកទាំងអស់ ហើយបញ្ហានានាដែលលើកមកពិភាក្សាត្រូវសម្រេចដោយសំលេងភាគច្រើនដាច់ខាត។ នៅក្នុងករណីមិនមានកូរ៉ុមគ្រប់ដើម្បីបើកមហាសន្និបាត កិច្ចប្រជុំនេះត្រូវពន្យាពេលចំនួន ១៤ថ្ងៃ ហើយកូរ៉ុមនៃកិច្ចប្រជុំលើកទី២ គឺ១/២សមាជិកទាំងអស់។ នៅក្នុងករណីដែលកិច្ចប្រជុំលើកទី២ នៅតែមិនមានគ្រប់ចំនួនកូរ៉ុមទៀត មហាសន្និបាតនេះត្រូវពន្យារយៈពេលចំនួន១៤ថ្ងៃទៀត ហើយ

[5] មាត្រា ២ នៃអនុក្រឹត្យស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម (ឧបសម្ព័ន្ធទី១)

[6] មាត្រា ១៤ កថាខណ្ឌទី១ នៃច្បាប់ស្តីពី មជ្ឈត្តការផ្នែកពាណិជ្ជកម្ម

[7] មាត្រា ៣ កថាខណ្ឌទី១ នៃអនុក្រឹត្យស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម (ឧបសម្ព័ន្ធទី១)

[8] មាត្រា ៥ នៃអនុក្រឹត្យស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម (ឧបសម្ព័ន្ធទី១)

ប្រសិនបើនៅតែមិនមានកូរ៉ុមគ្រប់នៅក្នុងការពន្យាលើកទី២ ចំនួនអ្នកដែលចូលរួមប្រជុំដែលត្រូវពន្យាពេលជាលើកទី២ ត្រូវចាត់ទុកថាជាកូរ៉ុមដើម្បីបើកមហាសន្និបាត។[9]

នៅក្នុងករណីដែលចាំបាច់ មហាសន្និបាតអាចស្នើឲ្យមានការប្រជុំបានផងដែរដោយប្រធានក្រុមប្រឹក្សាប្រតិបត្តិ ឬសមាជិកភាគច្រើននៃក្រុមប្រឹក្សាប្រតិបត្តិ ដោយមានភ្ជាប់ផងដែរនូវរបៀបវារៈក្នុងរយៈពេល ១៥ថ្ងៃយ៉ាងតិចមុនថ្ងៃប្រជុំ។ ប៉ុន្តែមហាសន្និបាតដែលបើកប្រជុំនេះ ត្រូវពិចារណាតែទៅលើបញ្ហាដែលមិនបានលើកឡើងនៅក្នុងមហាសន្និបាត ឬបញ្ហាដែលបានដោះស្រាយនៅក្នុងមហាសន្និបាតប្រចាំឆ្នាំដែលបានធ្វើឡើងរួចហើយប៉ុណ្ណោះ។[10] ប្រសិនបើក្រុមប្រឹក្សាប្រតិបត្តិមិនបានកោះប្រជុំមហាសន្និបាតវិសាមញ្ញតាមការស្នើសុំជាលាយលក្ខណ៍អក្សរក្នុងរយៈពេល ៣ខែនោះទេ សមាជិកដែលស្នើសុំឲ្យបើកមហាសន្និបាត អាចបើកមហាសន្និបាតបានតាមការជូនដំណឹងទៅសមាជិកទាំងអស់ក្នុងរយៈពេល ៣០ថ្ងៃមុនពេលបើកមហាសន្និបាត។[11]

កាលពីថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៤កន្លងទៅនេះ មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្មបានបើកមហាសន្និបាតប្រចាំឆ្នាំលើកទីមួយរបស់ខ្លួន ដែលនឹងលើយកមកអនុម័តនូវបទបញ្ជាផ្ទៃក្នុង វិធានស្តីពីមជ្ឈត្តការ ក្រមសីលធម៌សម្រាប់មជ្ឈត្តករ គម្រោងថវិកាប្រចាំឆ្នាំពីខែតុលា ឆ្នាំ២០១៤ ដល់ខែមីនា ឆ្នាំ២០១៦ សៀវភៅកម្រងគោលនយោបាយ និងវិធានណែនាំផ្នែកហិរញ្ញវត្ថុរបស់ **ម.ជ.ម**។[12] ដោយឡែកនៅក្នុងនៅក្នុងការដាក់ពិនិត្យ និងអនុម័តលើក្រមសីលធម៌សម្រាប់មជ្ឈត្តករមិនទាន់បានធ្វើនៅឡើយទេ ដោយហេតុការធ្វើសេចក្តីព្រាងនៃក្រមសីលធម៌នេះមិនទាន់បានចប់សព្វគ្រប់។ តែទោះជាយ៉ាងនេះក្តីក្រៅពីការដាក់ពិនិត្យ និងអនុម័តលើក្រមសីលធម៌សម្រាប់មជ្ឈត្តករ ការដាក់ពិនិត្យ និងអនុម័តលើវិធាន និងច្បាប់ផ្សេងៗតដូចមានរៀបរាប់ខាងលើត្រូវបានដាក់ឲ្យអនុម័ត ដោយការបោះឆ្នោតដោយលើដៃ និងយកនូវសំលេងភាគច្រើនដាច់ខាត។ ជាលទ្ធផលនៃមហាសន្និបាតប្រចាំឆ្នាំលើកទី១របស់ **ម.ជ.ម** មហាសន្និបាតបានអនុម័តប្រកបដោយជោគជ័យនូវបទបញ្ជាផ្ទៃក្នុង វិធានស្តីពីមជ្ឈត្តការ គម្រោងថវិកាប្រចាំឆ្នាំពីខែតុលា ឆ្នាំ២០១៤ ដល់ខែមីនា ឆ្នាំ២០១៦ សៀវភៅកម្រងគោលនយោបាយ និងវិធានណែនាំផ្នែកហិរញ្ញវត្ថុរបស់ **ម.ជ.ម** និងដាក់ឲ្យអនុវត្តចាប់ពីថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៤នេះតទៅ។[13]

---

[9] មាត្រា ៦ នៃអនុក្រឹត្យស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម (ឧបសម្ព័ន្ធទី១)

[10] មាត្រា ១៥ នៃច្បាប់ស្តីពី មជ្ឈត្តការផ្នែកពាណិជ្ជកម្ម និងមាត្រា ៣ កថាខណ្ឌទី២ នៃអនុក្រឹត្យស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម (ឧបសម្ព័ន្ធទី១)

[11] មាត្រា ៧ នៃអនុក្រឹត្យស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម (ឧបសម្ព័ន្ធទី១)

[12] លិខិតលេខ ០០៧/ម.ជ.ម./២០១៤ របស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៤(ឧបសម្ព័ន្ធទី៨)

[13] ការចូលរួមមហាសន្និបាតប្រចាំឆ្នាំលើកទី១ របស់ ម.ជ.ម នៅថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៤

### ២.១.២. ក្រុមប្រឹក្សាប្រតិបត្តិ

មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការពាណិជ្ជកម្ម ត្រូវបានគ្រប់គ្រងដោយក្រុមប្រឹក្សាប្រតិបត្តិ។[14] ក្រុមប្រឹក្សាប្រតិបត្តិត្រូវមានសមាជិកមិនលើសពី ៧នាក់ ហើយមានអាណត្តិរយៈពេល ៣ឆ្នាំ ដែលអាចបន្តឈរឈ្មោះបាន ១អាណត្តិទៀត។[15] សមាសភាពនៃក្រុមប្រឹក្សាមានដូចជា ប្រធានមួយរូប អនុប្រធានមួយរូប ហិរញ្ញិកមួយរូប និងសមាជិក ហើយការបោះឆ្នោតជ្រើសរើសសមាជិកនៃក្រុមប្រឹក្សាប្រតិបត្តិនេះ បានប្រព្រឹត្តទៅនៅថ្ងៃទី០៩ ខែមករា ឆ្នាំ២០១៣ ដែលទទួលបានលទ្ធផលដូចខាងក្រោម:

លោក **រស់ មុនិន្ទ:** ជាប្រធាន

លោកស្រី **សេង វួចហ៊ុន** ជាអនុប្រធាន

លោក **ប៉ា ងួនគា** ជាហិរញ្ញិក

លោក **Guy Spooner ប៊ុន យូឌី ផន បញ្ញា** និងលោកស្រី **ខៀវ ម៉ាលី** ជាសមាជិក។[16] ក្រុមប្រឹក្សាប្រតិបត្តិមានតួនាទី និងភារៈកិច្ចដូចជា:

- គ្រប់គ្រង និងសម្រេចការងារប្រចាំថ្ងៃ
- ការបង្កើត រៀបចំតាក់តែង ពិនិត្យ កែប្រែ និងអនុម័តវិធាន គោលនយោបាយ និងនីតិវិធីនានារបស់**ម.ជ.ម** ព្រមទាំងការពិនិត្យពិច័យលើទម្រង់នៃមជ្ឈត្តវិនិច្ឆ័យ។
- រៀបចំ និងត្រួតពិនិត្យសកម្មភាពរបស់មជ្ឈត្តករ និងអគ្គលេខាធិការ និងអគ្គលេខាធិការដ្ឋានទាំងមូល ព្រមទាំងតាមដានស្ថានភាពហិរញ្ញវត្ថុរបស់ **ម.ជ.ម**
- កំណត់ពីលក្ខខណ្ឌនានាសំរាប់បុគ្គលិក **ម.ជ.ម**
- ធ្វើរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ គម្រោងថវិកាប្រចាំឆ្នាំ និងរបាយការណ៍ស្តីពីសកម្មភាពការងាររបស់ **ម.ជ.ម** ជូនមហាសន្និបាត។[17]

ការប្រជុំរបស់ក្រុមប្រឹក្សាប្រតិបត្តិត្រូវធ្វើឡើងជាទៀងរាល់ខែ ហើយការប្រជុំក៏អាចធ្វើឡើងបន្ថែមនៅពេលណាក៏បាន ដែលមានការកោះហៅពីប្រធានក្រុមប្រឹក្សាប្រតិបត្តិ ដោយមានការជូន

[14] មាត្រា ៨ នៃអនុក្រឹត្យស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម (ឧបសម្ព័ន្ធទី១)

[15] មាត្រា ១២ កថាខណ្ឌទី២ នៃច្បាប់ស្តីពី មជ្ឈត្តការផ្នែកពាណិជ្ជកម្ម និងមាត្រា ៨ កថាខណ្ឌទី១ និង១២ នៃអនុក្រឹត្យស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម (ឧបសម្ព័ន្ធទី១)

[16] បទសម្ភាសន៍ជាមួយលោក ប៉ា ងួនគា ជាហិរញ្ញិក នៃក្រុមប្រឹក្សាប្រតិបត្តិ នៅថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៤ និងមាត្រា ៨ កថាខណ្ឌទី២ នៃអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម (ឧបសម្ព័ន្ធទី១)

[17] ប្រការ ២៥ នៃបទបញ្ជាផ្ទៃក្នុងរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម (ឧបសម្ព័ន្ធទី៣)

ដំណឹងទៅសមាជិកមុនរយៈពេល ៧ថ្ងៃមុនថ្ងៃប្រជុំ។ រាល់ការប្រជុំ គឺត្រូវមានវត្តមានសមាជិក ២/៣ នៃសមាជិកទាំងអស់ដើម្បីដំណើរការការប្រជុំ ហើយរាល់ការសម្រេចនៅក្នុងកិច្ចប្រជុំ ត្រូវសម្រេចដោយសំលេងភាគច្រើន ហើយក្នុងករណីដែលមានសំលេងស្មើគ្នា សំលេងរបស់ប្រធានក្រុមប្រឹក្សាប្រតិបត្តិមានឧត្តមានុភាព។[18] ការជ្រើសតាំងសមាជិករបស់ក្រុមប្រតិបត្តិ គឺត្រូវបានធ្វើឡើងនៅក្នុងមហាសន្និបាត។[19] ប៉ុន្តែការជ្រើសតាំងប្រធាន អនុប្រធាន និងហិរញ្ញិកនៃក្រុមប្រឹក្សាប្រតិបត្តិ គឺត្រូវបានធ្វើការជ្រើសរើសដោយឡែកតាមរយៈការបោះឆ្នោត។[20] សមាជិកនៃក្រុមប្រឹក្សាប្រតិបត្តិអាចជាជនជាតិខ្មែរ ឬបរទេស ប៉ុន្តែប្រធាន អនុប្រធាន និងហិរញ្ញិកនៃក្រុមប្រឹក្សាប្រតិបត្តិត្រូវតែមានសញ្ជាតិជាខ្មែរ។[21] ចាប់តាំងពីថ្ងៃដែលបានបង្កើតក្រុមប្រឹក្សាប្រតិបត្តិនេះរហូតមកដល់ថ្ងៃស្រាវជ្រាវនេះ ក្រុមប្រឹក្សាប្រតិបត្តិបានធ្វើការប្រជុំជាច្រើនលើក ប៉ុន្តែក្រុមប្រឹក្សាប្រតិបត្តិមិនទាន់បានធ្វើការប្រជុំណាមួយបើកជាលក្ខណៈផ្លូវការនៅឡើយទេ។[22]

### ក. ប្រធាន និងអនុប្រធាននៃក្រុមប្រឹក្សាប្រតិបត្តិ

ប្រធានក្រុមប្រឹក្សាប្រតិបត្តិ ជាប្រធានរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ហើយប្រធានក្រុមប្រឹក្សាប្រតិបត្តិ គឺត្រូវបានជ្រើសរើសនៅក្នុងកិច្ចប្រជុំដំបូងរបស់ខ្លួន។ ក្នុងករណីដែលការបោះឆ្នោតជ្រើសរើសប្រធានក្រុមប្រឹក្សាប្រតិបត្តិ មិនមានបេក្ខជនណាម្នាក់ទទួលបានសំលេងភាគច្រើនដាច់ខាត់ទេ បេក្ខជន ២រូប ដែលមានសំលេងឆ្នោតច្រើនជាងគេ ត្រូវបានឲ្យឈរឈ្មោះម្តងទៀតនៅក្នុងការបោះឆ្នោតជ្រើសរើសប្រធានក្រុមប្រឹក្សាប្រតិបត្តិជាលើកទី ២។[23]

អនុប្រធាន ជាអ្នកជួយដល់ការងាររបស់ប្រធានក្រុមប្រឹក្សាប្រតិបត្តិ ហើយជំនួសតំណែងប្រធាននៅពេលដែលប្រធានអវត្តមាន។ ការជ្រើសរើសអនុប្រធាន គឺត្រូវយកតាមសំលេងបោះឆ្នោតភាគច្រើន ហើយក្នុងករណីដែលការបោះឆ្នោតមានសំលេងស្មើគ្នា អ្នកដែលមានអាយុច្រើនជាងមាន អត្ថិភាព។[24]

---

[18] មាត្រា ២២ នៃអនុក្រឹត្យស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម (ឧបសម្ព័ន្ធទី១)

[19] មាត្រា ១២ នៃអនុក្រឹត្យស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម (ឧបសម្ព័ន្ធទី១)

[20] មាត្រា ១៣ នៃអនុក្រឹត្យស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម (ឧបសម្ព័ន្ធទី១)

[21] មាត្រា ១៤ កថាខណ្ឌទី ៣ នៃអនុក្រឹត្យស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម (ឧបសម្ព័ន្ធទី១)

[22] បទសម្ភាសន៍ជាមួយលោក រស់ មុនិន្ទ ជាប្រធាន នៃក្រុមប្រឹក្សាប្រតិបត្តិ នៅថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៤

[23] មាត្រា ១៤ កថាខណ្ឌទី១ និងទី៤ នៃអនុក្រឹត្យស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម (ឧបសម្ព័ន្ធទី១)

[24] មាត្រា ១៤ កថាខណ្ឌទី២ និងទី ៥ នៃអនុក្រឹត្យស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម (ឧបសម្ព័ន្ធទី១)

## ខ. ហិរញ្ញិក និងសមាជិកនៃក្រុមប្រឹក្សាប្រតិបត្តិ

ហិរញ្ញិក ជាអ្នកគ្រប់គ្រងមូលនិធិរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ព្រមទាំងប្រមូលចំណូល និងទូទាត់ការចំណាយផ្សេងៗ រួមទាំងត្រូវមានគណនីចរន្ត និងទទួលខុសត្រូវលើគណនីនោះ។ ការជ្រើសរើសហិរញ្ញិក គឺមានភាពដូចគ្នាទៅនឹងការជ្រើសរើសអនុប្រធានរបស់ក្រុមប្រឹក្សាប្រតិបត្តិដែរ។[25]

សមាជិករបស់ក្រុមប្រឹក្សាប្រតិបត្តិជាអ្នកជួយដល់ការងាររបស់ **ម.ជ.ម** និងបំពេញភារកិច្ចដែលក្រុមប្រឹក្សាប្រតិបត្តិប្រគល់ជូន។[26] ការជ្រើសរើសសមាជិករបស់ក្រុមប្រឹក្សាប្រតិបត្តិ គឺធ្វើឡើងតាមការបោះឆ្នោតជាសម្ងាត់ ហើយអ្នកដែលមានសិទ្ធិឈរឈ្មោះឲ្យមហាសន្និបាតបោះឆ្នោតឲ្យបាន លុះត្រាតែបុគ្គលនោះបានចុះឈ្មោះជាមជ្ឈត្តករក្នុងបញ្ជីនៃ **ម.ជ.ម**។[27] មជ្ឈត្តករដែលអាចឈរឈ្មោះជាសមាជិកបានត្រូវបំពេញនូវលក្ខខណ្ឌដូចខាងក្រោម:

- ការស្នើតែងតាំងបេក្ខជនមួយរូបដោយសមាជិកនៃ **ម.ជ.ម** ២រូប
- មានការយល់ព្រមពីសាមីខ្លួន
- សំណើរត្រូវធ្វើជាលាយលក្ខណ៍អក្សរ និងមានការចុះហត្ថលេខា។[28]

ទោះបីជាបានក្លាយជាសមាជិកនៃក្រុមប្រឹក្សាប្រតិបត្តិក៏ដោយ ប្រសិនបើសមាជិកណាម្នាក់របស់ក្រុមប្រឹក្សាប្រតិបត្តិក្លាយជាជនអសមត្ថភាព ឬត្រូវបានផ្តន្ទាទោសពីបទមជ្ឈឹម ឬឧក្រិដ្ឋ ឬអវត្តមានក្នុងការប្រជុំចំនួន ៣ដងជាប់ៗគ្នាដោយគ្មានមូលហេតុដូចមានចែងក្នុងមាត្រា ២១នៃអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម នោះសមាជិកនោះនឹងត្រូវបានបាត់បង់មុខតំណែងជាសមាជិកនៃក្រុមប្រឹក្សាប្រតិបត្តិ។ ក្នុងករណីដែលមានការបាត់បង់សមាជិក ប្រធាន**ម.ជ.ម**ត្រូវកោះប្រជុំដើម្បីជ្រើសរើសសមាជិកបង្គ្រប់ជំនួសកន្លែងសមាជិកដែលបានបាត់បង់នោះ។[29]

### ២.១.៣. អគ្គលេខាធិការដ្ឋាន

---

[25] មាត្រា ១៤ កថាខណ្ឌទី២ និងទី ៦ នៃអនុក្រឹត្យស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម (ឧបសម្ព័ន្ធទី១)

[26] មាត្រា ១៤ កថាខណ្ឌទី ៧ នៃអនុក្រឹត្យស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម (ឧបសម្ព័ន្ធទី១)

[27] មាត្រា ១៦ និង១៨ នៃអនុក្រឹត្យស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម (ឧបសម្ព័ន្ធទី១)

[28] មាត្រា ១៩ នៃអនុក្រឹត្យស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម (ឧបសម្ព័ន្ធទី១)

[29] មាត្រា ២៣ នៃអនុក្រឹត្យស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម (ឧបសម្ព័ន្ធទី១)

អគ្គលេខាធិការដ្ឋាន ជាសេនាធិការក្រុមប្រឹក្សាប្រតិបត្តិ ដែលមានអគ្គលេខាធិការមួយរូប និងអគ្គលេខាធិការរងមួយចំនួន ដែលត្រូវបានជ្រើសរើសដោយក្រុមប្រឹក្សាប្រតិបត្តិ។ អគ្គលេខាធិការដ្ឋានក្នុងនាមជាសេនាធិការ គឺមានតួនាទី និងភារកិច្ចដូចតទៅ:

- "គ្រប់គ្រងលើការងារ និងសកម្មភាពប្រចាំថ្ងៃរបស់ **ម.ជ.ម**
- អនុវត្តគោលនយោបាយដែលក្រុមប្រឹក្សាប្រតិបត្តិដាក់ចេញ
- រៀបចំកិច្ចប្រជុំរបស់ក្រុមប្រឹក្សាប្រតិបត្តិ មហាសន្និបាត និងកិច្ចប្រជុំផ្សេងៗ
- រក្សាទុកនៅឯកសារ
- ប្រមូលព័ត៌មានដែលពាក់ព័ន្ធ និងសកម្មភាពមជ្ឈត្តការផ្នែកពាណិជ្ជកម្ម
- ផ្តួចផ្តើមគំនិតលើកិច្ចការថ្មីៗ រៀបចំសកម្មភាព និងគម្រោងនានាដែលជួយទ្រទ្រង់តួនាទីរបស់ **ម.ជ.ម**
- ទ្រទ្រង់ផ្នែកបោះពុម្ពនានារបស់ **ម.ជ.ម** រួមទាំងកាន់កាប់គេហទំព័ររបស់ **ម.ជ.ម**
- រៀបចំការបណ្តុះបណ្តាល
- បំពេញភារកិច្ចផ្សេងៗដែលក្រុមប្រឹក្សាប្រគល់ជូន។" [30]

ក្រៅពីតួនាទី និងភារកិច្ចដូចមានចែងខាងលើ អគ្គលេខាធិការដ្ឋានត្រូវបំពេញមុខងារបន្ថែមទៀតដែលបានកំណត់នៅក្នុងបទបញ្ជាផ្ទៃក្នុងរបស់**ម.ជ.ម** គឺការគ្រប់គ្រងសំណុំរឿង ការងាររដ្ឋបាល និងហិរញ្ញវត្ថុ រួមទាំងការធ្វើទំនាក់ទំនងសាធារណៈជាដើម។[31] ក្នុងការគ្រប់គ្រងសំណុំរឿង អគ្គលេខាធិការដ្ឋានត្រូវគ្រប់គ្រងកាលវិភាគនៃសំណុំរឿងវិវាទ និងដំណើរការឯកសារផ្សេងៗ ព្រមទាំងទទួល និងពិនិត្យទៅលើពាក្យទាមទាររបស់ភាគីទាមទារនៃវិវាទផងដែរ។ ចំពោះផ្នែករដ្ឋបាល និងហិរញ្ញវត្ថុវិញ គឺកំណត់ និងប្រមូលកម្រៃសេវាចុះបញ្ជី កម្រៃសេវារដ្ឋបាល កម្រៃសេវាតែងតាំងមជ្ឈត្តករ និងកម្រៃសេវាវិវាទមជ្ឈត្តការពីភាគីវិវាទ។ ចំនែកឯការងាររដ្ឋបាល អគ្គលេខាធិការដ្ឋានត្រូវរក្សាឈ្មោះរបស់មជ្ឈត្តករ និងសមាជិកដ៏ទៃទៀតរបស់**ម.ជ.ម**។

ដោយហេតុថា **ម.ជ.ម** ទើបតែបង្កើតឡើង ហើយដំណើរការនៃ **ម.ជ.ម** មិនទាន់រៀបចំរួចរាល់ ដូច្នេះអគ្គលេខាធិការដ្ឋាននៃ **ម.ជ.ម** ដែលជាសេនាធិការរបស់ក្រុមប្រឹក្សាប្រតិបត្តិមិនទាន់ត្រូវបានជ្រើសរើស និងបង្កើតឡើងនោះទេ។[32]

### ២.១.៤. សវនកម្ម

[30] មាត្រា ២៦ នៃអនុក្រឹត្យស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម (ឧបសម្ព័ន្ធទី១)

[31] ប្រការ ៩ នៃបទបញ្ជាផ្ទៃក្នុងរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម (ឧបសម្ព័ន្ធទី៣)

[32] បទសម្ភាសន៍ជាមួយលោក ប៉ា ងួនគា ជាហិរញ្ញិក នៃក្រុមប្រឹក្សាប្រតិបត្តិ នៅថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៤

ដោយអនុលោមតាមមាត្រា ៣៩ នៃអនុក្រឹត្យស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម **ម.ជ.ម** តម្រូវឲ្យមានសវនករ ដើម្បីធ្វើសវនកម្មប្រចាំឆ្នាំ និងធ្វើសវនកម្មតាមការស្នើសុំរបស់ប្រធាននៃ **ម.ជ.ម** ព្រមទាំងបង្ហាញរបាយការណ៍របស់ខ្លួនទៅមហាសន្និបាត។ សវនករ ត្រូវបានជ្រើសតាំងដោយមានការយល់ព្រមពីមហាសន្និបាត ដែលមានអាណត្តិរយៈពេល ១ឆ្នាំ និងអាចត្រូវបានជ្រើសតាំងសារជាថ្មីបាន។ សវនករមានសិទ្ធិឲ្យសមាជិក និងបុគ្គលិកគ្រប់រូបរបស់ **ម.ជ.ម** ផ្ដល់នូវព័ត៌មាន និងសេចក្ដីពន្យល់នានាដែលសវនករត្រូវការបាន។[33]

ទន្ទឹមនឹង **ម.ជ.ម** មានសវនករផ្ទាល់ខ្លួន អាជ្ញាធរសវនកម្មជាតិដែលបង្កើតឡើងដោយច្បាប់ស្ដីពីសវនកម្ម និងយោងតាមមាត្រា ៣នៃច្បាប់ដដែល អាជ្ញាធរសវនកម្មជាតិក៏មានសិទ្ធិអំណាចក្នុងការធ្វើសវនកម្មទៅលើមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្មដែរ ដោយសារ **ម.ជ.ម** ជាគ្រឹះស្ថានសាធារណៈ ហើយធ្លាប់បានទទួលជំនួយពីរដ្ឋាភិបាលគឺក្រសួងពាណិជ្ជកម្មក្នុងការដំណើរការមជ្ឈមណ្ឌលនេះ។[34] ដូច្នេះអាជ្ញាធរសវនកម្មជាតិអាចធ្វើសវនកម្មលើមជ្ឈមណ្ឌលនេះបាន។

## ២.២. សមាជិកនៃមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម

សមាជិកនៃមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្មមាន មជ្ឈត្តករចំនួន ៥៣រូប នីតិបុគ្គលចំនួន ១០ និងសមាជិកគាំទ្រមួយចំនួន។[35] និតិបុគ្គលចំនួន ១០ ត្រូវបានជ្រើសមកពីស្ថាប័នផ្សេងៗដូចជាក្រសួងពាណិជ្ជកម្ម ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្រសួងសុខាភិបាល និងក្រសួងអប់រំជាដើម។[36]

### ២.២.១. លក្ខខណ្ឌចូលជាសមាជិកនៃ ម.ជ.ម

បុគ្គលទាំងឡាយដែលចង់ក្លាយជាសមាជិកនៃ **ម.ជ.ម** អាចជានីតិបុគ្គល ឬរូបវន្តបុគ្គលដូចជា:

- រូបវន្តបុគ្គលជាមជ្ឈត្តករដែលបានចុះឈ្មោះក្នុងបញ្ជីរបស់ **ម.ជ.ម**
- សភាពាណិជ្ជកម្ម
- គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

---

[33] មាត្រា ៤០ នៃអនុក្រឹត្យស្ដីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម (ឧបសម្ព័ន្ធទី១)

[34] មាត្រា ១ នៃច្បាប់ស្ដីពី សនវកម្មនៃព្រះរាជាណាចក្រកម្ពុជា

[35] បទសម្ភាសន៍ជាមួយលោក ប៉ា ងួនគា ជាហិរញ្ញិក នៃក្រុមប្រឹក្សាប្រតិបត្តិ នៅថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៤

[36] http://www.cambodiadaily.com/archives/arbitration-center-elects-board-members-8188/

- រាល់សមាគមដែលប្រមូលផ្តុំពាណិជ្ជករ ឧស្សាហកម្ម អាជីវករ និងសេវាករ។"[37]

ជាមួយនឹងការកំណត់របស់ច្បាប់ខាងលើ រូបវន្តបុគ្គលជាមជ្ឈត្តករដែលបានចុះបញ្ជីរបស់ **ម.ជ.ម** ជាបុគ្គលដែលមានសារៈសំខាន់ណាស់សំរាប់ **ម.ជ.ម** ព្រោះថាមជ្ឈត្តករនេះ បានបញ្ចប់នូវបរិញ្ញាបត្រជំនាញណាមួយរួចមកហើយ ហើយថែមទាំងមានបទពិសោធន៍ការងារ ៣ឆ្នាំផងទើបអាចចុះឈ្មោះជាមជ្ឈត្តករបាន។ បន្ថែមពីនេះក្រោយពីបានចុះឈ្មោះ មជ្ឈត្តករក៏ត្រូវបានឆ្លងកាត់វគ្គបណ្តុះបណ្តាលមជ្ឈត្តករផងដែរ។ ចំពោះគណៈមេធាវី ដែលជានីតិបុគ្គលវិញ សមាជិកភាគច្រើនជាបុគ្គលដែលមានចំណេះដឹងផ្នែកច្បាប់ ដែលជាតម្រូវការក្នុងការធ្វើការដោះស្រាយវិវាទ។ ប៉ុន្តែវិវាទដែលយកមកដោះស្រាយតាមរយៈមជ្ឈត្តការជាវិវាទពាណិជ្ជកម្ម ដូច្នេះច្បាប់ក៏អនុញ្ញាតឲ្យផងដែរដល់សមាគមដែលប្រមូលផ្តុំពាណិជ្ជករ ឬអាជីវករធ្វើជាសមាជិក ទោះបីជានីតិបុគ្គលនេះមិនមានចំណេះដឹងជ្រាលជ្រៅផ្នែកច្បាប់ តែនីតិបុគ្គលនេះមានបទពិសោធន៍ ក៏ដូចជាជំនាញទាក់ទងទៅនឹងបញ្ហា និងការអនុវត្តជាក់ស្តែងដែលធ្វើការជំណើរ និងការចេញសេចក្តីសម្រេចមានភាពយុត្តិធម៌។

រាល់ពាក្យស្នើសុំចូលជាសមាជិកត្រូវដាក់ឲ្យត្រួតពិនិត្យដោយក្រុមប្រឹក្សាប្រតិបត្តិ ដោយភ្ជាប់ជាមួយឯកសារ និងបង់វិភាគទានតាមការកំណត់របស់ **ម.ជ.ម**។[38] នៅពេលដែលបានក្លាយជាសមាជិកនៃ មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្មហើយ សមាជិកនីមួយៗត្រូវសុំបន្តវិញ្ញាបនបត្រចុះបញ្ជីរបស់ខ្លួនជារៀងរាល់ឆ្នាំដោយការបង់ភាគទានប្រចាំឆ្នាំ ដើម្បីបន្តសមាជិកភាពរបស់ខ្លួន ហើយរាល់ការផ្លាស់ប្តូរអាស័យដ្ឋានវិជ្ជាជីវៈ ឬអាស័យដ្ឋានផ្ទាល់ខ្លួន សមាជិកនោះត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅ **ម.ជ.ម** ក្នុងរយៈពេល ១ខែគិតចាប់ពីថ្ងៃផ្លាស់ប្តូរ។[39]

### ២.២.២. ការបាត់បង់សមាជិកភាពរបស់សមាជិកនៃ ម.ជ.ម

ទោះបីជាបានក្លាយទៅជាសមាជិកនៃ **ម.ជ.ម** ហើយក្តី ក្នុងករណីដូចមានចែងក្នុងមាត្រា ៣៥ នៃអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការពាណិជ្ជកម្ម សមាជិកនៃ **ម.ជ.ម** នឹងត្រូវបាត់សមាជិកភាព ហើយការបាត់បង់សមាជិកនេះគឺត្រូវបានសម្រេចដោយក្រុមប្រឹក្សាប្រតិបត្តិ។ ករណីបាត់បង់សមាជិកភាពមានដូចខាងក្រោម៖

- មិនបានបន្តចុះបញ្ជីជាមជ្ឈត្តករជាមួយ **ម.ជ.ម** តាមការកំណត់

[37] មាត្រា ១២ នៃច្បាប់ស្តីពី មជ្ឈត្តការផ្នែកពាណិជ្ជកម្ម

[38] មាត្រា ២៨ នៃអនុក្រឹត្យស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម (ឧបសម្ព័ន្ធទី១)

[39] មាត្រា ៣៣ នៃអនុក្រឹត្យស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម (ឧបសម្ព័ន្ធទី១)

- ក្លាយជាជនអសមត្ថភាព ដែលមិនអាចបំពេញការងាររបស់ខ្លួនបាន
- ត្រូវបានវិនិច្ឆ័យថា ក្ស័យធន ឬដាក់ឲ្យជំរះបញ្ជី
- សុំលាលែងជាលាយលក្ខណ៍អក្សរទៅ **ម.ជ.ម**
- ត្រូវផ្តន្ទាទោសពីបទមជ្ឈឹម ឬឧក្រិដ្ឋ
- បានរំលោភក្រមសសីលធម៌របស់មជ្ឈត្តករ និងបទបញ្ជាផ្ទៃក្នុង
- ទទួលមរណភាព
- ខកខានមិនបានបង់ភាគទានតាមការកំណត់

មុននឹងធ្វើការដកហូតសមាជិកភាពរបស់សមាជិកណាម្នាក់ សមាជិកនោះត្រូវបានផ្តល់ឱកាសឲ្យធ្វើការដោះសារទៅ **ម.ជ.ម** ជាលាយលក្ខណ៍អក្សរក្នុងពេលវេលាកំណត់មួយ។ ក្រោយពីបានផ្តល់ឱកាសដល់សមាជិកនោះក្នុងការដោះសាររួចហើយ ប្រសិនបើក្រុមប្រឹក្សាប្រតិបត្តិសម្រេចដកសមាជិកភាពរបស់សមាជិកនោះ ក្រុមប្រឹក្សាប្រតិបត្តិត្រូវផ្តល់ហេតុផលជាលាយលក្ខណ៍អក្សរទៅដល់សមាជិកនោះវិញ។ ក្នុងករណីដែលសមាជិកដែលត្រូវបានដកសមាជិកភាពមិនសុខចិត្តនឹងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាប្រតិបត្តិ សមាជិកនោះអាចធ្វើការប្តឹងទៅសាលាឧទ្ធរណ៍បាន។[40]

### ២.២.៣. ការជ្រើសរើសមជ្ឈត្តករ

ការជ្រើសរើសមជ្ឈត្តករលើកដំបូង ជាភារកិច្ចរបស់គណៈកម្មការរៀបចំ និងជ្រើសរើស មជ្ឈត្តករ។ អាស្រ័យហេតុនេះនៅថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ ២០០៩ គណៈកម្មការរៀបចំ និងជ្រើសរើសមជ្ឈត្តករដែលមានឯ.ឧ ម៉ៅ ថូរ៉ា ជាប្រធានបានចេញសេចក្តីជូនដំណឹងលេខ២៧៤០ ព.ណ ធតក ស្តីពីការជ្រើសរើសមជ្ឈត្តករដំបូង ដើម្បីបង្កើតមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តករផ្នែកពាណិជ្ជកម្ម។ ការជ្រើសរើសមជ្ឈត្តករលើកដំបូងមានការកំណត់ចំនួនពី៥០ ទៅ៦០រូប។ បុគ្គលដែលត្រូវបានជ្រើសរើសដំបូងមិនតិចជាង ៥០រូប ក្រោយពីបានឆ្លងកាត់វគ្គបណ្តុះបណ្តាល និងទទួលបានជោគជ័យពីការប្រឡង ទើបអាចដាក់ពាក្យសុំធ្វើជាមជ្ឈត្តករនៅមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តករផ្នែកពាណិជ្ជកម្ម។[41]

#### ក. លក្ខខណ្ឌនៃការជ្រើសរើសមជ្ឈត្តករលើកដំបូង

[40] មាត្រា ៣៦ នៃអនុក្រឹត្យស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម (ឧបសម្ព័ន្ធទី១)

[41] មាត្រា ៥២ កថាខណ្ឌទី១ នៃអនុក្រឹត្យស្តីពី ការកែសម្រួលមាត្រា ៥២ នៃអនុក្រឹត្យស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម (ឧបសម្ព័ន្ធទី១)

បេក្ខជនដែលអាចដាក់ពាក្យជាមជ្ឈត្តករដំបូងនៅព្រះរាជាណាចក្រកម្ពុជា អាចជារូបវន្តបុគ្គលដែលមានសញ្ជាតិខ្មែរ ឬបរទេស ហើយត្រូវបំពេញនូវលក្ខណៈសម្បត្តិដូចខាងក្រោម៖

- មានអាយុចាប់ពី ៣០ ឆ្នាំឡើងទៅ
- មានបរិញ្ញាបត្រជំនាញណាមួយ ក្រោយពីបានបញ្ចប់ការសិក្សានៅតាមសាកលវិទ្យាល័យក្នុងព្រះរាជាណាចក្រកម្ពុជា ឬនៅបរទេស
- មានបទពិសោធន៍ការងារយ៉ាងតិច ៣ឆ្នាំ។

លើសពីនេះទៅទៀត ប្រសិនបើពុំមានលក្ខណៈខាងលើនេះទេ បេក្ខជនដែលមានសញ្ជាតិខ្មែរ ឬបរទេស ត្រូវជាបុគ្គលដែលធ្លាប់ធ្វើជា៖

- សមាជិកនៃស្ថាប័នវិជ្ជាជីវៈមជ្ឈត្តករផ្នែកពាណិជ្ជកម្ម ដែលទទួលស្គាល់ដោយគណៈកម្មការ ឬ
- មជ្ឈត្តករ ឬអ្នកតំណាងក្នុងដំណើរការមជ្ឈត្តការផ្នែកពាណិជ្ជកម្មចាប់ពី ៣ដងឡើងទៅ ឬបានសរសេរសេចក្តីបង្គាប់មជ្ឈត្តការផ្នែកពាណិជ្ជកម្មចំនួនយ៉ាងតិច ៣ ក្នុងពេលដែលបុគ្គលនោះធ្វើជាមជ្ឈត្តករ ។

ក្រៅពីនេះមជ្ឈត្តករមិនត្រូវស្ថិតនៅក្រោមឋានានុក្រមជាមន្ត្រីនៃស្ថាប័ននីតិប្រតិបត្តិ ស្ថាប័ននីតិបញ្ញត្តិ និងតុលាការ ព្រមទាំងមិនធ្លាប់ត្រូវបានផ្តន្ទាទោសពីបទមជ្ឈឹម ឬឧក្រិដ្ឋណាមួយឡើយ ហើយបានបញ្ចប់វគ្គបណ្តុះបណ្តាលមជ្ឈត្តការផ្នែកពាណិជ្ជកម្ម។[42] ដោយគោរពតាមលក្ខខណ្ឌខាងលើ បេក្ខជនត្រូវធ្វើការប្រឡងទទួលបានជោគជ័យទើបអាចដាក់ក្លាយជាមជ្ឈត្តករបាន។[43]

ដោយឡែកក្រោយពីបានបើកមហាន្និបាតលើកទីមួយរបស់ **ម.ជ.ម** និងអនុម័តទៅលើបទបញ្ជាផ្ទៃក្នុងរបស់**ម.ជ.ម** រូបវន្តដែលអាចសុំចូលជាមជ្ឈត្តករបន្ថែមទៀតគឺត្រូវមានលក្ខណៈសម្បត្តិដូចខាងក្រោម:

- មានអាយុចាប់ពី ៣០ ឆ្នាំឡើងទៅ
- មានបរិញ្ញាបត្រជំនាញណាមួយ ក្រោយពីបានបញ្ចប់ការសិក្សានៅតាមសាកលវិទ្យាល័យក្នុងព្រះរាជាណាចក្រកម្ពុជា ឬនៅបរទេស

[42] មាត្រា ២៩ នៃអនុក្រឹត្យស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម (ឧបសម្ព័ន្ធទី១) និងសេចក្តីជូនដំណឹងស្តីពីការជ្រើសរើសមជ្ឈត្តករដំបូងដើម្បីបង្កើតមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម (ឧបសម្ព័ន្ធទី៧)

[43] មាត្រា ៥២ កថាខណ្ឌទី១ នៃអនុក្រឹត្យស្តីពី ការកែសម្រួលមាត្រា ៥២ នៃអនុក្រឹត្យស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម (ឧបសម្ព័ន្ធទី១)

- បានឆ្លងកាត់វគ្គបណ្តុះបណ្តាលផ្នែកមជ្ឈត្តការ
- បានប្រឡងជាប់ការប្រលងដែលរៀបចំដោយ**ម.ជ.ម** ស្ថាប័នផ្សេងដែលទទួលស្គាល់ដោយ**ម.ជ.ម**

ឬមួយរូបវន្តបុគ្គលនោះបានបំពេញនូវលក្ខខណ្ឌខាងក្រោមៈ

- ធ្លាប់ជាសមាជិកនៃស្ថាប័នវិជ្ជាជីវៈមជ្ឈត្តករផ្នែកពាណិជ្ជកម្មយ៉ាងតិច ២ឆ្នាំ
- ធ្លាប់ជាមជ្ឈត្តករ ឬអ្នកតំណាងក្នុងដំណើរការមជ្ឈត្តការផ្នែកពាណិជ្ជកម្មចាប់ពី ៣ដងឡើងទៅ ឬបានសរសេរសេចក្តីបង្គាប់មជ្ឈត្តការផ្នែកពាណិជ្ជកម្មចំនួនយ៉ាងតិច ៣ ក្នុងពេលដែលបុគ្គលនោះធ្វើជាមជ្ឈត្តករ ក្នុងន័យនេះគឺសំដៅដល់មជ្ឈត្តករដែលជា មជ្ឈត្តករបរទេស ឬមជ្ឈត្តករអាក់ហុក ដែលធ្លាប់បានដំណើរការមជ្ឈត្តការនៅឯបរទេស និងត្រូវធ្វើការប្រឡងដើម្បីធ្វើជាមជ្ឈត្តករ
- មានវិញ្ញាបនប័ត្រចុះបញ្ជីជាមជ្ឈត្តករ និងបានរក្សាសមាជិកភាពជាមជ្ឈត្តករយ៉ាងតិច ២ឆ្នាំជាប់គ្នា។[44]

ចំនែកឯនៅប្រទេសសង្ហឹបុរីវិញ មជ្ឈត្តករត្រូវមានលក្ខណៈដូចខាងក្រោមៈ

- មានបរិញ្ញាបត្រ
- បទពិសោធន៍ការងារចំនួនយ៉ាងតិច ១០ឆ្នាំ
- ជាសមាជិកនៅវិទ្យាស្ថានជំនាញមជ្ឈត្តករ ឬវិទ្យាស្ថានមជ្ឈត្តករសង្ហឹបុរី ឬវិទ្យាស្ថានវិជ្ជាជីវៈមជ្ឈត្តការផ្សេងទៀតដែលមានភាពប្រហាក់ប្រហែលគ្នា
- មានធ្លាប់ធ្វើជាមជ្ឈត្តករក្នុងការការដោះស្រាយវិវាទ ៥ដង ឬច្រើនជាងនេះ
- បានចេញនូវសេចក្តីសម្រេចមជ្ឈត្តវិនិច្ឆ័យយ៉ាងតិចចំនួន ២
- មានអាយុចាប់ពី ៣០ឆ្នាំទៅ ៧៥ឆ្នាំ។[45]

នោះបញ្ជាក់ឲ្យឃើញថា ដើម្បីក្លាយជាមជ្ឈត្តករបាន គឺទាមទារឲ្យមាននូវបទពិសោធន៍ការងារច្រើននៅក្នុងវិស័យពាណិជ្ជកម្ម និងបានឆ្លងការវគ្គបណ្តុះបណ្តាលជាមជ្ឈត្តករ។

### ខ. វគ្គបណ្តុះបណ្តាលមជ្ឈត្តករដំបូង

[44] ប្រការ ១២ នៃបទបញ្ជាផ្ទៃក្នុងរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម (ឧបសម្ព័ន្ធទី៣)

[45] http://www.siac.org.sg/our-arbitrators/standards-for-admission-to-siac-panel

ក្រោយពីការប្រកាសជ្រើសរើសមជ្ឈត្តករដំបូង ក្រសួងពាណិជ្ជកម្មក៏បានប្រកាសបញ្ជីឈ្មោះបេក្ខជនដែលត្រូវបានជ្រើសរើសជាមជ្ឈត្តករដំបូងចំនួន ៥៦រូប នៅថ្ងៃទី១២ ខែមេសា ឆ្នាំ២០១០ ដែលត្រូវទទួលការបណ្តុះបណ្តាល។ សិក្ខាកាមនៃវគ្គបណ្តុះបណ្តាលនេះត្រូវបានបង្ហាត់បង្រៀន និងឆ្លងកាត់ការជ្រើសរើសវាយតម្លៃយ៉ាងហ្មត់ចត់ពីគ្រូឧទ្ទេសនាមជាជនជាតិខ្មែរចំនួន០៣រូប និងជនជាតិសឹង្ហបុរីចំនួន ០៥រូប។ កម្មវិធីបណ្តុះបណ្តាលមានរយៈពេលជាងមួយខែ ដែលប្រព្រឹត្តទៅពីថ្ងៃ១៨ ខែមិថុនា ដល់ថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១០។ កម្មវិធីបណ្តុះបណ្តាលគ្របដណ្តប់លើប្រធានបទសេចក្តីផ្តើមនៃមជ្ឈត្តការព្រមទាំងសវនាការនៃមជ្ឈត្តការ ដែលបានសិក្សាទៅលើនីតិវិធីរបស់មជ្ឈត្តការ ច្បាប់ពាណិជ្ជកម្ម ជំនាញរបស់មជ្ឈត្តករ និងពីរបៀបសរសេរមជ្ឈត្តវិនិច្ឆ័យ។[46]

វគ្គសិក្សានេះបានទទួលការឧបត្ថម្ភជាជំនួយដូចជា ជំនួយបច្ចេកទេសពីសហាគមន៍អ៊ឺរ៉ុបប្រចាំនៅកម្ពុជា សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC) ប្រចាំនៅកម្ពុជា ដែលជាសមាជិកនៃក្រុមធនាគារពិភពលោក (ADB) ព្រមទាំងកិច្ចសហប្រតិបត្តិការជាមួយប្រទេសហ្វាំងឡង់ អៀកឡង់ ស្វីស និងប្រទេសណូវែលហ្សេឡង់។[47]

### គ. ការប្រលងជ្រើសរើសបញ្ចប់វគ្គបណ្តុះបណ្តាលមជ្ឈត្តការផ្នែកពាណិជ្ជកម្ម

បន្ទាប់ពីបានបញ្ចប់វគ្គបណ្តុះបណ្តាលសម្រាប់មជ្ឈត្តករដំបូង ក្រសួងពាណិជ្ជកម្មក៏បានចេញសេចក្តីជូនដំណឹងលេខ៣៩៩៧ ព.ណ នតក ស្តីពីការប្រលងបញ្ចប់វគ្គបណ្តុះបណ្តាលសម្រាប់មជ្ឈត្តករដំបូង នៅថ្ងៃទី២០ ខែសីហា ឆ្នាំ២០១០។ ការប្រលងមានចំនួន ២ដង ចំពោះបេក្ខជនដែលមិនបានទទួលជោគជ័យពីការប្រលងលើកទី១ មានសិទ្ធិប្រលងលើកទី២ទៀត។

ការប្រលងរួមមានពីម៉ូឌុលៈ

- ម៉ូឌុលទី ១ ៖ ជំនាញមជ្ឈត្តការ
- ម៉ូឌុលទី ២ ៖ ច្បាប់ពាណិជ្ជកម្ម។

ការប្រលងសម្រាប់មណ្ឌលនីមួយៗមានរយៈពេលបីម៉ោង។ វិញ្ញាសារប្រឡងត្រូវបានរៀបចំ ឡើងដោយគ្រូបណ្តុះបណ្តាល ដែលមកពីវិទ្យាស្ថានមជ្ឈត្តការសាំងហ្គាពួរ (SIArb) លោក សុខ ស៊ីផានី និងអ្នកជំនាញផ្សេងទៀត។ វិញ្ញាសារប្រឡងគ្របដណ្តប់លើប្រធានបទដែលមានក្នុងកម្មវិធីបណ្តុះបណ្តាល។ ចំពោះភាសាវិញ បេក្ខជនអាចធ្វើការប្រលងជាភាសាខ្មែរ ឬអង់គ្លេស។

---

[46] បទសម្ភាសន៍ជាមួយលោកស្រី ស៊ីន គឹមស៊ាន ជាមជ្ឈត្តករ នៃ ម.ជ.ម នៅថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១៤

[47] http://www.moc.gov.kh/pdf/pdfnews/2010_06_15_Launching_of_Training_for_the_first_Group_of_NAC.pdf

សម្រាប់ ម៉ូឌុលស្តីពីជំនាញមជ្ឈត្តការ លទ្ធផលនៃការប្រឡងនឹងត្រូវផ្អែកលើលទ្ធផលសរុបរវាងការវាយតម្លៃបេក្ខជននៅ ក្នុងពេលពិភាក្សាក្រុមក្នុងកំឡុងវគ្គបណ្តុះបណ្តាលឆ្នាំ២០១០ និងលទ្ធផលនៃការប្រឡងសរសេរ។ សម្រាប់ម៉ូឌុលស្តីពីច្បាប់ពាណិជ្ជកម្ម លទ្ធផលនៃការប្រឡងនឹងត្រូវផ្អែកទៅលើលទ្ធផលនៃការសរសេរតែប៉ុណ្ណោះ។ រីឯការវិនិច្ឆ័យក្នុងការដាក់ពិន្ទុ និងសេចក្តីសម្រេចរបស់គ្រូបណ្តុះបណ្តាលត្រូវបានចាត់ទុកថាជាសេចក្តីសម្រេចស្ថាពរនឹងមិនត្រូវបានតវ៉ាឡើយ។ គួរបញ្ជាក់ផងដែរថាមានតែបេក្ខជនដែលបានប្រឡងជាប់ម៉ូឌុលទាំងពីរប៉ុណ្ណោះ ទើបមានសិទ្ធិចុះឈ្មោះជាមជ្ឈត្តករជាមួយមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការ។[48]

នៅក្នុងការប្រឡងបញ្ចប់វគ្គបណ្តុះបណ្តាលមជ្ឈត្តការផ្នែកពាណិជ្ជកម្មលើកទី១ លើមុខជំនាញច្បាប់ពាណិជ្ជកម្ម ដែលបានប្រព្រឹត្តទៅនៅថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០១០ មានបេក្ខជនចំនួន ៤០រូបបានប្រឡងជាប់ជាស្ថាពរ។ យ៉ាងណាមិញបេក្ខជន ដែលមិនទទួលជោគជ័យក្នុងការប្រឡងលើកទី១ និងបេក្ខជនដែលមិនបានចូលរួមប្រឡងលើកទី១ អាចប្រឡងលើកទី២ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១១ វេលាម៉ោង៨ និង៣០នាទី ដល់ម៉ោង១១ និង៣០នាទី។[49]

ចំណែកឯលទ្ធផល នៃការប្រឡងបញ្ចប់វគ្គបណ្តុះបណ្តាលមជ្ឈត្តការផ្នែកពាណិជ្ជកម្មលើកទី១លើមុខជំនាញមជ្ឈត្តការពាណិជ្ជកម្ម ដែលបានប្រព្រឹត្តទៅនៅថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១០ វិញមានបេក្ខជនចំនួន ៣៨រូប ប៉ុណ្ណោះដែលបានប្រឡងជាប់ដោយជោគជ័យ។ មិនខុសគ្នាពីការប្រឡងច្បាប់ពាណិជ្ជកម្មដែរបេក្ខជនដែលមិនទទួលជោគជ័យ ឬអវត្តមានក្នុងការប្រឡងលើកទី១ មានឱកាសចូលរួមការប្រឡងលើកទី២ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១១ វេលាម៉ោង៨ និង៣០ ដល់ម៉ោង១១ និង៣០នាទី។[50]

សរុបមកក្រោយពីបានបញ្ចប់វគ្គបណ្តុះបណ្តាល មានតែបេក្ខជនចំនួន ៥២រូបប៉ុណ្ណោះដែលបានបញ្ចប់វគ្គបណ្តុះបណ្តាលក្នុងចំនោម ៥៦រូបដែលត្រូវបានជ្រើសរើសជាមជ្ឈត្តករ ហើយបានជាលទ្ធផលនៅថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១១ នៅសល់តែបេក្ខជនចំនួន ៤៨រូបប៉ុណ្ណោះ ដែលបានប្រលងជាប់ជាស្ថាពរនឹងក្លាយជាមជ្ឈត្តករនៅមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម។[51] ក្នុង

[48] បទបញ្ជាសម្រាប់ការប្រឡងបញ្ចប់វគ្គបណ្តុះបណ្តាលមជ្ឈត្តការផ្នែកពាណិជ្ជកម្មលេខ ៨៥៩ ព.ណ នគក ចុះថ្ងៃទី១១ ខែមិនា ឆ្នាំ២០១១ (ឧបសម្ព័ន្ធទី៧)

[49] បញ្ជីឈ្មោះប្រឡងដែលទទួលបានជោគជ័យក្នុងការប្រឡងបញ្ចប់វគ្គបណ្តុះបណ្តាលមជ្ឈត្តការផ្នែកពាណិជ្ជកម្មលើកទី១ លើមុខជំនាញច្បាប់ពាណិជ្ជកម្មលេខ ២៧២៣ ព.ណ មគក ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១១ (ឧបសម្ព័ន្ធទី៧)

[50] បញ្ជីឈ្មោះប្រឡងដែលទទួលបានជោគជ័យក្នុងការប្រឡងបញ្ចប់វគ្គបណ្តុះបណ្តាលមជ្ឈត្តការផ្នែកពាណិជ្ជកម្មលើកទី១ លើមុខជំនាញ មជ្ឈត្តការផ្នែកពាណិជ្ជកម្មលេខ ២៧២២ ព.ណ មគក ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១១ (ឧបសម្ព័ន្ធទី៧)

[51] http://www.moc.gov.kh/pdf/pdfnews/2013_03_04_00.pdf

ចំណោមបេក្ខជន ៥៨រូបដែលបានក្លាយជាមជ្ឈត្តករ មានបេក្ខជនចំនួន ២៨រូបគឺជាមេធាវី និង បេក្ខជនផ្សេងទៀតមកពីវិស័យផ្សេងៗ។[52]

### ២.៣. សាខារបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម

ដើម្បីផ្តល់នូវភាពងាយស្រួល និង ភាពឆាប់រហ័សដល់ដំណើរការដោះស្រាយវិវាទផ្នែកពាណិជ្ជកម្ម មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម អាចបង្កើតនូវសាខារបស់ខ្លួនបានទៅតាមបណ្តាលខេត្តនានានៅព្រះរាជាណាចក្រកម្ពុជាបាន។ ទន្ទឹមនឹងការបង្កើតនេះ **ម.ជ.ម** ក៏ត្រូវចេញនូវសេចក្តីសម្រេចរបស់ខ្លួនក្នុងការកំណត់ពីការរៀបចំ និងការប្រព្រឹត្តទៅរបស់សាខានីមួយៗរបស់ខ្លួនផងដែរ។[53]

ដោយសារនៅកម្ពុជាមជ្ឈត្តការទើបតែបង្កើតឡើង ដូច្នេះសាខានៃ **ម.ជ.ម** មិនទាន់ត្រូវបានបង្កើតឡើងនោះទេ។ តែទោះជាយ៉ាងនេះក្តី នៅបណ្តាលប្រទេសមួយចំនួនដូចជាសង្ហ៊ីបុរី និងហុងកុង ដែលជាប្រទេសបានបង្កើតឡើងនូវមជ្ឈត្តការយូរហើយនោះ និងមានការរីកចំរើននូវផ្នែកនេះក៏ពុំទាន់ឃើញមានបង្កើតនូវសាខាសំរាប់មជ្ឈត្តការនៅឡើយទេ។ ដោយឡែកនៅសហរដ្ឋអាមេរិចវិញ ដោយសារតែមជ្ឈត្តការជាយន្តការដែលត្រូវបានពាណិជ្ជករប្រើប្រាស់ច្រើន ហើយជារដ្ឋមួយដែលមានផ្ទៃដីធំ ដូចនេះមជ្ឈត្តការនៅសហរដ្ឋអាមេរិចបានបង្កើតសាខារបស់ខ្លួននៅគ្រប់ទីក្រុងរបស់ខ្លួន ដែលធ្វើឲ្យភាគីវិវាទមានភាពងាយស្រួលក្នុងការជ្រើសរើសសាខាណាមួយ ដែលមានភាពងាយស្រួលសំរាប់ភាគីទាំងពីរដោះស្រាយវិវាទ។[54]

## ផ្នែកទី ៣ ប្រភពធនធាន

មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្មមានប្រភពធនធានសំខាន់ៗចំនួន ៣ គឺបានមកពីភាគទានរបស់សមាជិកខ្លួន អំណោយ និងវិភាគទានផ្សេងៗ និងកម្រៃសេវាផ្នែករដ្ឋបាលរបស់ខ្លួន។[55]

ភាគទានរបស់សមាជិក គឺបានមកពីការបង់ភាគទានជាសមាជិកប្រចាំឆ្នាំ ដើម្បីសុំបន្តសមាជិកភាពរបស់ខ្លួនតាមការកំណត់របស់មហាសន្និបាត។ ប៉ុន្តែក្នុងករណីដែលត្រូវការមូលនិធិ

[52] http://www.cambodiadaily.com/archives/arbitration-center-elects-board-members-8188/

[53] មាត្រា ៤១ នៃអនុក្រឹត្យស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម (ឧបសម្ព័ន្ធទី១)

[54] https://www.adr.org/aaa/faces/s/contact/us?_afrLoop=1571677032300980&_afrWindowMode=0&_afrWindowId=a29lt9ry3_319#%40%3F_afrWindowId%3Da29lt9ry3_319%26_afrLoop%3D1571677032300980%26_afrWindowMode%3D0%26_adf.ctrl-state%3Da29lt9ry3_355

[55] មាត្រា ៤២ នៃអនុក្រឹត្យស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម (ឧបសម្ព័ន្ធទី១)

បន្ថែមដែលតម្រូវដោយ**ម.ជ.ម** នោះ**ម.ជ.ម** អាចធ្វើការប្រមូលពីសមាជិករបស់ខ្លួនបន្ថែមបាន ដែលនេះតម្រូវឲ្យមានការយល់ព្រមពីមហាសន្និបាត ដែលត្រូវមានសំលេងលើសពី ៥០%នៃសមាជិកវត្តមានក្នុងមហាសន្និបាតយល់ព្រម។[56] ក្រោយពីបានសម្រេចដោយមហាសន្និបាតលើកទី ១ ភាគទានរបស់សមាជិក **ម.ជ.ម** ត្រូវបានចែកជាបួនធំគឺភាគទានរបស់មជ្ឈត្តករ ភាគទានរបស់សមាជិកជានីតិបុគ្គល ភាគទានសមាជិកគាំទ្រជារូបវន្តបុគ្គល និងភាគទានសមាជិកគាំទ្រជានីតិបុគ្គល។[57] ការបង់សមាជិកភាពនេះ គឺត្រូវបង់ក្នុងរយៈពេល១ឆ្នាំម្តងដែលត្រូវចាប់ផ្តើមពីខែសីហា ឆ្នាំ២០១៤ ហើយភាគទានសម្រាប់នីតិបុគ្គលគឺ ៥០០ដុល្លាក្នុង១ឆ្នាំ ភាគទានសម្រាប់មជ្ឈត្តករគឺ ២៥០ដុល្លាក្នុង១ឆ្នាំ ភាគទានសម្រាប់សមាជិកគាំទ្រជារូបបវន្តបុគ្គលគឺ ១០០ដុល្លាក្នុង១ឆ្នាំ និងភាគទានសម្រាប់សមា ជិកគាំទ្រជានីតិបុគ្គលគឺ ៣០០ដុល្លាក្នុង១ឆ្នាំ។[58]

មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្មក៏អាចទទួលអំណោយ ឬជំនួយផ្សេងៗពីស្ថាប័ន ឬអង្គភាពនានា ដើម្បីឧបត្ថម្ភ និងគាំទ្រដល់ **ម.ជ.ម** ឲ្យដំណើរការបានឆាប់រហ័ស និងមានភាពរលូនផងដែរ។ ជាក់ស្តែងនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៩ សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC) បានចុះហត្ថលេខាលើអនុស្សារណៈយោគយល់គ្នាជាមួយក្រសួងពាណិជ្ជកម្ម សំរាប់រយៈពេល៣ឆ្នាំ ក្នុងការបង្កើតមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ដែលមានកិច្ចសហប្រតិបត្តិការជាមួយធនាគារអភិវឌ្ឍន៍អាស៊ី (ADB) និងដៃគូអភិវឌ្ឍន៍អន្តរជាតិផ្សេងៗ ទៀតរួមទាំងផ្តល់ការប្រឹក្សាយោបល់ដល់គណៈកម្មការរៀបចំ និងជ្រើសរើសមជ្ឈត្តករដំបូង និងការបណ្តុះបណ្តាលមជ្ឈត្តករដំបូងផងដែរ។[59]

ទន្ទឹមនឹងការទទួលបានប្រាក់ចំនូលពីការបង់ភាគទាន និងទទួលជំនួយផ្សេងៗ **ម.ជ.ម** ក៏ទទួលបានកម្រៃសេវាផងដែលពីផ្នែករដ្ឋបាលរបស់ខ្លួន ដែលបានមកពីការបង់ពន្ធក្នុងការដាក់ពាក្យបណ្តឹង និងឯកសារនានាពីភាគីមានជម្លោះដើម្បីជាកម្រៃសេវាក្នុងការដោះស្រាយវិវាទ។ កម្រៃសេវានេះរួមមាន កម្រៃសេវាចុះបញ្ជី កម្រៃសេវារដ្ឋបាល កម្រៃសេវាតែងតាំងមជ្ឈត្តករ កម្រៃសេវាវេទិកាមជ្ឈត្តការ និងកម្រៃផ្សេងៗទៀត។[60]

---

[56] មាត្រា ៤៣ កថាខណ្ឌទី៤ នៃអនុក្រឹត្យស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម (ឧបសម្ព័ន្ធទី១)

[57] ប្រការ ១៧ នៃបទបញ្ជាផ្ទៃក្នុងរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម (ឧបសម្ព័ន្ធទី៣)

[58] ចំណុចទី៣ នៃសំណើថវិការបស់មជ្ឈមណ្ឌលមជ្ឈត្តការផ្នែកពាណិជ្ជកម្មសំរាប់រយៈពេលពីខែតុលា ឆ្នាំ២០១៤ ដល់ខែមិនា ឆ្នាំ២០១៦ (ឧបសម្ព័ន្ធទី៥)

[59] http://www.moc.gov.kh/pdf/pdfnews/2009%2008%2010th,%20Signing%20Ceremony%20of%20MOU%20Between%20MoC%20&%20IFC.pdf

[60] វិធាន ៤១ នៃវិធានស្តីពីមជ្ឈត្តការរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម (ឧបសម្ព័ន្ធទី២)

# ជំពូកទី ២

# នីតិវិធីដោះស្រាយវិវាទពាណិជ្ជកម្មក្រៅប្រព័ន្ធតុលាការនៅកម្ពុជា

នៅកម្ពុជាការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការត្រូវបានធ្វើឡើង និងមានទទួលស្គាល់ក៏ដូចជាការជម្រុញឲ្យមានការដោះស្រាយនេះឡើងដែរ។ ជាទូទៅការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនេះត្រូវបានប្រើប្រាស់ច្រើននៅក្នុងវិវាទពាណិជ្ជកម្ម។

## ១. គោលការណ៍ទូទៅនៃការដោះស្រាយវិវាទក្រៅប្រពន្ធ័តុលាការ

ដើម្បីដោះស្រាយវិវាទដែលកើតមានឡើងនៅក្នុងរឿងពាណិជ្ជកម្ម ភាគីមិនមែនសុទ្ធតែពឹងផ្អែកទៅលើតុលាការទាំងស្រុងនោះទេ គឺគេអាចធ្វើការដោះស្រាយតាមរយៈក្រៅប្រព័ន្ធតុលាការបាន។ ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលារការ មានច្រើនទម្រង់សំរាប់យកមកដោះស្រាយវិវាទដូចជាការចរចា សន្ទានកម្ម ឬការផ្សះផ្សា និងមជ្ឈត្តកម្ម។ ការដោះស្រាយតាមវិធីទាំងអស់នេះសុទ្ធតែជាមូលដ្ឋានគ្រឹះនៃការដោះស្រាយវិវាទពាណិជ្ជកម្មក្រៅប្រព័ន្ធតុលាការ។ មុននឹងឈានដល់ការដោះស្រាយតាមរយៈមជ្ឈត្តកម្ម ជាទូទៅភាគីវិវាទតែងតែជ្រើសរើសយកការចរចា ឬសន្ទានកម្មយកមកធ្វើយន្តការក្នុងការដោះស្រាយវិវាទជាមុនសិន ព្រោះថាការចចារ ឬសន្ទានកម្មមានលក្ខណៈងាយស្រួលចំណាយតិច និងចំនេញពេលវេលា ព្រមទាំងក្នុងគោលបំណងរក្សាទំនាក់ទំនងរបស់ភាគីទាំងពីរ។ ទោះជាយ៉ាងនេះក្តី មជ្ឈត្តកម្មនៅតែត្រូវការយកមកធ្វើជាយន្តការក្នុងការដោះស្រាយវិវាទ ព្រោះការចចារ ឬសន្ទារកម្ម មិនមានលក្ខណៈចាប់បង្ខំដល់ភាគីវិវាទទេទោះបីជាភាគីទាំងពីរបានព្រមព្រៀងគ្នាហើយក៏ដោយ។ ផ្ទុយទៅវិញយន្តការមជ្ឈត្តកម្ម គឺមានលក្ខណៈចាប់បង្ខំទៅដល់ភាគីដែលមិនព្រមគោរព និងអនុវត្តតាមសេចក្តីសម្រេចរបស់មជ្ឈត្តការគឺមជ្ឈត្តវិនិច្ឆ័យ។

### ១.១. ការចរចា

ការចរចា ជានីតិវិធីមួយដែលមានលក្ខណៈងាយស្រួល និងសាមញ្ញដែលត្រូវបានប្រើប្រាស់ជារៀងរាល់ថ្ងៃក្នុងជីវភាពរស់នៅ និងក្នុងការដោះស្រាយវិវាទផ្សេងៗផងដែរ ទោះបីនៅក្នុងប្រព័ន្ធច្បាប់ស៊ីវិល (Civil Law) ឬប្រព័ន្ធច្បាប់អង់គ្លេស (Common Law)។ ការចរចាត្រូវបានគេឲ្យនិយមន័យថា ជាដំណើរការនៃការឆ្លើយឆ្លងគ្នាទៅវិញទៅមក ដែលភាគីទាំងអស់ដាក់ជាសំណើរ ឬពិចារណាលើសំណើរផ្សេងៗ រហូតដល់សំណើរណាមួយត្រូវបានធ្វើឡើងហើយត្រូវបានគេទទួល

យក។[61] ការចរចាអាចធ្វើឡើងដោយផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរ ហើយវាជួយដល់ការដោះស្រាយវិវាទធំ និងតូចជាច្រើន។ ការចរចាធ្វើអាចធ្វើឡើងដោយផ្ទាល់រវាងភាគីវិវាទ ឬតាមរយៈតំណាងពួកគេ។ ការចរចាអាចធ្វើឡើងជាច្រើនរបៀបដូចជា ការចរចាដោយផ្ទាល់ ការចរចាតាមរយៈទូរស័ព្ទ ឬការចរចាតាមរយៈសំបុត្រ ឬអ៊ីម៉ែលជាដើម។[62] ការដោះស្រាយវិវាទតាមរយៈការចរចានេះ អាចជួយឲ្យភាគីវិវាទមិនចាំបាច់ចំនាយថវិកាច្រើន រក្សាបាននូវទំនាក់ទំនងរវាងភាគីមានការសម្ងាត់ និងការជ្រើសរើសដំណោះស្រាយជាការព្រមព្រៀងគ្នារបស់ភាគី ដែលធ្វើឲ្យមានភាពងាយស្រួលក្នុងការអនុវត្ត។ ភាគីវិវាទតែងតែធ្វើការចរចាឲ្យអស់នូវលទ្ធភាពជាមុនសិន មុននឹងឈានដល់មជ្ឈត្តការ។

### ១.២. មជ្ឈត្តកម្ម

មជ្ឈត្តកម្ម គឺជាយន្តការមួយសំរាប់ធ្វើការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ដែលភាគីនៃវិវាទដាក់បញ្ហាវិវាទរបស់ខ្លួន ដោយស្ម័គ្រចិត្តទៅបុគ្គលអព្យាក្រឹត្យម្នាក់ ឬមួយក្រុម ដើម្បីធ្វើការពិចារណាទៅលើភស្តុតាងដែលបានដាក់ជូន និងការអះអាង ហើយចេញនូវសេចក្តីសម្រេចចុងក្រោយមួយ ដែលមានលក្ខណៈចាប់បង្ខំឲ្យភាគីអនុវត្តតាម ហៅថាសេចក្តីសម្រេចមជ្ឈត្តការ ឬមជ្ឈត្តវិនិច្ឆ័យ។ ជាទូទៅវិវាទពាណិជ្ជកម្មភាគច្រើន គឺជ្រើសរើសយកយន្តការនេះដើម្បីធ្វើការដោះស្រាយវិវាទ ព្រោះវាមានភាពឆាប់រហ័ស សន្សំសំចៃ សម្ងាត់ និងទទួលស្គាល់ជាអន្តរជាតិផងដែរ។ នៅក្នុងដំណើរការមជ្ឈត្តការ ភាគីវិវាទជាអ្នកមានសិទ្ធិក្នុងការជ្រើសរើសនីតិវិធីសម្រាប់ដោះស្រាយមជ្ឈត្តករ ច្បាប់ដែលត្រូវយកមកអនុវត្ត ដោយការព្រមព្រៀងគ្នារវាងភាគីទាំងពីរ។

## ២. កិច្ចព្រមព្រៀងមជ្ឈត្តកម្ម

### ២.១. គោលការណ៍ទូទៅនៃកិច្ចព្រមព្រៀងមជ្ឈត្តកម្ម

នៅពេលដែលបុគ្គលនៃកិច្ចព្រមព្រៀងមជ្ឈត្តការបានព្រមព្រៀងគ្នា ធ្វើការដោះស្រាយវិវាទរបស់ខ្លួនដោយមជ្ឈត្តការ នោះមានន័យថាភាគីទាំងពីរបានព្រមព្រៀងគ្នាជ្រើសយកមជ្ឈត្តការជាយន្តការក្នុងការដោះស្រាយវិវាទរបស់ពួកគេ និងបានបោះបង់សិទ្ធិក្នុងការប្តឹងរបស់ខ្លួនទៅស្ថាប័នតុលាការ។[63] ប៉ុន្តែភាគីនៅតែអាចប្តឹងទៅតុលាការបាន ប្រសិនបើភាគីទាំងពីរព្រមព្រៀងគ្នាមិនប្តឹង

[61] សៀវភៅដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ (មេធាវី ស៊ីវិន អ៊ែម អូស្ទើរមីឡឺរ) បោះពុម្ពលើកទី២ ទំព័រទី១៣

[62] សៀវភៅការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ របស់ក្រសួងពាណិជ្ជកម្ម និងធនាគារអភិវឌ្ឍន៍អាស៊ី ទំព័រទី១៣ និង១៤

[63] មាត្រា ៨ នៃច្បាប់ស្តីពី មជ្ឈត្តការផ្នែកពាណិជ្ជកម្ម

ទៅស្ថាប័នមជ្ឈត្តការ ឬកិច្ចព្រមព្រៀងនោះត្រូវបានទុកជាមោឃៈ ឬកម្មវត្ថុនៃវិវាទមិនបានចែងនៅក្នុងកិច្ចព្រមព្រៀងមជ្ឈត្តការ។

ឧទាហរណ៍: ភាគីទាំងពីរបានព្រមព្រៀងគ្នាក្នុងកិច្ចព្រមព្រៀងមជ្ឈត្តការថា រាល់វិវាទដែលកើតឡើងក្នុងការដឹកជញ្ជូនទំនិញត្រូវធ្វើការដោះស្រាយតាមមជ្ឈត្តការ។ តែវិវាទដែលកើតឡើងរវាងភាគីទាំងពីរគឺលើគុណភាពនៃទំនិញ ដែលជាវិវាទមិនបានចែងជាកម្មវត្ថុនៃកិច្ចព្រមព្រៀងមជ្ឈត្តការនោះភាគីណាមួយអាចធ្វើការប្ដឹងទៅតុលាការមានសមត្ថកិច្ចបាន។

### ២.២. លក្ខខណ្ឌសុពលភាព

កិច្ចព្រមព្រៀងមជ្ឈត្តការ ដែលមានលក្ខណៈសុពលភាពបានលុះត្រាតែកិច្ចព្រមព្រៀងនោះត្រូវបានបំពេញតាមលក្ខខណ្ឌមួយចំនួន ក្នុងរួមមានដូចជា ការព្រមព្រៀង ការធ្វើឡើងជាលាយលក្ខណអក្សរ សមត្ថភាពរបស់ភាគី ទំនាក់ទំនងគតិតយុត្តិ និងកម្មវត្ថុនៃវិវាទ។[64]

#### ២.២.១. ការព្រមព្រៀង

នៅក្នុងបញ្ញត្តិនៃច្បាប់ភាគីនៃកិច្ចសន្យា ឬកិច្ចព្រមព្រៀងត្រូវបានផ្ដល់ឲ្យនូវសេរីភាពនៃឆន្ទៈ និងការព្រមព្រៀងគ្នាក្នុងការធ្វើកិច្ចព្រមព្រៀង។[65] ដោយឡែកនៅក្នុងច្បាប់ស្ដីពី មជ្ឈត្តការផ្នែកពាណិជ្ជកម្មវិញ កិច្ចព្រមព្រៀងក៏តម្រូវឲ្យមានការព្រមព្រៀងផងដែររវាងគូភាគីនៃកិច្ចព្រមព្រៀង។[66] ការព្រមព្រៀងក្នុងន័យនេះ មានន័យថាកិច្ចព្រមព្រៀងមជ្ឈត្តការត្រូវបានបង្កើតឡើងដោយគ្មានការបង្ខិតបង្ខំ ការភ័ន្តច្រឡំ ការឆបោក ការគម្រាមកំហែង និងការគេងចំនេញហួសហេតុពីភាគីណាមួយ ពោលគឺកិច្ចព្រមព្រៀងនេះបង្កើតឡើងដោយគ្មានវិការៈ។[67]

#### ២.២.២. ការធ្វើឡើងជាលាយលក្ខណអក្សរ

នៅកម្ពុជា កិច្ចព្រមព្រៀងមជ្ឈត្តការ គឺតម្រូវឲ្យធ្វើឡើងជាលាយលក្ខណអក្សរ។[68] ការធ្វើឡើងជាលាយលក្ខណអក្សរនេះសំដៅទៅលើ "កិច្ចព្រមព្រៀងដែលស្ថិតនៅក្នុងឯកសារចុះហត្ថលេខាដោយភាគីវិវាទ ឬដែលស្ថិតនៅក្នុងការផ្ញើរលិខិតស្នាម ឬមធ្យោបាយទូរគមនាគមន៍តាមប្រព័ន្ធអេឡិចត្រូនិចដែលផ្ដល់កំណត់ត្រាបញ្ជាក់ពីការព្រមព្រៀងគ្នា ឬដែលស្ថិតនៅក្នុងការប្ដូរគ្នាទៅវិញទៅមកនូវពាក្យទាមទារ

[64] មាត្រា ២ នៃអនុសញ្ញាទីក្រុងញូវយ៉កស្ដីពី ការទទួលស្គាល់ និងការប្រតិបត្តិសេចក្ដីសម្រេចមជ្ឈត្តករបរទេស (ឧបសម្ព័ន្ធទី៦)
[65] មាត្រា ៣ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧ និងមាត្រា ៣ នៃក្រឹត្យច្បាប់លេខ៣៨ ស្ដីពី កិច្ចសន្យា និងការទទួលខុសត្រូវក្រៅកិច្ចសន្យា
[66] មាត្រា ៧ កថាខណ្ឌទី២ នៃច្បាប់ស្ដីពី មជ្ឈត្តការផ្នែកពាណិជ្ជកម្ម
[67] មាត្រា ៣៤៥ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧
[68] មាត្រា ៧ កថាខណ្ឌទី២ នៃច្បាប់ស្ដីពី មជ្ឈត្តការផ្នែកពាណិជ្ជកម្ម

ឬពាក្យដោះសារ ដែលក្នុងនោះភាគីវិវាទមួយបានទាមទារហើយមិនត្រូវបានបដិសេធដោយភាគីវិវាទម្ខាងទៀត”[69] ជារួមគឺរាល់ឯកសារដែលភាគីទាំងពីរបានព្រមព្រៀងគ្នា និងបានចុះហត្ថលេខាលើលិខិតនោះ។ ម្យ៉ាងទៀតដើម្បីឲ្យកាន់តែមានភាពច្បាស់លាស់ និងមានសុពលភាព ភាគីនៃវិវាទគួរតែកំណត់ឲ្យបានច្បាស់អំពីសិទ្ធិ និងការរៀបចំនូវដំណើរការរបស់មជ្ឈត្តការដូចជា កំណត់អំពីទីកន្លែង ភាសា ចំនួនមជ្ឈត្តករ ច្បាប់ដែលត្រូវយកមកអនុវត្ត និងនីតិវិធីជាដើម។

នៅក្នុងអនុសញ្ញាទីក្រុងញូវយ៉ក គឺជម្រុញឲ្យភាគីវិវាទគួរតែធ្វើការព្រមព្រៀងគ្នាជាលាយលក្ខណអក្សរ ដោយបានកំណត់ថា រដ្ឋជាសមាជិកនៃអនុសញ្ញានេះ ត្រូវទទួលស្គាល់កិច្ចព្រមព្រៀងដែលធ្វើឡើងជាលាយលក្ខអក្សរ។[70]

### ២.២.៣. សមត្ថភាពរបស់ភាគី

បុគ្គលដែលអាចចុះកិច្ចសន្យាបាន ហើយកិច្ចសន្យានោះមានសុពលភាព លុះត្រាតែបុគ្គលនោះមានសមត្ថភាពគតិយុត្តិទៅតាមច្បាប់បានកំណត់។ បុគ្គលទាំងឡាយណាដែលក្រមរដ្ឋប្បវេណីបានកំរិតនូវសមត្ថភាពរបស់បុគ្គលនោះដូចជាអនីតិជន ជននៅក្រមអាណាព្យាបាលទូទៅ និងហិតូបត្ថម្ភកៈ គឺជាបុគ្គលដែលគ្មានសមត្ថភាពគ្រប់គ្រាន់ក្នុងការចុះកិច្ចសន្យា។[71] ដូច្នេះក្រៅពីបុគ្គលដែលក្រមរដ្ឋប្បវេណីបានកំណត់ដូចមានរៀបរាប់ខាងលើ ត្រូវបានចាត់ទុកថាជាបុគ្គលដែលមានសមត្ថភាពគ្រប់គ្រាន់ដែលអាចចុះកិច្ចសន្យា ឬកិច្ចព្រមព្រៀងបាន។

### ២.២.៤. ទំនាក់ទំនងគតិយុត្តិ

ទោះបីជាយ៉ាងណាក៏ដោយដើម្បីឲ្យកិច្ចព្រមព្រៀងមជ្ឈត្តការនេះមានសុពលភាព គឺទាមទារឲ្យមាននូវទំនាក់ទំនងគតិយុត្តិដែលពុំអាចខ្វះបានឡើយនៅក្នុងវិស័យពាណិជ្ជកម្មអន្តរជាតិ។[72] នៅក្នុងន័យនេះទំនាក់ទំនងគតិយុត្តិ សំដៅដល់ទំនាក់ទំនងតាមផ្លូវច្បាប់រវាងភាគីទាំងពីរក្នុងការបង្កើតនូវកិច្ចសន្យា។ ការកើតឡើងនូវបញ្ហាទំនាក់ទំនងគតិយុត្តនេះ ច្រើនកើតទៅលើអ្នកដែលតំណាងឲ្យភាគីណាមួយមិនបានតែងតាំងឡើងដោយពិប្រាកដពីភាគីនោះ។

ឧទាហរណ៍: ក្នុងករណីដែលភាគីមួយ (ក) បានអះអាងថាខ្លួនជាតំណាងឲ្យភាគី (ខ) ក្នុងការចុះកិច្ចសន្យាជាមួយភាគី (គ) នោះអ្នកតំណាង (ក) គឺត្រូវតែបានតែងតាំង ឬចាត់តាំងពិត

---

[69] មាត្រា ៧ កថាខណ្ឌទី២ នៃច្បាប់ស្តីពី មជ្ឈត្តការផ្នែកពាណិជ្ជកម្ម

[70] មាត្រា ២ កថាខណ្ឌទី១ នៃអនុសញ្ញាទីក្រុងញូវយកស្តីពី ការទទួលស្គាល់ និងការប្រតិបត្តិសេចក្តីសម្រេចមជ្ឈត្តករបរទេស(ឧបសម្ព័ន្ធទី៦)

[71] មាត្រា ១៦ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧

[72] មាត្រា ២ នៃអនុសញ្ញាទីក្រុងញូវយ៉កស្តីពី ការទទួលស្គាល់ និងការប្រតិបត្តិសេចក្តីសម្រេចមជ្ឈត្តករបរទេស (ឧបសម្ព័ន្ធទី៦) និង មាត្រា ៧ (ជម្រើសទី២) នៃ UNICITRAL Model Law

ប្រាកដពីភាគី (ខ) ក្នុងការចុះកិច្ចសន្យាកិច្ចសន្យានេះ។ បើមិនដូច្នេះទេកិច្ចសន្យាដែលភាគី (គ) បានចុះជាមួយភាគី (ក) ដែលមិនបានចាត់តាំងដោយភាគីម្ខាងទៀត (ខ) គឺពុំបង្កើតនូវទំនាក់ទំនងគតិយុត្តិជារវាងភាគី (ខ) និង (គ) ទេ។

### ២.២.៥. កម្មវត្ថុនៃវិវាទ

ថ្វីត្បិតតែភាគីមានសេរីភាពក្នុងការជ្រើសរើសយកយន្តការមជ្ឈត្តការ មកធ្វើការដោះស្រាយវិវាទរបស់ខ្លួនក៏ពិតមែន ប៉ុន្តែដោយអនុលោមតាមបទបញ្ញត្តិនៃច្បាប់ស្តីពី មជ្ឈត្តការផ្នែកពាណិជ្ជកម្ម គឺបានកំរិតត្រឹមការដោះស្រាយវិវាទផ្នែកពាណិជ្ជកម្មតែប៉ុណ្ណោះ។[73] បានន័យថាកម្មវត្ថុដែលអាចធ្វើឲ្យកិច្ចព្រមព្រៀងមានសុពលភាពចំពោះមជ្ឈត្តការ លុះត្រាតែកម្មវត្ថុនៃវិវាទនោះជារឿងពាណិជ្ជកម្ម ដែលមិនប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ និងជាកម្មវត្ថុស្របច្បាប់។

ឧទាហរណ៍: នៅក្នុងកិច្ចព្រមព្រៀងមជ្ឈត្តការ ភាគីបានកំណត់ថារាល់វិវាទដែលកើតឡើងរវាងនិយោជក និងនិយោជិតត្រូវធ្វើការដោះស្រាយតាមរយៈមជ្ឈត្តការផ្នែកពាណិជ្ជកម្ម។ ក្នុងករណីនេះកម្មវត្ថុនៃវិវាទមិនមែនជាកម្មវត្ថុនៃពាណិជ្ជកម្មទេ គឺជាពាក់ព័ន្ធនឹងទំនាក់ទំនងការងារ។ ដូច្នេះកិច្ចព្រមព្រៀងនេះមិនមានសុពលភាពចំពោះមជ្ឈត្តការផ្នែកពាណិជ្ជកម្មទេ។

## ៣. នីតិវិធីនៃមជ្ឈត្តកម្ម

### ៣.១. ការជ្រើសរើសស្ថាប័នមជ្ឈត្តការ

ការជ្រើសរើសយន្តការមជ្ឈត្តការ មកធ្វើការដោះស្រាយវិវាទពាណិជ្ជកម្មអាចធ្វើឡើងតាម២របៀបគឺ ការព្រមព្រៀងគ្នាទៅស្ថាប័នមជ្ឈត្តការតាមកិច្ចព្រមព្រៀងមជ្ឈត្តការ និងការព្រមព្រៀងគ្នាទៅស្ថាប័នមជ្ឈត្តការក្រោយពេលមានវិវាទកើតឡើង។

### ៣.១.១. ការជ្រើសរើសស្ថាប័នមជ្ឈត្តកម្មតាមកិច្ចព្រមព្រៀងមជ្ឈត្តការ

#### ក. ការព្រមព្រៀងគ្នាទៅស្ថាប័នមជ្ឈត្តកម្មតាមកិច្ចសន្យា

នៅពេលដែលភាគីទាំងពីរបានព្រមព្រៀងគ្នានៅក្នុងកិច្ចព្រមព្រៀងមជ្ឈត្តការ ពេលដែលមានវិវាទកើតឡើង វិវាទនោះគឺត្រូវតែធ្វើការដោះស្រាយតាមរយៈមជ្ឈត្តការ លើកលែងតែភាគីទាំងពីរធ្វើការព្រមព្រៀងគ្នាផ្សេងពីនេះ មានន័យថានៅពេលមានវិវាទភាគីណាមួយនៃកិច្ចព្រមព្រៀងមជ្ឈត្តការអាចធ្វើការប្តឹងទៅមជ្ឈត្តការបាន ដោយសំអាងទៅលើកិច្ចព្រមព្រៀងមជ្ឈត្តការនោះ។

[73] មាត្រា ១ នៃច្បាប់ស្តីពី មជ្ឈត្តការផ្នែកពាណិជ្ជកម្ម

**ខ. ការបង្គាប់របស់តុលាការឲ្យទៅស្ថាប័នមជ្ឈត្តកម្ម**

ទោះបីជាដូចបានរៀបរាប់ខាងលើក្តី ភាគីណាមួយក៏នូវតែមានសិទ្ធិប្តឹងទៅតុលាការបាន។ ប៉ុន្តែនៅពេលវិវាទដែលបានដាក់ទៅតុលាការជាកម្មវត្ថុនៃកិច្ចព្រមព្រៀងមជ្ឈត្តការ តុលាការត្រូវបញ្ជូនភាគីវិវាទនោះទៅមជ្ឈត្តការវិញ នៅពេលដែលមានការស្នើពីភាគីវិវាទម្ខាងទៀត លើកលែងតែតុលាការរកឃើញថាកិច្ចព្រមព្រៀងមជ្ឈត្តការនោះត្រូវបានទុកជាមោឃៈ ដោយមិនបានបំពេញនូវលក្ខខណ្ឌសុពលភាព ឬមិនអាចអនុវត្តបាន។[74]

ជាទូទៅកិច្ចព្រមព្រៀងមជ្ឈត្តការត្រូវបានចែងនៅក្នុងកិច្ចសន្យារវាងភាគីទាំងពីរ។ ក្នុងករណីនេះ ទោះបីជាកិច្ចសន្យារវាងភាគីទាំងពីរត្រូវបានទុកជាមោឃៈក៏ដោយ ក៏វាមិននាំឲ្យបាត់បង់នូវសុពលភាពនៃខចែងពីកិច្ចព្រមព្រៀងមជ្ឈត្តការដែរ។

**៣.១.២.ការជ្រើសរើសស្ថាប័នមជ្ឈត្តកម្មតាមការព្រមព្រៀងក្រោយពេលមានវិវាទកើតឡើង**

នៅពេលដែលភាគីវិវាទមិនបានធ្វើការព្រមព្រៀងគ្នាជាមុន ឬបានធ្វើការព្រមព្រៀងគ្នាក្នុងការដោះស្រាយវិវាទតាមរយៈមជ្ឈត្តការក៏ដោយ តែការព្រមព្រៀងនោះមិនបានកំណត់ចំពោះបញ្ហាវិវាទដែលកើតឡើង ក៏ភាគីវិវាទអាចធ្វើការព្រមព្រៀងគ្នានៅពេលក្រោយបានដែរ។ ការព្រមព្រៀងគ្នាក្រោយពេលមានវិវាទកើតឡើងនេះ ភាគីវិវាទអាចព្រមព្រៀងគ្នាទៅមជ្ឈត្តការតែម្តង ឬធ្វើឡើងនូវកិច្ចព្រមព្រៀងមជ្ឈត្តការថ្មីមួយក្រោយពេលវិវាទដែលកំណត់ពីនីតិវិធី និងបញ្ហាវិវាទដែលមាននៅក្នុងកិច្ចព្រមព្រៀងនោះ។

ឧទាហរណ៍: ភាគីមានកិច្ចព្រមព្រៀងមជ្ឈត្តការដែលចែងថា រាល់វិវាទដែលមិនអាចធ្វើការដោះស្រាយបានទាក់ទងនឹងការដឹកជញ្ជូន ត្រូវយកទៅដោះស្រាយតាមរយៈមជ្ឈត្តការ។ ប៉ុន្តែនៅពេលដែលមានវិវាទកើតឡើង បញ្ហាវិវាទគឺទាក់ទងនឹងការប្រគល់ប្រាក់។ ដូចនេះប្រសិនភាគីវិវាទចង់ដោះស្រាយវិវាទនេះតាមរយៈមជ្ឈត្តការ ភាគីទាំងពីរអាចបង្កើតនូវកិច្ចព្រមព្រៀងមជ្ឈត្តការថ្មីមួយទៀត ដែលកំណត់លើការដោះស្រាយវិវាទទាក់ទងនឹងការប្រគល់ប្រាក់នោះ។

**៣.២. ដំណើរការនៃមជ្ឈត្តការ**

**៣.២.១. ការចាប់ផ្តើមមជ្ឈត្តកម្ម**

[74] មាត្រា ៨ កថាខណ្ឌទី ១ នៃច្បាប់ស្តីពី មជ្ឈត្តការផ្នែកពាណិជ្ជកម្ម

ក្រោយពេលមានវិវាទកើតឡើង ហើយវិវាទនោះត្រូវបានព្រមព្រៀងគ្នាធ្វើការដោះស្រាយតាមរយៈមជ្ឈត្តការ នៅពេលនោះភាគីណាមួយនៃវិវាទដែលមានបំណងចង់ដាក់វិវាទរបស់ខ្លួនឲ្យដោះស្រាយតាមរយៈមជ្ឈត្តការ ត្រូវធ្វើសេចក្តីជូនដំណឹងអំពីមជ្ឈត្តកម្មទៅអគ្គលេខាធិការដ្ឋានរបស់ **ម.ជ.ម**។ សេចក្តីជូនដំណឹងនេះត្រូវរៀបរាប់នូវពត៌មានមួយចំនួនដូចមានចែងនៅក្នុងវិធាន ៧.១ នៃវិធានស្តីពីមជ្ឈត្តការរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្មដែលមានដូចជាៈ សេចក្តីថ្លែងបញ្ជាក់ថាភាគីវិវាទដាក់ឲ្យដោះស្រាយតាមមជ្ឈត្តការ ឈ្មោះ អាស័យដ្ឋាន សញ្ជាតិរបស់ភាគីវិវាទ កិច្ចសន្យា កិច្ចព្រមព្រៀងមជ្ឈត្តការ សេចក្តីថ្លែងសង្ខេប ចំនួនមជ្ឈត្តករ និងការស្នើសុំផ្សេងៗ។ ក្នុងការទទួល សេចក្តីជូនដំណឹងនេះ អគ្គលេខាធិការដ្ឋានត្រូវពិនិត្យលើភាពពេញលេញនៃសេចក្តីជូនដំណឹង ហើយភាគីប្តឹងទាមទារត្រូវបង់កម្រៃសេវាចុះបញ្ជីចំនួន ២៥០ (ពីររយហាសិប) ដុល្លា[75] ដែលតម្រូវដោយ **ម.ជ.ម** ដើម្បីឲ្យសេចក្តីជូនដំណឹងនេះមានភាពពេញលេញ។ ក្នុងករណីដែលអគ្គលេខាធិការដ្ឋានពិនិត្យឃើញថាមានភាពមិនពេញលេញនៃសេចក្តីជូនដំណឹង ភាគីប្តឹងទាមទារត្រូវបំពេញបន្ថែមនូវចំណុចខ្វះខាត។ អគ្គលេខាធិការដ្ឋានត្រូវធ្វើការជូនដំណឹងទៅគូភាគីវិវាទវិញ នៅពេលដែលសេចក្តីជូនដំណឹងបានបំពេញភាពពេញលេញរួចរាល់។[76]

បន្ទាប់មកអគ្គលេខាធិការដ្ឋានត្រូវធ្វើការជូនដំណឹងទៅភាគីវិវាទម្ខាងទៀត ហើយភាគីនោះមានរយៈពេល ១៥ថ្ងៃក្នុងការធ្វើសេចក្តីជូនដំណឹងតបទៅអគ្គលេខាធិការដ្ឋានវិញ ដោយបំពេញនូវពត៌មានដូចគ្នាទៅនឹងការធ្វើសេចក្តីជូនដំណឹងអំពីមជ្ឈត្តការ។[77] ទោះបីជាភាគីឆ្លើយតបមិនបានឆ្លើយតបត្រឡប់មកវិញក៏ដោយ ក៏ដំណើរការមជ្ឈត្តការនៅតែដំណើរការដដែល ហើយដំណើរការមជ្ឈត្តការត្រូវបានចាប់ផ្តើម នៅពេលដែលភាគីឆ្លើយតបបានទទួលការជូនដំណឹងរបស់អគ្គលេខាធិការដ្ឋាន។[78]

### ៣.២.២. ការជ្រើសរើសមជ្ឈត្តករ

#### ក. ចំនួនមជ្ឈត្តករ

សេរីភាពក្នុងការកំណត់ចំនួនមជ្ឈត្តករដើម្បីធ្វើការដោះស្រាយវិវាទ គឺជាសិទ្ធិរបស់ភាគីវិវាទ តែទោះបីជាយ៉ាងនេះក្តី សេរីភាពនៅក្នុងការកំណត់នេះត្រូវបានកំរិតដោយច្បាប់ដែលអនុញ្ញាតឲ្យភាគីវិវាទកំណត់យកមជ្ឈត្តករត្រឹមតែចំនួនសេសប៉ុណ្ណោះ ដើម្បីធានាទទួលបាននូវ

[75] ចំណុច១.១ នៃតារាងតម្លៃសេវារបស់មជ្ឈត្តមណ្ឌលជាតិមជ្ឈត្តការផ្នែកពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា (ឧបសម្ព័ន្ធទី៤)
[76] វិធាន ៧ នៃវិធានស្តីពី មជ្ឈត្តការរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម (ឧបសម្ព័ន្ធទី២)
[77] វិធាន ៨ នៃវិធានស្តីពី មជ្ឈត្តការរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម (ឧបសម្ព័ន្ធទី២)
[78] វិធាន ៧.៧ នៃវិធានស្តីពី មជ្ឈត្តការរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម (ឧបសម្ព័ន្ធទី២)

ដំណោះស្រាយចុងក្រោយចំពោះវិវាទ។ ក្នុងករណីដែលភាគីវិវាទមិនបានកំណត់ចំនួននៃមជ្ឈត្តករទេនោះ មជ្ឈត្តករត្រូវបានកំណត់ថាមានចំនួន ៣នាក់។[79] ដោយសារប្រទេសកម្ពុជាទើបតែបង្កើតឡើងនូវដំណើរការមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ដូច្នេះការកំណត់យកមជ្ឈត្តករចំនួន ៣នាក់គឺមានគុណសម្បត្តិច្រើនដល់ការដោះស្រាយវិវាទ ព្រោះថាមជ្ឈត្តការផ្នែកពាណិជ្ជកម្មសំរាប់កម្ពុជានូវមានភាពថ្មី និងមិនទាន់មានបទពិសោធន៍គ្រប់គ្រាន់ក្នុងការដោះស្រាយវិវាទ។

### ខ. ការតែងតាំងមជ្ឈត្តករ

នៅក្នុងការតែងតាំងមជ្ឈត្តករ ក៏មិនខុសពីការកំណត់ចំនួនមជ្ឈត្តករដែរ គឺវាជាសិទ្ធិសេរីភាពរបស់ភាគីវិវាទ ក្នុងការកំណត់លើនីតិវិធីយ៉ាងដូចម្តេចសំរាប់តែងតាំងមជ្ឈត្តករ។ ក្នុងករណីដែលភាគីវិវាទមិនបានព្រមព្រៀងគ្នាក្នុងការតែងតាំងមជ្ឈត្តករ ការតែងតាំងចំពោះមជ្ឈត្តករមានចំនួនតែម្នាក់ គឺភាគីទាំងពីរត្រូវព្រមព្រៀងគ្នាជ្រើសរើសមជ្ឈត្តករម្នាក់នោះក្នុងរយៈពេល ១៥ថ្ងៃ បន្ទាប់ពីបានទទួលការជូនដំណឹងអំពីភាពពេញលេញនៃសេចក្តីជូនដំណឹងឆ្លើយតប។ ប្រសិនបើភាគីមិនអាចតែងតាំងមជ្ឈត្តកររួមគ្នាបានក្នុងរយៈពេលកំណត់ខាងលើ ការតែងតាំងគឺជាសមត្ថកិច្ចរបស់គណៈ កម្មាធិការតែងតែងរបស់ **ម.ជ.ម**។[80]

ដោយឡែកចំពោះមជ្ឈត្តករតែមានចំនួន ៣នាក់វិញ ភាគីនីមួយៗត្រូវធ្វើការតែងតាំងមជ្ឈត្តករម្នាក់មួយ ហើយមជ្ឈត្តករទាំងពីរនោះត្រូវជ្រើសរើសមជ្ឈត្តករទីបីធ្វើជាប្រធានវេទិកាមជ្ឈត្តការ។ ដូចគ្នាដែរប្រសិនបើភាគីណាមួយមិនបានធ្វើការតែងតាំងមជ្ឈត្តករ ការតែងតាំងគឺជាសមត្ថកិច្ចរបស់គណៈកម្មាធិការតែងតែងរបស់**ម.ជ.ម**។[81] ក្នុងករណីមជ្ឈត្តករទាំងពីរមិនអាចធ្វើការព្រមព្រៀងគ្នាជ្រើសរើសមជ្ឈត្តករទី៣បានក្នុងរយៈពេល ៣០ថ្ងៃ ភាគីម្ខាងទៀត ឬភាគីណាមួយនៃវិវាទអាចធ្វើសំណូមពរទៅតុលាការ ឬ **ម.ជ.ម** ឲ្យចាត់វិធានការលើបញ្ហានេះបាន ហើយការសម្រេចរបស់តុលាការ ឬ **ម.ជ.ម** ជាសេចក្តីសម្រេចចុងក្រោយដែលមិនអាចតវ៉ាបាន។

ក្នុងការតែងតាំងមជ្ឈត្តករ តុលាការ ឬ **ម.ជ.ម** ត្រូវពិចារណាលើលក្ខណៈសម្បត្តិរបស់មជ្ឈត្តករដែលមានចែងក្នុងកិច្ចព្រមព្រៀងរបស់ភាគីវិវាទ ដើម្បីធានាដល់ការជ្រើសតាំងមជ្ឈត្តករដែលឯករាជ្យ និងមិនលម្អៀង និងត្រូវពិនិត្យលើសញ្ជាតិរបស់មជ្ឈត្តករ និងសញ្ជាតិភាគីវិវាទ។[82]

[79] មាត្រា ១៨ នៃច្បាប់ស្តីពី មជ្ឈត្តការផ្នែកពាណិជ្ជកម្ម និងវិធាន ៩ នៃវិធានស្តីពី មជ្ឈត្តការរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម (ឧបសម្ព័ន្ធទី២)

[80] វិធាន ១០.៣ នៃវិធានស្តីពី មជ្ឈត្តការរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម (ឧបសម្ព័ន្ធទី២)

[81] វិធាន ១០.២ នៃវិធានស្តីពី មជ្ឈត្តការរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម (ឧបសម្ព័ន្ធទី២)

[82] មាត្រា ១៩ កថាខណ្ឌទី ៣ ៤ និង៥ នៃច្បាប់ស្តីពី មជ្ឈត្តការផ្នែកពាណិជ្ជកម្ម

គួរបញ្ជាក់ផងដែរពាល់ការតែងតាំងមជ្ឈត្តករ ដែលធ្វើឡើងដោយគណៈកម្មាធិការតែងតាំងរបស់ **ម.ជ.ម** ភាគីវិវាទត្រូវបង់កម្រៃសេវាចំនួន ៣០០ (បីរយ)ដុល្លា សម្រាប់ការតែងតាំងមជ្ឈត្តករម្នាក់។[83]

## គ. ការជំទាស់ក្នុងការតែងតាំងមជ្ឈត្តករ

ទោះបីជាយ៉ាងណាក្តី ភាគីវិវាទណាមួយអាចធ្វើការបដិសេធមជ្ឈត្តករបាន ដោយការប្តឹងជំទាស់ទៅនឹងមជ្ឈត្តករនោះ។ ការប្តឹងជំទាស់នឹងមជ្ឈត្តករអាចធ្វើទៅបាន លុះត្រាតែមានការសង្ស័យទៅលើភាពមិនលម្អៀង ឬភាពឯករាជ្យរបស់មជ្ឈត្តករនោះ ឬនៅពេលដែលមជ្ឈត្តករមិនមានលក្ខណៈសម្បត្តិដូចដែលភាគីបានព្រមព្រៀងគ្នា។ ការប្តឹងជំទាស់នេះផងដែរ គឺអាចធ្វើទៅបានតែក្នុងករណីដែលមូលហេតុនៃការជំទាស់ត្រូវបានដឹងក្រោយពេលជ្រើសតាំងរួចប៉ុណ្ណោះ មានន័យថាប្រសិនបើមជ្ឈត្តករនោះមិនទាន់បានជ្រើសតាំងជាមជ្ឈត្តករសំរាប់វេទិកាមជ្ឈត្តការទេ ភាពមិនលម្អៀង និងភាពឯករាជ្យរបស់មជ្ឈត្តករនោះមិនប៉ះពាល់វេទិកាមជ្ឈត្តការឡើយ។ ម្យ៉ាងទៀតមជ្ឈត្តករត្រូវគោរពនូវគោលការណ៍មិនលម្អៀង និងឯករាជ្យនៅក្នុងពេលដំណើរការវេទិកាមជ្ឈត្តការ។[84] ដូច្នេះមានតែមជ្ឈត្តករដែលបានជ្រើសតាំងរួចទើបអាចបញ្ជាក់បានថា មជ្ឈត្តករនោះមានភាពមិនលម្អៀង និងឯករាជ្យភាពដែរឬទេនៅក្នុងដំណើរការវេទិកាមជ្ឈត្តការ និងអាចធ្វើការប្តឹងជំទាស់បាន។ ភាពមិនលម្អៀងក្នុងន័យនេះគឺជាការលម្អៀងទៅរកភាគីណាមួយ នៅក្នុងដំណើរការមជ្ឈត្តការដូចជាការអនុញ្ញាតឲ្យភាគីមួយមានឆ្លើយ ឬការដាក់ភស្តុតាងច្រើនជាងភាគីមួយទៀត ឬមជ្ឈត្តករនោះស្តាប់យកតែហេតុផល និងទទួលយកនូវភស្តុតាងតែពីភាគីម្ខាង ដែលនាំឲ្យការកាត់សេចក្តីមិនមានភាពយុត្តិធម៌។ ឧទាហរណ៍: ដោយសារភាគីមួយជាក្រុមហ៊ុនវិនិយោគធំ ធ្វើឲ្យមជ្ឈត្តករមានបំណងចង់ធ្វើការរកស៊ីជាមួយ។ ដូច្នេះមជ្ឈត្តករបានផ្តល់ឱកាស និងយកចិត្តទុកដាក់ដល់ភាគីនោះច្រើនជាង ដើម្បីធ្វើការយកចិត្តបុគ្គលនោះក្នុងការអនុញ្ញាតឲ្យខ្លួនបានរកស៊ីជាមួយជាដើម។ ចំនែកឯឯករាជ្យភាពវិញ សំដៅទៅលើការឯករាជ្យរបស់មជ្ឈត្តករនោះ ដែលមិនស្ថិតនៅក្រោមអំណាចណាមួយ ឬទំនាក់ទំនងជិតស្និត ហើយអាចនាំឲ្យប៉ះពាល់ការសម្រេចសេចក្តី។ ឧទាហរណ៍: ភាគី (ក) បានជ្រើសរើសយកមជ្ឈត្តករម្នាក់ ដែលមជ្ឈត្តករនោះគឺជាបុគ្គលិកនៅក្រុមហ៊ុននោះ ដើម្បីឲ្យធ្វើជាមជ្ឈត្តករក្នុងការដោះស្រាយវិវាទរបស់ខ្លួន។ ដូច្នេះមជ្ឈត្តកររូបនេះមិនមានភាពឯករាជ្យឡើយ ដោយសារប្រសិនបើគាត់កាត់សេចក្តីឲ្យភាគីម្ខាងទៀតជាអ្នកឈ្នះ នោះគាត់នឹងអាចបាត់បង់ការងារជាបុគ្គលិននៃក្រុមហ៊ុននោះ។ ក្នុងករណីមួយទៀត ប្រសិនបើមជ្ឈត្តការ

[83] ចំណុចទី២.១ នៃតារាងតម្លៃសេវារបស់មជ្ឈត្តមណ្ឌលជាតិមជ្ឈត្តការផ្នែកពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា (ឧបសម្ព័ន្ធទី៨)
[84] មាត្រា ២០ នៃច្បាប់ស្តីពី មជ្ឈត្តការផ្នែកពាណិជ្ជកម្ម

និងភាគីវិវាទណាមួយជាប់សាច់ញាតិគ្នា នោះភាពឯករាជ្យរបស់មជ្ឈត្តករនេះក៏អាចត្រូវបាត់បង់ដែរ។

ដើម្បីធ្វើការប្តឹងជំទាស់ទៅនឹងមជ្ឈត្តករ ភាគីវិវាទត្រូវធ្វើការប្តឹងជាលាយលក្ខអក្សរទៅវេទិកាមជ្ឈត្តការក្នុងរយៈពេល ១៥ថ្ងៃ ឬក្រោយពីបានដឹងពីភាពលម្អៀង ឬមិនឯករាជ្យរបស់មជ្ឈត្តករនោះ សំរាប់ករណីដែលភាគីមិនមានការព្រមព្រៀងគ្នាជាមុនក្នុងការប្តឹងជំទាស់។ ប៉ុន្តែប្រសិនបើ ភាគីវិវាទបានព្រមព្រៀងគ្នាលើការប្តឹងជំទាស់ នីតិវិធីក្នុងការប្តឹងជំទាស់ត្រូវធ្វើតាមការព្រមព្រៀងនោះ។ នៅពេលទទួលបានពាក្យបណ្តឹងប្តឹងជំទាស់ វេទិកាមជ្ឈត្តការត្រូវធ្វើការពិនិត្យនិងសម្រេចលើប្តឹងនោះ ប៉ុន្តែប្រសិនបើមជ្ឈត្តករបានលាលែងពីមុខតំណែងមជ្ឈត្តករសំរាប់វេទិកានោះដោយខ្លួនឯង ឬភាគីម្ខាងទៀតយល់ព្រមក្នុងប្តឹងជំទាស់នេះ វេទិកាមជ្ឈត្តការមិនចាំបាច់ធ្វើការពិនិត្យឡើយ គឺវេទិកាមជ្ឈត្តការត្រូវសម្រេចដកមជ្ឈត្តករនោះចេញនឹងជំនួសដោយមជ្ឈត្តករថ្មីតែម្តង។ ការជំនួសដោយមជ្ឈត្តករថ្មី គឺត្រូវធ្វើការតែងតាំងតាមនីតិវិធីជ្រើសរើសមជ្ឈត្តករមុនដដែល។ ក្នុងករណីដែលការប្តឹងជំទាស់ត្រូវបានបដិសេធ ភាគីជំទាស់អាចធ្វើការស្នើទៅតុលាការ ឬមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ដើម្បីចេញសេចក្តីសម្រេចចុងក្រោយក្នុងរយៈពេល ៣០ថ្ងៃ។ ទន្ទឹមនឹងការប្តឹងជំទាស់នេះ ដំណើរការមជ្ឈត្តការនៅតែបន្តដដែល ដើម្បីធានាដល់ភាពឆាប់រហ័សនៃដំណើរការមជ្ឈត្តការ។[85]

## ឃ. អំណាច និងភារកិច្ចរបស់មជ្ឈត្តករ

អំណាចរបស់មជ្ឈត្តករ គឺខុសពីអំណាចរបស់ចៅក្រមតុលាការ ព្រោះថាអំណាចរបស់ចៅក្រមមានកំណត់នៅក្នុងច្បាប់ ហើយភាគីវិវាទមិនអាចកែប្រែអំណាចនោះបានឡើយ។ ផ្ទុយទៅវិញអំណាចរបស់មជ្ឈត្តករ ភាគីវិវាទអាចធ្វើការកំណត់ទៅតាមសេចក្តីត្រូវការរបស់ភាគីវិវាទ។

ក្នុងនាមជាមជ្ឈត្តករនៅក្នុងដំណើរការមជ្ឈត្តការ មជ្ឈត្តករមានភារកិច្ចដូចជា:

- ធានាថាមជ្ឈត្តវិនិច្ឆ័យមានអានុភាពអនុវត្ត និងចាប់បង្ខំ
- ធានានូវភាពមិនលម្អៀង និងឯករាជ្យ
- ផ្តល់ភាពស្មើគ្នាដល់ភាគីវិវាទ
- អនុលោមតាមនីតិវិធីដែលមានក្នុងកិច្ចព្រមព្រៀង ឬការកំណត់របស់មជ្ឈត្តការ
- បំពេញនូវកាតព្វកិច្ចរហូតដល់បញ្ចប់នីតិវិធី
- រក្សាការសម្ងាត់

[85] មាត្រា ២១ នៃច្បាប់ស្តីពី មជ្ឈត្តការផ្នែកពាណិជ្ជកម្ម

- ពន្លើននីតិវិធី
- មិនអាចធ្វើការផ្ទេរអំណាចឲ្យទៅភាគីណាមួយ
- ធ្វើការសម្រេចទៅតាមបញ្ញត្តិច្បាប់
- មិនប្រើលើសអំណាចដែលខ្លួនមាន
- ការសហការគ្នាក្នុងដំណើរការមជ្ឈត្តការ
- មិនទទួលអំណោយពីភាគីវិវាទ។[86]

### ៣.២.៣. ដំណើរការមជ្ឈត្តការ

#### ក. ទីកន្លែងធ្វើមជ្ឈត្តការ

ការជ្រើសរើសយកទីកន្លែងណាមួយក្នុងការធ្វើដំណើរការមជ្ឈត្តការ គឺជាការព្រមព្រៀងរបស់ភាគីវិវាទ ប៉ុន្តែក្នុងករណីភាគីវិវាទមិនបានព្រមព្រៀងគ្នាទេនោះ ទីកន្លែងសម្រាប់ធ្វើមជ្ឈត្តការគឺធ្វើឡើងនៅរាជធានីភ្នំពេញ។[87] ទោះបីជាយ៉ាងនេះក្តីទីកន្លែងធ្វើមជ្ឈត្តការអាចធ្វើឡើងផ្សេងពីនេះ ប្រសិនបើកាលៈទេសៈនៃសំណុំរឿងតម្រូវដូចជាភាពងាយស្រួលក្នុងការពិនិត្យភស្តុតាង ការស្តាប់សាក្សី ឬអ្នកជំនាញជាដើម។ ឧទាហរណ៍: ភាគីវិវាទមិនបានព្រមព្រៀងគ្នាអំពីទីកន្លែងធ្វើមជ្ឈត្តការទេ ប៉ុន្តែភាគីវិវាទទាំងពីរមានទីលំនៅនៅខេត្តកំពង់ស្ពឺដូចគ្នា ហើយកម្មវត្ថុដែលជាវិវាទស្ថិតនៅក្នុងខេត្តនោះដែរ ដូច្នេះទីកន្លែងសម្រាប់ធ្វើមជ្ឈត្តការត្រូវធ្វើឡើងក្នុងខេត្តកំពង់ស្ពឺ។

#### ខ. វិធានច្បាប់អនុវត្ត

ការសម្រេចយកច្បាប់ណាមួយយកមកអនុវត្តគឺជាសេរីភាពរបស់របស់ភាគី។ ប្រសិនបើភាគីវិវាទមិនបានធ្វើការកំណត់យកច្បាប់ណាមួយសម្រាប់យកមកអនុវត្តទេនោះ វេទិកាមជ្ឈត្តការជាអ្នកកំណត់យកច្បាប់ណាមួយយកមកអនុវត្តដែលវេទិកាមជ្ឈត្តការយល់ថាសមស្រប និងអាចអនុវត្តបានចំពោះបញ្ហាវិវាទ។[88] ដោយសារភាពខ្វះចន្លោះនៃច្បាប់ ការដែលភាគីវិវាទបានព្រមព្រៀងគ្នាជ្រើសរើសយកច្បាប់ណាមួយសម្រាប់យកមកអនុវត្តហើយ ប៉ុន្តែច្បាប់នោះមិនអាចយកមកអនុវត្តបានចំពោះបញ្ហាវិវាទ បញ្ញត្តិនៃច្បាប់មិនបានកំណត់អំពីការដែលត្រូវជ្រើសរើសច្បាប់ថ្មីដើម្បីយកមកអនុវត្តចំពោះវិវាទនោះទេ។ ចំពោះវិធាននៃច្បាប់ វេទិកាមជ្ឈត្តការមិនមែនពិនិត្យ និងពិចារណាតែទៅលើច្បាប់ប៉ុណ្ណោះទេ តែវេទិកាមជ្ឈត្តការក៏ពិនិត្យ និងពិចារណាផងដែរទៅលើ

[86] http://www.preservearticles.com/201104065087/arbitrator-his-appointment-powers-and-duties.html

[87] វិធាន ១៦នៃវិធានស្តីពី មជ្ឈត្តការរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម (ឧបសម្ព័ន្ធទី២)

[88] មាត្រា ២៨ នៃច្បាប់ស្តីពី មជ្ឈត្តការផ្នែកពាណិជ្ជកម្ម និងវិធាន ១៧.១ នៃវិធានស្តីពី មជ្ឈត្តការរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម (ឧបសម្ព័ន្ធទី២)

បញ្ញត្តិដែលមានចែងនៅក្នុងកិច្ចសន្យា និងទម្លាប់នៃការធ្វើពាណិជ្ជកម្ម។[89] ឧទាហរណ៍: ភាគីក្រុមហ៊ុនរបស់ម៉ាឡេ មានរោងចក្រនៅកម្ពុជា ហើយធ្វើការរកស៊ីជាមួយភាគីមួយទៀតដែលជាក្រុមហ៊ុនថៃក្នុងការនាំចេញនាំចូលនូវផលិតផលនោះ។ ក្នុងករណីនេះភាគីទាំងពីរអាចធ្វើការព្រមព្រៀងគ្នាជ្រើសរើសយកច្បាប់ណាមួយសំរាប់យកមកអនុវត្តនៅពេលមានវិវាទបាន ដូចជាច្បាប់ម៉ាឡេ ច្បាប់កម្ពុជា ឬច្បាប់ថៃ ឬច្បាប់នៃប្រទេសណាផ្សេងទៀតក៏បាន។

**គ. ភាសា**

ភាសាក៏ជាសេរីភាពក្នុងការកំណត់យករបស់ភាគីវិវាទដែរ ប្រសិនបើខ្លួនយល់ថាមានភាពងាយស្រួលក្នុងការធ្វើមជ្ឈត្តការ។ ថ្វីត្បិតតែបានកំណត់ដូច្នេះក៏ដោយវេទិកាមជ្ឈត្តការអាចបង្គាប់ឲ្យមានការបកប្រែពីភាគិវិវាទណាមួយដោយជាលាយលក្ខណអក្សរ ឬដោយផ្ទាល់មាត់ទៅភាសាមួយទៀតដែលវេទិកាមជ្ឈត្តការត្រូវការ។ ក្នុងករណីដែលភាគីវិវាទខកខានមិនបានកំណត់ភាសាសម្រាប់ប្រើប្រាស់ វេទិកាមជ្ឈត្តការជាអ្នកសម្រេចកំណត់យកភាសាណាមួយមកប្រើប្រាស់ដោយពិចារណាទៅលើភាគីវិវាទ និងឯកសារដែលពាក់ព័ន្ធ។[90]

### ៣.២.៤. ការបោះបង់សិទ្ធិប្តឹងជំទាស់

នៅពេលដែលភាគីបានព្រមព្រៀងគ្នាជ្រើសរើសយកមជ្ឈត្តការ ក្នុងការដោះស្រាយវិវាទរបស់ពួកគេនៅពេលដែលមានវិវាទកើតឡើង ប្រសិនបើភាគីណាមួយបានប្តឹងទៅមជ្ឈត្តការ ហើយភាគីម្ខាងទៀតបានដឹងថាភាគីនោះបានប្រព្រឹត្តខុសនឹងការព្រមព្រៀងគ្នា ប៉ុន្តែភាគីវិវាទនៅតែបន្តដំណើរការមជ្ឈត្តការដោយមិនធ្វើការប្តឹងជំទាស់ នោះមានន័យថាភាគីវិវាទបានបោះបង់សិទ្ធិក្នុងការជំទាស់របស់ខ្លួន ហើយព្រមគោរពយកនូវការប្រព្រឹត្តថ្មីនេះ។

## ៣.៣. នីតិវិធីក្នុងការដោះស្រាយវិវាទ

ក្រោយពីបានដឹងពីទីកន្លែងក្នុងការដោះស្រាយវិវាទតាមរយៈមជ្ឈត្តការ និងបានដាក់ពាក្យបណ្តឹង ព្រមទាំងជ្រើសរើសភាសា និងមជ្ឈត្តករួចហើយ ការជ្រើសរើសនីតិវិធី គឺជាជំហានបន្ទាប់។ នៅក្នុងការជ្រើសរើសនីតិវិធីក្នុងការដោះស្រាយវិវាទ ក៏មិនខុសគ្នាទៅនឹងការជ្រើសរើសទីកន្លែង ភាសា និងមជ្ឈត្តករនោះទេ គឺវាផ្អែកទៅតាមការព្រមព្រៀងគ្នារបស់ភាគីវិវាទ។ ក្នុងករណីដែលភាគីវិវាទទាំងពីរមិនបានធ្វើការព្រមព្រៀងគ្នា វេទិកាមជ្ឈត្តការត្រូវកំណត់យកនីតិវិធីមួយដែលវេទិកា

[89] វិធាន ១៧.៣ នៃវិធានស្តីពី មជ្ឈត្តការរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម (ឧបសម្ព័ន្ធទី២)

[90] មាត្រា ៣០ នៃច្បាប់ស្តីពី មជ្ឈត្តការផ្នែកពាណិជ្ជកម្ម និងវិធាន ១៨.១ និង១៨.២ នៃវិធានស្តីពី មជ្ឈត្តការរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម (ឧបសម្ព័ន្ធទី២)

យល់ថាសមស្រប។[91] នីតិវិធីក្នុងការដោះស្រាយវិវាទមាន២ គឺសវនាការដោយផ្ទាល់មាត់ និង ដំណើរការមជ្ឈត្តការដោយផ្អែកលើឯកសារផ្សេងៗជាភស្តុតាង។[92]

ប្រសិនបើដំណើរការមជ្ឈត្តការដោយផ្អែកលើឯកសារផ្សេងៗជាភស្តុតាង ត្រូវបានជ្រើសរើសជានីតិវិធីក្នុងការដោះស្រាយវិវាទ នោះវេទិកាមជ្ឈត្តការគឺធ្វើការពិនិត្យ និងសម្រេចតែទៅលើភស្តុតាងដែលភាគីវិវាទដាក់ជូនឲ្យពិនិត្យប៉ុណ្ណោះ។ ដោយឡែកប្រសិនបើសវនាការដោយផ្ទាល់មាត់ត្រូវបានជ្រើសរើសជានីតិវិធីក្នុងការដោះស្រាយវិវាទវិញនោះ វេទិកាមជ្ឈត្តការត្រូវរៀបចំឲ្យមានសវនាការ ដែលនីតិវិធីធម្មតានៃសវនាករមជ្ឈត្តការមានភាពដូចគ្នាជាមួយនឹងនីតិវិធីនៅតុលាការដែរ គឺបែងចែកជា ៦ដំណាក់កាលសំខាន់ៗគឺៈ សេចក្តីថ្លែងហេតុបើករបស់មជ្ឈត្តករ សេចក្តីថ្លែងហេតុបើករបស់ភាគី ការប្រើប្រាស់ភស្តុតាងជាឯកសារ ការសាកសួរសាក្សី ការឆ្លើយ និងឆ្លើយតប និងសេចក្តីថ្លែងការបិទ។[93]

### ៣.៣.១. សេចក្តីថ្លែងហេតុបើករបស់មជ្ឈត្តករ

នៅក្នុងដំណាក់កាលនេះមជ្ឈត្តករ គឺជាអ្នកបើកសវនាការដែលត្រូវណែនាំពីខ្លួនឯងទៅភាគីវិវាទ បញ្ជាក់ឡើងវិញនូវនីតិវិធីក្នុងការដោះស្រាយវិវាទដែលភាគីបានព្រមព្រៀងគ្នា ឬកំណត់ដោយវេទិកាមជ្ឈត្តការ និងផ្តល់ទស្សនៈរបស់ខ្លួនទៅលើបញ្ហាវិវាទ ដើម្បីឲ្យភាគីវិវាទយល់ច្បាស់ពីលំដាប់លំដោយនៃនីតិវិធី និងបញ្ហាវិវាទដែលនឹងត្រូវលើកយកមកដោះស្រាយក្នុងសវនការ។

### ៣.៣.២. សេចក្តីថ្លែងហេតុបើករបស់ភាគី

បន្ទាប់ពីមជ្ឈត្តករបានធ្វើសេចក្តីថ្លែងហេតុបើករួចហើយ ភាគីវិវាទត្រូវធ្វើសេចក្តីថ្លែកហេតុរបស់ខ្លួនទៅវេទិកា ដែលបញ្ជាក់ពីអង្គហេតុ និងអង្គច្បាប់ និងការទាមទាររបស់ខ្លួន។ បន្ថែមពីលើនេះ សេចក្តីថ្លែងការបើកផ្ទាល់មាត់អាចធ្វើឡើងជំនួស ឬបន្ថែមលើការរៀបរាប់សង្ខេបមុនសវនាការបាន។ គោលបំណងនៃការធ្វើសេចក្តីថ្លែងការនេះ គឺដើម្បីឲ្យមជ្ឈត្តករយល់បន្ថែម និងកាន់តែច្បាស់ពីអង្គហេតុ និងវិវាទដែលកើតមានឡើង ដើម្បីមានភាពងាយស្រួលក្នុងការវាយតម្លៃលើភស្តុតាង និងឯកសារនានា។

### ៣.៣.៣. ការប្រើប្រាស់ភស្តុតាង

[91] មាត្រា ២៧ នៃច្បាប់ស្តីពី មជ្ឈត្តការផ្នែកពាណិជ្ជកម្ម

[92] វិធាន ២៤ នៃវិធានស្តីពី មជ្ឈត្តការរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម (ឧបសម្ព័ន្ធទី២)

[93] សៀវភៅការដោះស្រាយវិវាទក្រៅផ្លូវតុលាការរបស់ក្រសួងពាណិជ្ជកម្ម និងធនាគារអភិវឌ្ឍនអាស៊ី ទំព័រ ៣៧ និង ៣៨ និងសៀវភៅដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ (មេធាវី ស្ទីវិន អ៊ែម អូស្ទើរមីឡឺរ) បោះពុម្ពលើកទី ២ ទំព័រ ១៧៥ ចំនុចទី៤

នៅក្នុងរឿងដែលមានភាពស្មុគស្មាញ ភស្តុតាងជាឯកសារ គឺមានសារៈសំខាន់ណាស់ក្នុងការដោះស្រាយវិវាទ។ ជាទូទៅភាគីដែលចាប់ផ្តើមដំណើរការមជ្ឈត្តកម្ម គឺតែងតែមាននូវភស្តុតាង និងឯកសារនានា ក្នុងការអះអាងសំរាប់ការទាមទាររបស់ខ្លួន។ ដោយឡែកភាគីចុងចម្លើយក៏ត្រូវមានភស្តុតាងផងដែរ ក្នុងករណីដែលខ្លួនពុំបានប្រព្រឹត្តដូចដែលភាគីដើមបណ្តឹងចោទ ដើម្បីធ្វើការដោះបន្ទុក។ ភស្តុតាងជាឯកសារ អាចជាកិច្ចសន្យាដែលបង្កើតឲ្យមានវិវាទ លិខិត ឬឯកសារឆ្លើយឆ្លងគ្នា វិក័យបត្រ ឬការចុះបញ្ជីគណនីផ្សេងៗ។ បន្ថែមពីលើការពិនិត្យភស្តុតាង និងឯកសារ មជ្ឈត្តករក៏អាចអញ្ជើញអ្នកជំនាញឲ្យមកធ្វើការបកស្រាយបំភ្លឺបន្ថែមបាន ហើយមជ្ឈត្តករក៏អាចចុះទៅពិនិត្យបន្ថែមដល់ទីកន្លែងផងដែរ។

### ៣.៣.៤. ការសាកសួរសាក្សី

ក្រៅពីការពិនិត្យភស្តុតាង ការសាកសួរសាក្សីក៏មានសារៈសំខាន់ដែរ ក្នុងការស្រាយបំភ្លឺបន្ថែមនូវបញ្ហាវិវាទ។ នៅក្នុងនីតិវិធីសាកសួរសាក្សីក្នុងដំណើរការមជ្ឈត្តការ គឺដូចគ្នាទៅនឹងដំណើរការនៃការសាកសួរសាក្សីនៅក្នុងតុលាការដែរ។ ភាគីដែលចង់ដាក់បញ្ចូលនូវសាក្សីចូលសវនាការ ត្រូវមានការយល់ព្រមពីមជ្ឈត្តករជាមុនសិន ហើយសាក្សីត្រូវធ្វើការស្បថស្បែរមុននឹងផ្តល់ចម្លើយ ឬធ្វើការអះអាង។ សាក្សីជំនាញជាទូទៅ អាចជួយក្នុងការបញ្ជាក់ពីករណីវិវាទរបស់នរណាម្នាក់នៅក្នុងដំណើរការមជ្ឈត្តការ។ នៅក្នុងនីតិវិធីសាកសួរសាក្សីនេះ ភាគីអាចធ្វើការសាកសួរដេញដោលជាមួយសាក្សីបាន ហើយបើសិនជាមជ្ឈត្តករមានសំនួរបន្ថែម មជ្ឈត្តករក៏អាចធ្វើការសាកសួរទៅលើសាក្សីនោះបានផងដែរ។[94]

### ៣.៣.៥. ការឆ្លើយ និងឆ្លើយតប

នៅក្នុងដំណើរការមជ្ឈត្តការសវនាការអនុញ្ញាតឲ្យមានការឆ្លើយ និងឆ្លើយតបរបស់ភាគី។ ភាគីមួយឆ្លើយ បន្ទាប់មកភាគីម្ខាងទៀតឆ្លើយតបទៅវិញ ដែលការឆ្លើយនេះគឺត្រូវសំអាងទៅលើភស្តុតាងដែលមាន និងបញ្ជាក់បន្ថែម។ នៅក្នុងការឆ្លើយ និងឆ្លើយតបនេះនេះផងដែរ មជ្ឈត្តករអាចស្នើសុំឲ្យ ភាគីស្រាយបំភ្លឺបន្ថែមទៅលើភស្តុតាងដែលខ្លួនបានដាក់ជូនសវនាការនូវបញ្ហាជាក់លាក់ខ្លះ។

### ៣.៣.៦. សេចក្តីថ្លែងការបិទ

[94] បទសម្ភាសន៍ជាមួយលោកស្រី ស៊ីន គឹមស៊ាន ជាមជ្ឈត្តករនៃ ម.ជ.ម នៅថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១៤

ដំណាក់ការចុងក្រោយមុននឹងឈានដល់ការចេញសេចក្តីសម្រេចមជ្ឈត្តការ គឺការធ្វើសេចក្តីថ្លែងការបិទសវនាការ ដោយភាគីនីមួយៗសង្ខេបឡើងវិញនូវទស្សនៈរបស់ពួកគេ ដោយសង្កត់ធ្ងន់ទៅលើចំណុចសំខាន់ៗ ដើម្បីឲ្យមជ្ឈត្តករធ្វើការពិភាក្សា និងសម្រេចលើរឿងក្តីនោះ។ ជាទូទៅនៅក្នុងដំណាក់កាលនេះ មេធាវីរបស់ចុងបណ្តឹង ឬភាគីចុងបណ្តឹងផ្ទាល់ជាអ្នកធ្វើសេចក្តីថ្លែងការបិទនេះមុន។

ជារួមនៅក្នុងនីតិវិធីសវនាការនេះ ភាគីត្រូវបានធានាផ្តល់នូវសិទ្ធិស្មើរគ្នាទាំងការសួរដេញដោល ការឆ្លើយ និងការដាក់ឯកសារ ឬភស្តុតាងផ្សេងៗ ហើយដំណើរការនៃសវនាការមជ្ឈត្តការមិនត្រូវបានកំណត់ចំនួនសវនាការឡើយ គឺវាអាស្រ័យទៅលើចំនួននៃវិវាទ និងភាពស្មុគស្មាញនៃវិវាទ។

## ៣.៤. នីតិវិធីក្រោយការដោះស្រាយវិវាទ

នៅក្រោយពេលវិវាទត្រូវបានដោះស្រាយ នីតិវិធីបន្ទាប់ គឺការចេញនូវសេចក្តីសម្រេចមជ្ឈត្តវិនិច្ឆ័យ។ ក្នុងករណីដែលមានការខ្វះខាត ការសុំកែតម្រូវ ការបកស្រាយជ្ឈត្តវិនិច្ឆ័យ និងការចេញសេចក្តីសម្រេចបន្ថែម គឺជាករណីបន្ថែមពីលើការចេញមជ្ឈត្តវិនិច្ឆ័យដើម។

### ៣.៤.១. ការចេញសេចក្តីសម្រេចមជ្ឈត្តវិនិច្ឆ័យ

ក្រោយពីនីតិវិធីសវនាការត្រូវបានបញ្ចប់ ជំហានបន្ទាប់ក៏ដូចជាជំហានចុងក្រោយគឺការចេញនូវសេចក្តីសម្រេចមជ្ឈត្តវិនិច្ឆ័យ។ ក្នុងការចេញនូវសេចក្តីសម្រេចមជ្ឈត្តវិនិច្ឆ័យ វេទិកាមជ្ឈត្តការត្រូវសម្រេចលើវិវាទដោយពឹងផ្អែក និងពិចារណាលើភស្តុតាង វិធាននៃច្បាប់ លក្ខខណ្ឌនៃកិច្ចសន្យា ក៏ដូចជាទម្លាប់នៃការធ្វើពាណិជ្ជកម្មរបស់ភាគីវិវាទ និងអាចធ្វើមជ្ឈត្តវិនិច្ឆ័យឲ្យស្របតាមសមធម៌។[95]

វេទិកាមជ្ឈត្តការត្រូវបញ្ជូនសេចក្តីព្រាងមជ្ឈត្តវិនិច្ឆ័យទៅអគ្គលេខាធិការដ្ឋាន ដើម្បីពិនិត្យពិច័យលើទម្រង់របស់មជ្ឈត្តវិនិច្ឆ័យមុននឹងធ្វើការចេញនូវមជ្ឈត្តវិនិច្ឆ័យ។ ក្នុងការចេញនូវមជ្ឈត្តវិនិច្ឆ័យនេះ វេទិកាមជ្ឈត្តការត្រូវធ្វើឡើងជាលាយលក្ខណអក្សរ និងបញ្ជាក់ពីមូលហេតុដែលនាំឲ្យចេញនូវមជ្ឈត្តវិនិច្ឆ័យ ព្រមទាំងកាលបរិច្ឆេទ និងទីកន្លែងដែលមជ្ឈត្តវិនិច្ឆ័យត្រូវបានធ្វើឡើងផងដែរ។[96] ការបញ្ជាក់ពីមូលហេតុនេះ គឺត្រូវបានកំណត់ក្នុងបញ្ញត្តិច្បាប់ ដែលទាមទារឲ្យមជ្ឈត្តករ

[95] វិធាន ១៧ នៃវិធានស្តីពីមជ្ឈត្តការរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម (ឧបសម្ព័ន្ធទី២)

[96] មាត្រា ៣៩ កថាខណ្ឌទី១ និង៤ នៃច្បាប់ស្តីពី មជ្ឈត្តការផ្នែកពាណិជ្ជកម្ម និងវិធាន ៣៣ នៃវិធានស្តីពីមជ្ឈត្តការរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម (ឧបសម្ព័ន្ធទី២)

បញ្ជាក់នូវការយល់ឃើញក្នុងការសម្រេចនូវការចេញមជ្ឈត្តវិនិច្ឆ័យនេះ។ តែទោះជាយ៉ាងណាសេរីភាពក្នុងការកំណត់របស់ភាគីវិវាទគឺមានវិសាលភាពជាងការកំណត់ច្បាប់ មានន័យថាក្នុងករណីភាគីវិវាទបានព្រមព្រៀងគ្នា ឬបានកំណត់នៅក្នុងកិច្ចព្រមព្រៀងដោយមិនចាំបាច់ឲ្យវេទិកាមជ្ឈត្តការបញ្ជាក់ពីមូលហេតុក្នុងមជ្ឈត្តវិនិច្ឆ័យនោះ នោះវេទិកាមជ្ឈត្តការមិនចាំបាច់បញ្ជាក់ពីមូលហេតុនោះទេ គឺវេទិកាមជ្ឈត្តការកំណត់ត្រឹមតែការសម្រេច ដែលត្រូវយកមកអនុវត្តសំរាប់ភាគីវិវាទតែប៉ុណ្ណោះ។[97]

ទោះបីជាយ៉ាងនេះក្តី ចំពោះសោហ៊ុយចំណាយក្នុងដំណើរការមជ្ឈត្តការ គឺត្រូវកំណត់នៅក្នុងមជ្ឈត្តវិនិច្ឆ័យ[98] ដែលជាទូទៅគឺបែងចែក៥០ស្មើរគ្នាចំពោះភាគីវិវាទ ប៉ុន្តែនៅពេលខ្លះក៏ឃើញមានផងដែរថាភាគីដែលចាញ់ក្តីត្រូវបង់ថ្លៃទាំងស្រុងតែម្តង ប្រសិនបើភាគីវិវាទបានកំណត់ទុកជាមុន។ ការចំណាយក្នុងដំណើរការមជ្ឈត្តការមានដូចជា កម្រៃសេវាចុះបញ្ជី កម្រៃសេវារដ្ឋបាល កម្រៃសេវាតែងតាំងមជ្ឈត្តករ កម្រៃសេវាវេទិកាមជ្ឈត្តការ និងកម្រៃផ្សេងៗទៀត។[99] អ្វីដែលសំខាន់នោះគឺប្រសិនបើមានមជ្ឈត្តករលើសពីម្នាក់ នោះការចេញនូវមជ្ឈត្តវិនិច្ឆ័យត្រូវធ្វើឡើងតាមមតិភាគច្រើនដោយប្រៀប ហើយត្រូវមានចុះហត្ថលេខាពីមជ្ឈត្តករទាំងអស់នៃវេទិកាមជ្ឈត្តការ។

ម៉្យាងវិញទៀតនៅពេលដែលភាគីវិវាទបានព្រមព្រៀងស្រុះស្រួលគ្នា ទោះបីជានៅមុនពេលចាប់ផ្តើម ឬកំពុងធ្វើដំណើរការមជ្ឈត្តការក៏ដោយ ឬភាគីវិវាទឯកភាពឲ្យបញ្ចប់ដំណើរការមជ្ឈត្តការពេលនោះមជ្ឈត្តការត្រូវធ្វើការបញ្ចប់ដំណើរការរបស់ខ្លួន និងចេញនូវមជ្ឈត្តវិនិច្ឆ័យដោយបញ្ជាក់ថាភាគីវិវាទបានផ្សះផ្សាគ្នា ដោយមិនចាំបាច់មានមូលហេតុអ្វីត្រូវបញ្ជាក់លើសេចក្តីសម្រេចនោះទេ ឬក៏អាចចេញនូវដីកាបង្គាប់បញ្ចប់ដំណើរការមជ្ឈត្តការ ដោយអាស្រ័យទៅលើដំណើររឿង និងការឯកភាពរបស់ភាគីវិវាទ។[100] ឧទាហរណ៍: ក្រោយពេលដែលភាគីវិវាទបានឯកភាពគ្នាបញ្ចប់ដំណើរការមជ្ឈត្តការ ហើយភាគីស្នើសុំឲ្យមជ្ឈត្តការចេញនូវមជ្ឈត្តវិនិច្ឆ័យមួយពីការឯកភាពគ្នាបញ្ចប់ដំណើរការមជ្ឈត្តការ នោះវេទិកាមជ្ឈត្តការត្រូវចេញនូវមជ្ឈត្តវិនិច្ឆ័យ តែក្នុងករណីដែលពុំមានការស្នើសុំនោះទេ វេទិកាមជ្ឈត្តការអាចចេញនូវដីកាបញ្ចប់ដំណើរការមជ្ឈត្តការបាន។ ដោយឡែកក្នុងករណីភាគីប្តឹងទាមទារបានដកពាក្យទាមទាររបស់ខ្លួនវិញ ហើយភាគីឆ្លើយតបមិនធ្វើការជំទាស់នឹងការដកពាក្យនោះ ឬវេទិកាមជ្ឈត្តការរកឃើញនូវមូលហេតុដែលបញ្ជាក់ពីភាពមិនចាំបាច់ក្នុងការ

[97] មាត្រា ២៩ កថាខណ្ឌទី២ នៃច្បាប់ស្តីពី មជ្ឈត្តការផ្នែកពាណិជ្ជកម្ម
[98] មាត្រា ២៩ កថាខណ្ឌទី២ នៃច្បាប់ស្តីពី មជ្ឈត្តការផ្នែកពាណិជ្ជកម្ម
[99] វិធាន ៤១ នៃវិធានស្តីពី មជ្ឈត្តការរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម (ឧបសម្ព័ន្ធទី២)
[100] មាត្រា ៣៨ នៃច្បាប់ស្តីពី មជ្ឈត្តការផ្នែកពាណិជ្ជកម្ម

ការបន្តដំណើរការ ឬការធ្វើមជ្ឈត្តការនោះពុំអាចបន្តទៅទៀតការ នោះដំណើរការមជ្ឈត្តការត្រូវបញ្ចប់ដោយការចេញនូវដីកាបង្គាប់បញ្ចប់ដំណើរការមជ្ឈត្តការ។[101] រាល់ការចេញនូវសេចក្តីសម្រេចមជ្ឈត្តវិនិច្ឆ័យ វេទិការមជ្ឈត្តការកំណត់ចេញតែមជ្ឈត្តវិនិច្ឆ័យដែលជាភាសាខ្មែរ ឬភាសាអង់គ្លេសតែប៉ុណ្ណោះ។[102]

### ៣.៤.២. ការសុំកែតម្រូវ បកស្រាយមជ្ឈត្តវិនិច្ឆ័យ និងការចេញសេចក្តីសម្រេចបន្ថែម

ក្រោយពីចេញនូវមជ្ឈត្តវិនិច្ឆ័យរួចហើយ បញ្ញត្តិនៃច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្មបានផ្តល់ឱកាសឲ្យភាគីវិវាទអាចស្នើសុំកែតម្រូវចំពោះកំហុសបច្ចេកទេស ដែលកើតឡើងដោយការធ្វេសប្រហែសលើមជ្ឈត្តវិនិច្ឆ័យដូចជា កំហុសផ្នែកគណនា កំហុសផ្នែកការងារលេខាធិការ និងកំហុសនៃការបោះពុម្ព រឺកំហុសដទៃទៀតដែលមានលក្ខណៈស្រដៀងគ្នា។ ឧទាហរណ៍: ចំនួនទឹកប្រាក់នៃវិវាទគឺ ១០០០០ ដុល្លា ចំនែកឯនៅក្នុងមជ្ឈត្តវិនិច្ឆ័យសម្រេចឲ្យ ១០០០ដុល្លា ឬកំហុសនៃអក្ខរាវិរុទ្ធដទៃទៀត នោះភាគីដែលចាញ់ក្តីអាចស្នើសុំទៅវេទិកាមជ្ឈត្តការឲ្យកែតម្រូវបាន។

ម្យ៉ាងវិញទៀត ការសុំកែតម្រូវនេះមិនចាំបាច់តម្រូវទាល់តែភាគីវិវាទស្នើសុំនោះទេ ប្រសិនបើវេទិកាមជ្ឈត្តការមើលឃើញនូវកំហុសរបស់ខ្លួន វេទិកាមជ្ឈត្តការអាចធ្វើការកែតម្រូវដោយខ្លួនឯងបាន។[103] ដោយឡែកភាគីវិវាទអាចធ្វើការស្នើសុំដល់វេទិកាមជ្ឈត្តការឲ្យធ្វើការបកស្រាយ រឺអធិប្បាយលើសេចក្តីសម្រេចមជ្ឈត្តវិនិច្ឆ័យដែលមានភាពមិនច្បាស់លាស់ ដោយមានការជូនដំណឹងទៅភាគីម្ខាងទៀតជាមុន ហើយរាល់ការបកស្រាយសេចក្តីសម្រេចនេះ នឹងក្លាយជាផ្នែកមួយនៃសេចក្តីសម្រេចមជ្ឈត្តវិនិច្ឆ័យ។[104]

ទោះបីជាយ៉ាងណាក្តីភាពខ្វះចន្លោះនៅតែមាន ក្នុងករណីដែលមជ្ឈត្តវិនិច្ឆ័យមិនបានដាក់បញ្ចូលនូវការទាមទារ ដែលបានលើកឡើងក្នុងដំណើរការមជ្ឈត្តការទេ ពេលនោះភាគីវិវាទដោយបានជូនដំណឹងទៅភាគីម្ខាងទៀតពីបញ្ហានេះ អាចស្នើសុំផងដែរឲ្យវេទិកាមជ្ឈត្តការចេញសេចក្តីសម្រេចបន្ថែមចំពោះបណ្តឹងទាមទារនេះ។[105] ឧទាហរណ៍: វិវាទកើតឡើងទៅលើការដឹកជញ្ជូនយឺតយ៉ាវ និងទំនិញមិនមានគុណភាពទៅតាមការព្រមព្រៀងគ្នា ប៉ុន្តែនៅពេលដែលចេញសេចក្តី

[101] មាត្រា ៤០ នៃច្បាប់ស្តីពី មជ្ឈត្តការផ្នែកពាណិជ្ជកម្ម

[102] វិធាន ១៨.៣ នៃវិធានស្តីពី មជ្ឈត្តការរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម (ឧបសម្ព័ន្ធទី២)

[103] មាត្រា ៤១ ចំនុចទី១ (ក) និង ចំនុចទី២ នៃច្បាប់ស្តីពី មជ្ឈត្តការផ្នែកពាណិជ្ជកម្ម

[104] មាត្រា ៤១ ចំនុចទី១ (ខ) នៃច្បាប់ស្តីពី មជ្ឈត្តការផ្នែកពាណិជ្ជកម្ម

[105] មាត្រា ៤១ ចំនុចទី៣ នៃច្បាប់ស្តីពី មជ្ឈត្តការផ្នែកពាណិជ្ជកម្ម

សម្រេចគឺកំណត់តែទៅលើវិវាទដឹកជញ្ជូនយឺតយ៉ាវ មិនបានកំណត់ពីវិវាទលើគុណភាពទំនិញ។ ដូច្នេះភាគីអាចស្នើសុំឲ្យមានសេចក្តីសម្រេចបន្ថែមលើវិវាទនៃគុណភាពនៃទំនិញបាន។

រាល់ការស្នើសុំកែតម្រូវ បកស្រាយមជ្ឈត្តវិនិច្ឆ័យ ឬការចេញនូវសេចក្តីសម្រេចបន្ថែម ភាគីដែលចង់ស្នើសុំត្រូវធ្វើការស្នើសុំនេះក្នុងរយៈពេល ៣០ថ្ងៃ បន្ទាប់ពីបានទទួលមជ្ឈត្តវិនិច្ឆ័យ។ ចំណែកឯវេទិកាមជ្ឈត្តការវិញក៏មានរយៈពេល ៣០ថ្ងៃ ដូចគ្នាក្នុងការកែតម្រូវ បកស្រាយមជ្ឈត្តការ ឬចេញនូវសេចក្តីសម្រេចបន្ថែម បន្ទាប់ពីបានពីបានទទួលពាក្យស្នើសុំពីភាគី។[106] ប៉ុន្តែក្នុងករណីចាំបាច់ វេទិកាមជ្ឈត្តការអាចធ្វើការពន្យាពេលបាន ដោយជូនដំណឹងទៅភាគីវិវាទពីការពន្យាពេលនេះ។[107] ក្នុងការចេញនូវមជ្ឈត្តវិនិច្ឆ័យកែតម្រូវ បកស្រាយ ឬមជ្ឈត្តវិនិច្ឆ័យបន្ថែម វេទិកាមជ្ឈត្តការត្រូវបញ្ជូនសេចក្តីព្រាងមជ្ឈត្តវិនិច្ឆ័យទៅអគ្គលេខាធិការដ្ឋាន ដើម្បីពិនិត្យពិច័យលើទម្រង់របស់មជ្ឈត្តវិនិច្ឆ័យមុននឹងធ្វើការចេញនូវមជ្ឈត្តវិនិច្ឆ័យនេះដូចគ្នានឹងមជ្ឈត្តវិនិច្ឆ័យដើមដែរ។

## ៤. អានុភាពនៃសេចក្តីសម្រេចមជ្ឈត្តវិនិច្ឆ័យ និងការប្តឹងឧបាស្រ័យ

### ៤.១. អានុភាពនៃសេចក្តីសម្រេចមជ្ឈត្តវិនិច្ឆ័យ

តាមច្បាប់ប្រទេសភាគីច្រើន និងច្បាប់អន្តរជាតិព្រមទាំងកម្ពុជាផង សេចក្តីសម្រេចមជ្ឈត្តវិនិច្ឆ័យគឺជាសេចក្តីសម្រេចចុងក្រោយ និងមានអនុភាពចាប់បង្ខំ។[108] តែទោះបីជាយ៉ាងនេះក្តីវាមិនមានអានុភាពទាំងស្រុងភ្លាមទេចំពោះភាគីវិវាទ ពោលគឺប្រសិនបើភាគីចាញ់ក្តីខកខានមិនបានគោរពតាមមជ្ឈត្តវិនិច្ឆ័យនោះ វេទិកាមជ្ឈត្តការពុំមានអំណាចចាប់បង្ខំដល់ភាគីនោះឡើយ។ ថ្វីត្បិតតែវេទិកាមជ្ឈត្តការពុំមានអំណាចចាប់បង្ខំដល់ភាគី ប៉ុន្តែក្នុងករណីដែលភាគីចាញ់ក្តីមិនគោរពតាមសេចក្តីសម្រេចមជ្ឈត្តវិនិច្ឆ័យ ភាគីឈ្នះក្តីអាចយកសេចក្តីសម្រេចនោះទៅសុំការអនុវត្តតាមប្រព័ន្ធតុលាការបាន។ ដោយឡែកនៅកម្ពុជាសមត្ថកិច្ចក្នុងការអនុវត្តនេះជាសមត្ថកិច្ចរបស់សាលាឧទ្ធរណ៍ មានន័យថាភាគីឈ្នះក្តីត្រូវយកសេចក្តីសម្រេចនេះទៅសុំការអនុវត្តពីសាលាឧទ្ធរណ៍។[109] ក្នុងការស្នើសុំឲ្យអនុវត្តនេះភាគីត្រូវដាក់ពាក្យសុំជាលាយលក្ខណអក្សរទៅសាលាឧទ្ធរណ៍ ជាមួយនឹងមជ្ឈត្តវិនិច្ឆ័យ និងកិច្ចព្រមព្រៀងមជ្ឈត្តការនូវច្បាប់ដើម ឬសំណៅចម្លងដែលមានការបញ្ជាក់ត្រឹម

---

[106] មាត្រា ៥១ នៃច្បាប់ស្តីពី មជ្ឈត្តការផ្នែកពាណិជ្ជកម្ម

[107] មាត្រា ៥១ ចំនុចទី៤ នៃច្បាប់ស្តីពី មជ្ឈត្តការផ្នែកពាណិជ្ជកម្ម

[108] វិធាន ៣៧ នៃវិធានស្តីពី មជ្ឈត្តការរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម (ឧបសម្ព័ន្ធទី២)

[109] មាត្រា ៥៥ កថាខណ្ឌទី១ នៃច្បាប់ស្តីពី មជ្ឈត្តការផ្នែកពាណិជ្ជកម្ម

ត្រូវ ព្រមទាំងសំណៅបកប្រែជាភាសាខ្មែរដែលមានការបញ្ជាក់ត្រឹមត្រូវ ប្រសិនបើច្បាប់ដើមមិនមែនជាភាសាខ្មែរ។[110]

អ្វីដែលជាលក្ខណៈពិសេសនៃមជ្ឈត្តវិនិច្ឆ័យនោះគឺ កម្ពុជាបានផ្តល់សច្ចាប័នលើអនុសញ្ញាស្តីពីការទទួលស្គាល់ និង ការអនុវត្តន៍សេចក្តីសម្រេចរបស់មជ្ឈត្តករបរទេស ឬអនុសញ្ញាទីក្រុងញូវយ៉កនៅថ្ងៃទី០៥ ខែមករា ឆ្នាំ១៩៦០ និងចូលជាធរមាននៅថ្ងៃទី០៤ ខែមេសា ឆ្នាំ១៩៦០។[111] ការចូលជាសមាជិកនៃអនុសញ្ញានេះ គឺធ្វើឲ្យសេចក្តីសម្រេចមជ្ឈត្តការទោះបីធ្វើឡើងនៅប្រទេសណាក៏ដោយឲ្យតែជាសមាជិកនៃអនុសញ្ញានេះរួមទាំងកម្ពុជាផង អាចយកសេចក្តីសម្រេចនេះទៅអនុវត្តន៍នៅប្រទេសផ្សេងដែលជាសមាជិកនៃអនុសញ្ញា និងទទួលបានការទទួលស្គាល់ផងដែរ។[112] ក្នុងនោះសមាជិកនៃអនុសញ្ញានេះគឺមានចំនួន១៤៩ប្រទេស[113] ដែលមានភាពងាយស្រួលដល់ភាគីវិវាទក្នុងការអនុវត្តនៃសេចក្តីសម្រេចចំពោះភាគីវិវាទម្ខាងទៀត ដែលមិនមែនជាជនជាតិខ្មែរ និងមិនមានទ្រព្យសកម្មក្នុងប្រទេសកម្ពុជា។ ឧទាហរណ៍ៈ វិវាទរវាងក្រុមហ៊ុនថៃ និងក្រុមហ៊ុនចិនត្រូវបានធ្វើមជ្ឈត្តការនៅកម្ពុជា។ មជ្ឈត្តវិនិច្ឆ័យរបស់មជ្ឈត្តការកម្ពុជា ក្រុមហ៊ុនថៃអាចយកមជ្ឈត្តវិនិច្ឆ័យនេះទៅសុំឲ្យអនុវត្តចំពោះក្រុមហ៊ុនចិនដែលមានទ្រព្យសកម្មនៅប្រទេសចិនបាន។

### ៤.២. ការប្តឹងជំទាស់នឹងសេចក្តីសម្រេចមជ្ឈត្តវិនិច្ឆ័យ

សេចក្តីសម្រេចរបស់មជ្ឈត្តការ ឬមជ្ឈត្តវិនិច្ឆ័យ ជាសេចក្តីសម្រេចចុងក្រោយដែលភាគីមិនអាចធ្វើការតវ៉ាបាន។ តែទោះជាយ៉ាងនេះក្តីបញ្ញត្តិនៃច្បាប់បានកំណត់នូវលក្ខខណ្ឌមួយចំនួនដែលភាគីវិវាទអាចធ្វើការប្តឹងតវ៉ានឹងសេចក្តីសម្រេចនោះ។ ការប្តឹងជំទាស់នឹងសេចក្តីសម្រេចមជ្ឈត្តការមិនអាចធ្វើឡើងចំពោះការមិនពេញចិត្តនឹងសេចក្តីសម្រេចនោះទេ គឺភាគីវិវាទអាចប្តឹងជំទាស់នឹងសេចក្តីសម្រេចរបស់មជ្ឈត្តការបានតែចំពោះដំណើរការនៃវិវាទមជ្ឈត្តការបានធ្វើខុសនឹងនីតិវិធីដែលភាគីបានកំណត់ក្នុងកិច្ចព្រមព្រៀង ឬផ្ទុយនឹងបញ្ញត្តិនៃច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម។[114] ការប្តឹងជំទាស់នឹងនីតិវិធីក្នុងដំណើរការមជ្ឈត្តការអាចត្រូវធ្វើឡើង បើភាគីណាមួយនៃវិវាទបានបាត់បង់សិទ្ធិមួយចំនួនដូចជាការតែងតាំងមជ្ឈត្តករ ឬមិនបានទទួលដំណឹងពីដំណើរការមជ្ឈត្តការ ឬកិច្ចព្រមព្រៀងមជ្ឈត្តការនោះពុំអាចយកជាការបាន ឬកម្មវត្ថុនៃវិវាទពុំអាចដោះស្រាយ

---

[110] មាត្រា ៤៥ កថាខណ្ឌទី២ នៃច្បាប់ស្តីពី មជ្ឈត្តការផ្នែកពាណិជ្ជកម្ម

[111] http://www.newyorkconvention.org/contracting-states/list-of-contracting-states

[112] មាត្រា ១ នៃអនុសញ្ញាទីក្រុងញូវយ៉កស្តីពី ការទទួលស្គាល់ និងការអនុវត្តន៍សេចក្តីសម្រេចរបស់មជ្ឈត្តករបរទេស (ឧបសម្ព័ន្ធទី៦)

[113] http://www.newyorkconvention.org/contracting-states

[114] មាត្រា ៤៤ នៃច្បាប់ស្តីពី មជ្ឈត្តការផ្នែកពាណិជ្ជកម្ម

តាមរយៈមជ្ឈត្តការបាន ឬដំណើរការនៃមជ្ឈត្តការមិនស្របតាមកិច្ចព្រមព្រៀងរបស់ភាគី ឬមជ្ឈត្ត វិនិច្ឆ័យផ្ទុយនឹងនយោបាយសាធារណៈជាដើម។[115]

ក្នុងការប្តឹងជំទាស់នឹងសេចក្តីសម្រេចមជ្ឈត្តការ ភាគីវិវាទណាមួយដែលមានបំណងចង់ប្តឹងអាចធ្វើការដាក់ពាក្យប្តឹងជំទាស់ទៅសាលាឧទ្ធរណ៍ជាលាយលក្ខណអក្សរ និងភស្តុតាងដែលបង្ហាញពីកំហុសឆ្គងនៃនីតិវិធីរបស់វេទិកាមជ្ឈត្តការ ដើម្បីឲ្យសាលាឧទ្ធរណ៍ធ្វើការពិនិត្យនឹងសម្រេចលើ បណ្តឹងទាស់នោះក្នុងរយៈពេល ៣០ថ្ងៃគិតចាប់ពីថ្ងៃ ដែលភាគីនោះបានទទួលមជ្ឈត្តវិនិច្ឆ័យ។[116] ក្រោយពីសាលាឧទ្ធរណ៍បានចេញសេចក្តីសម្រេចលើបណ្តឹងទាស់នោះហើយ ប្រសិនបើភាគីមិនពេញចិត្តនឹងសេចក្តីសម្រេចនោះ ភាគីវិវាទអាចធ្វើការប្តឹងបន្តទៅតុលាការកំពូលក្នុងរយៈពេល ១៥ថ្ងៃ ហើយសេចក្តីសម្រេចរបស់តុលាការកំពូលលើបណ្តឹងជំទាស់នេះគឺជាសេចក្តីសម្រេចចុងក្រោយបង្អស់។[117]

[115] មាត្រា ៤៤ កថាខណ្ឌទី២ នៃច្បាប់ស្តីពី មជ្ឈត្តការផ្នែកពាណិជ្ជកម្ម

[116] មាត្រា៤២ និង ៤៤ កថាខណ្ឌទី៣ នៃច្បាប់ស្តីពី មជ្ឈត្តការផ្នែកពាណិជ្ជកម្ម

[117] មាត្រា៤៤ នៃច្បាប់ស្តីពី មជ្ឈត្តការផ្នែកពាណិជ្ជកម្ម

# ជំពូកទី ៣

# លក្ខណៈដូច និងលក្ខណៈខុសគ្នានៃមជ្ឈត្តការ និងតុលាការ

## ផ្នែកទី១ លក្ខណៈដូចគ្នា

មជ្ឈត្តការ និងតុលាការ សុទ្ធតែជាស្ថាប័នស្វែងរកដំណោះស្រាយដ៏មានប្រសិទ្ធភាពសំរាប់គូភាគីដែលមានជំលោះ ហើយនីតិវិធីមួយចំនួននៃស្ថាប័នទាំងពីនេះ គឺមានលក្ខណៈដូចគ្នា។ ទាំងស្ថាប័នមជ្ឈត្តការ និងតុលាការ ភាគីវិវាទត្រូវតែដាក់ពាក្យបណ្តឹងរបស់ខ្លួនទៅស្ថាប័ននោះ ដើម្បីស្វែងរកដំណោះស្រាយ។ លក្ខណៈដូចគ្នាចម្បងនៃស្ថាប័នទាំងពីរ មាន៣ចំណុចសំខាន់ៗដូចជាៈ ការដោះស្រាយផ្តោតលើភស្តុតាង និងច្បាប់ អ្នកតំណាង ការចេញនូវសេចក្តីសម្រេច និងការសុំឲ្យអនុវត្តនៃសេចក្តីសម្រេច។

### ១. ការដោះស្រាយវិវាទផ្តោតលើភស្តុតាង និងច្បាប់

ក្នុងការដោះស្រាយវិវាទ ស្ថាប័នទាំងពីរគឺផ្តោតសំខាន់ទៅលើ ភស្តុតាង និងអង្គច្បាប់ដែលត្រូវយកមកអនុវត្ត មានន័យថាវិវាទត្រូវបានដោះស្រាយទៅតាមផ្លូវច្បាប់។ ដោយឡែកក្នុងការដាក់ជូននូវភស្តុតាង សាក្សី ឬអ្នកជំនាញ គឺភាគីត្រូវដាក់ទៅស្ថាប័នណាមួយ ដែលស្ថាប័នទាំងពីរនេះសុទ្ធតែជាស្ថាប័នអព្យាក្រឹត្យ ដើម្បីធ្វើការពិនិត្យ និងសំរេចលើបញ្ហាវិវាទ។

### ២. អ្នកតំណាង

នៅក្នុងការដោះស្រាយនេះផងដែរទាំងមជ្ឈត្តការ និងតុលាការ ភាគីវិវាទអាចចាត់តាំងអ្នកតំណាងរបស់ខ្លួនដែលជាមេធាវី ដើម្បីតំណាងឲ្យខ្លួនក្នុងការដោះស្រាយវិវាទបាន ហើយភាគិវិវាទមិនសិទ្ធិក្នុងការផ្លាស់ប្តូរអ្នកតំណាងប្រសិនបើខ្លួនមិនពេញចិត្តនឹងអ្នកតំណាងនោះ។

### ៣. ការចេញនូវសេចក្តីសម្រេច និងការសុំឲ្យអនុវត្តនៃសេចក្តីសម្រេច

ក្រោយពីការដោះស្រាយត្រូវបានបញ្ចប់ ស្ថាប័នទាំងពីរត្រូវចេញនូវសេចក្តីសម្រេចមួយដែលសេចក្តីសម្រេចនោះមានអានុភាពចាប់បង្ខំដល់ភាគីវិវាទ ដោយតុលាការចេញនូវសាលក្រម រីឯមជ្ឈត្តការចេញនូវមជ្ឈត្តវិនិច្ឆ័យ ពោលគឺសេចក្តីសម្រេចនេះចងភ្ជាប់នូវកាតព្វកិច្ចឲ្យភាគីទាំងពីរគោរព និងអនុវត្តតាម។ ប៉ុន្តែក្នុងករណីដែលភាគីណាមួយមិនគោរពតាមសេចក្តីសម្រេចរបស់មជ្ឈត្តការ ឬតុលាការ ភាគីមួយទៀតអាចយកសេចក្តីសម្រេចរបស់មជ្ឈត្តការ ឬតុលាការនេះ មកដាក់ជូនតុលាការដើម្បីសុំការអនុវត្តដោយបង្ខំបាន។

## ផ្នែកទី២ លក្ខណៈខុសគ្នា

ថ្វីត្បិតតែដំណើរការនៃមជ្ឈត្តកាផ្នែកពាណិជ្ជកម្ម មានភាពស្រដៀងគ្នាខ្លះទៅនឹងតុលាការក៏ដោយ ប៉ុន្តែភាពខុសគ្នានៃដំណើរការនីតិវិធីទាំងពីរនៅតែមាន ហើយភាពខុសគ្នានៃដំណើរការទាំងពីរនេះគឺមានច្រើនជាងភាពដូចគ្នា។ ភាពខុសគ្នាចម្បងនៃដំណើរការមជ្ឈត្តការ និងតុលាការគឺមាន ៤ចំណុចសំខាន់ៗដូចជាជម្រើសរបស់ភាគីវិវាទ ភាពឆាប់រហ័ស ចំណាយតិច និងការសម្ងាត់នៃរឿងក្តី ជំនាញក្នុងការដោះស្រាយវិវាទ អ្នកតំណាង សេចក្តីសម្រេចចុងក្រោយ។

### ១. ជម្រើសរបស់ភាគីវិវាទ

នៅក្នុងដំណើរការមជ្ឈត្តការ រាល់ការកំណត់លើនីតិវិធីនៃដំណើរការគឺជាការកំណត់ និងការព្រមព្រៀងគ្នារបស់ភាគីវិវាទ ដែលមានដូចជាទីកន្លែង ពេលវេលា ច្បាប់ដែលត្រូវយកមកអនុវត្ត នីតិវិធីសវនាការ ការជ្រើសរើសមជ្ឈត្តករ វិវាទដែលត្រូវយកមកដោះស្រាយ និងមធ្យោបាយដែលត្រូវយកមកដោះស្រាយជាដើម។ ផ្ទុយទៅវិញនៅក្នុងដំណើរការរបស់តុលាការភាគីវិវាទពុំមានសិទ្ធិក្នុងការកំណត់យកនីតិវិធីណាមួយដូចមានរៀបរាប់ខាងលើនេះទេ ដែលរាល់នីតិវិធីនេះគឺត្រូវបានកំណត់នៅក្នុងច្បាប់ ហើយមិនអាចធ្វើការកែប្រែបាន។

### ២. ភាពឆាប់រហ័ស ចំណាយតិច និងការសម្ងាត់នៃរឿងក្តី

ភាពសំខាន់នៃដំណើរការមជ្ឈត្តការ គឺភាពឆាប់រហ័ស និងការចំណាយតិច ដែលជាតម្រូវការសំរាប់អ្នកធ្វើពាណិជ្ជកម្មព្រោះថាក្នុងនាមជាពាណិជ្ជករ ឬក្រុមហ៊ុន គឺស្វែងរកប្រាក់ចំនេញ។ ក្រោយពីបានជ្រើសរើសមជ្ឈត្តកររួចហើយនោះ សវនាការនៃមជ្ឈត្តការនឹងអាចចាប់ផ្តើមបានក្នុងរយៈពេលខ្លី ហើយវាអាចបត់បែនបានទៅតាមភាគីបានផងដែរ ចំនែកឯដំណើរការនៃតុលាការវិញ គឺអាចត្រូវអូសបន្លាយជាច្រើនឆ្នាំ ដោយសារការកកស្ទះរឿងក្តីដែលត្រូវធ្វើការដោះស្រាយ និងចំនួនរឿងក្តីច្រើនពេកនៅតុលាការ។ ម្យ៉ាងវិញទៀតការបើកសវនាការរបស់តុលាការត្រូវកំណត់កាលវិភាគតាមប្រតិទិនរបស់តុលាការ ដែលរឿងក្តីខ្លះមិនអាចបើកសវនាការនៅថ្ងៃដែលបានកំណត់ និងត្រូវលើកទៅថ្ងៃផ្សេងទៀតដោយសារពោពេញទៅដោយរឿងក្តី។ អ្វីដែលសំខាន់គឺមជ្ឈត្តការមិនមានទេនូវបញ្ជូនឲ្យជំរះជាថ្មីការចេញនូវមជ្ឈត្តវិនិច្ឆ័យ ដែលខុសពីតុលាការ ដែលការបញ្ជូនរឿងឲ្យជំរះសារជាថ្មីអាចធ្វើឡើងដោយសាលាឧទ្ធរណ៍ និងតុលាការកំពូល ជាហេតុធ្វើឲ្យរឿងក្តីមួយមានភាពស្មុគស្មាញ និងចំណាយពេលយូរ។

ភាពចាំបាច់របស់ភាគីវិវាទក្នុងនីតិវិធីរបស់មជ្ឈត្តការ គឺមានភាពឯកជន និងសម្ងាត់ដែលវាជាសេចក្តីត្រូវការរបស់ពាណិជ្ជករ ឬក្រុមហ៊ុនវិវាទ ជាពិសេសក្រុមហ៊ុនបរទេសដែលមានឈ្មោះល្បីល្បាញ។ ក្រុមហ៊ុនទាំងនោះតែងតែចង់រក្សានូវការសម្ងាត់របស់ខ្លួននៅពេលដែលមានវិវាទកើតឡើង ដើម្បីរក្សាកេរ៍ឈ្មោះរបស់ក្រុមហ៊ុន ភាពជាឯកជននេះមិនមានទេនៅក្នុងសវនាការរបស់តុលាការ ដែលជាការបើកជាសាធារណៈ ហើយអនុញ្ញាតឲ្យភាគីដទៃដែលមិនពាក់ព័ន្ធអាចចូលស្តាប់ពីបញ្ហាវិវាទ ជាពិសេសគឺអ្នកសារពត៌មាន។

### ៣. ជំនាញក្នុងការដោះស្រាយវិវាទ និងអ្នកតំណាង

បើពិនិត្យមើលទៅលើការជ្រើសរើសមជ្ឈត្តករ និងចៅក្រម នៅក្នុងដំណើរការមជ្ឈត្តការភាគីវិវាទមានសិទ្ធិពេញលេញក្នុងការជ្រើសរើសយកមជ្ឈត្តករណា ដែលភាគីពេញចិត្តមកធ្វើការកាត់សេចក្តី។ ចំនែកឯនៅតុលាការវិញ ចៅក្រមត្រូវបានតែងតាំងដោយតុលាការដែលភាគីវិវាទមិនមានសិទ្ធិក្នុងការស្នើសុំចៅក្រមណាម្នាក់ដើម្បីជំរះក្តីលើវិវាទនោះទេ។ អ្វីដែលកាន់តែខុសគ្នាទៀតនោះ គឺមជ្ឈត្តករស្ថិតនៅក្នុងជំនាញពាណិជ្ជកម្មដែលជាកម្មវត្ថុនៃវិវាទ និងយល់ច្បាស់នៃបញ្ហាវិវាទ ហើយដោះស្រាយតែទៅលើវិវាទដែលជារឿងរដ្ឋប្បវេណីប៉ុណ្ណោះ គឺវិវាទពាណិជ្ជកម្ម។ រីឯចៅក្រមវិញគឺស្ថិតនៅក្នុងគោលការណ៍ទូទៅនៃការដោះស្រាយវិវាទ ដែលមិនមានលើជំនាញណាមួយជាក់លាក់នោះទេ គឺដោះស្រាយទៅលើរឿងរដ្ឋប្បវេណីក៏ដូចជារឿងព្រហ្មទណ្ឌ។

ដោយឡែកច្បាប់ស្តីពី អង្គភាពចាត់តាំងតុលាការ ដែលកំពុងធ្វើនូវសេចក្តីព្រាងច្បាប់ប្រសិនបើសេចក្តីព្រាងច្បាប់នេះចូលជាធរមាននោះ តុលាការពាណិជ្ជកម្ម និងសភាពាណិជ្ជកម្មនៃសាលាឧទ្ធរណ៍ និងតុលាការកំពូលនឹងត្រូវបានបង្កើតឡើង ហើយវិវាទពាណិជ្ជកម្មនឹងអាចដោះស្រាយតាមតុលាការ និងសភាពាណិជ្ជកម្ម។ នៅពេលនោះភាពខុសគ្នាលើជំនាញក្នុងការដោះស្រាយវិវាទមិនមានទៀតនោះទេ។

ទោះបីជាអ្នកតំណាងអាចជាមេធាវី ក្នុងការតំណាងឲ្យភាគីណាមួយនៅក្នុងស្ថាប័នទាំងពីរដែលជាលក្ខណៈដូចគ្នា ប៉ុន្តែនៅក្នុងដំណើរមជ្ឈត្តការអ្នកតំណាងនៃភាគីវិវាទអាចជាអ្នកដែលមានចំណេះដឹងផ្នែកច្បាប់ មិនចាំបាច់តែជាមេធាវីរហូតនោះទេ ដែលផ្ទុយគ្នាទាំងស្រុងនឹងតុលាការ អ្នកតំណាងនៃភាគីវិវាទត្រូវតែជាមេធាវីនៃគណៈមេធាវីនៃព្រះរាជណាចក្រកម្ពុជា។

### ៤. សេចក្តីសម្រេចចុងក្រោយ

អ្វីដែលសំខាន់នោះ គឺសេចក្តីសម្រេចរបស់មជ្ឈត្តការគឺជាសេចក្តីសម្រេចចុងក្រោយ ដែលភាគីវិវាទមិនអាចធ្វើការប្តឹងឧបាស្រ័យទៅនឹងលទ្ធផលនៃសេចក្តីសម្រេច ហើយវាមានងាយស្រួលសំរាប់យកទៅអនុវត្ត។ រីឯតុលាការវិញក្រោយពីចេញនូវសេចក្តីសម្រេចរួចហើយ ប្រសិនបើភាគីមិនពេញចិត្តនឹងសេចក្តីសម្រេចនោះ ភាគីដែលមិនសុខចិត្តអាចធ្វើការប្តឹងឧបាស្រ័យទៅសាលាឧទ្ធរណ៍ និងតុលាការកំពូលបាន ដែលត្រូវចំណាយពេលយូររហូតដល់ចេញនូវសេចក្តីសម្រេចចុងក្រោយហើយអាចយកមកអនុវត្តបាន។

# សេចក្ដីសន្និដ្ឋាន

ឆ្លងកាត់តាមការស្រាវជ្រាវ និងបកស្រាយខាងលើបានបញ្ជាក់ឲ្យឃើញថា មជ្ឈត្តការផ្នែកពាណិជ្ជកម្មនៅកម្ពុជា គឺត្រូវបានគ្រប់គ្រងដោយមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម។ ក្រោយពីមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្មត្រូវបានបង្កើតឡើង រាល់បទដ្ឋានគតិយុត្តិដែលត្រូវយកមកគ្រប់គ្រងទាំងក្នុងដំណើរការមជ្ឈត្តការ និងមជ្ឈមណ្ឌលផ្ទាល់គឺអនុម័តដោយមហាសន្និបាត។ ម.ជ.ម គឺគ្រប់គ្រងដោយក្រុមប្រឹក្សាប្រតិបត្តិ និងអគ្គលេខាធិការដ្ឋាន ដែលការងារភាគច្រើនជាបន្ទុករបស់អគ្គលេខាធិការដ្ឋានដូចជាការងាររដ្ឋបាល ការងារប្រមូលប្រាក់កម្រៃ និងការងារប្រចាំថ្ងៃផង រីឯក្រុមប្រឹក្សាគឺជាអ្នកតាក់តែងនូវវិធាននានាដែលចាំបាច់ និងសម្រេចលើការងារមួយចំនួនរបស់អគ្គលេខាធិការដ្ឋាន។

ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការគឺជាយន្តការមួយដ៏ល្អសម្រាប់ពាណិជ្ជករ ដែលមានដូចជាការចរចា និងមជ្ឈត្តកម្ម។ មុននឹងឈានដល់ការដោះស្រាយតាមរយៈមជ្ឈត្តការ ភាគីវិវាទគួរតែព្យាយាមធ្វើការដោះស្រាយវិវាទរបស់ពួកគេតាមការចរចា ឬសន្ធានកម្មទៅតាមលទ្ធភាពដែលអាចធ្វើបាន ជាពិសេសនៅពេលបញ្ហាវិវាទនៅតូច ឬមិនមានភាពស្មុគស្មាញ ដើម្បីរក្សាទំនាក់ទំនងរវាងភាគីទាំងពីរ ព្រោះថាតាមយន្តការទាំងពីរនេះ ការដោះស្រាយគឺកើតចេញពីការព្រមព្រៀងគ្នាដោយភាគីទាំងពីរ។ ដូច្នេះពុំមានភាគីណាមួយត្រូវបានចាត់ទុកថាចាញ់ ឬភាគីណាមួយត្រូវបានចាត់ទុកថាឈ្នះឡើយ ដែលខុសពីមជ្ឈត្តការដែលចេញនូវសេចក្ដីសម្រេចមជ្ឈត្តវិនិច្ឆ័យកំណត់ពីភាគីចាញ់ និងភាគីឈ្នះហើយអាចនាំឲ្យបាត់បង់នូវទំនាក់ទំនងរវាងភាគី។ នៅក្នុងមជ្ឈត្តកម្ម ការដោះស្រាយវិវាទអាចធ្វើបានតែកម្មវត្ថុនៃវិវាទនោះជាកម្មវត្ថុនៃពាណិជ្ជកម្មតែប៉ុណ្ណោះ។ ការចាប់ផ្ដើមនូវដំណើរការមជ្ឈត្តការ គឺនៅពេលដែលភាគីឆ្លើយតបបានទទួលនូវការជូនដំណឹងពីអគ្គលេខាធិការដ្ឋានពីការដាក់បញ្ហាវិវាទឲ្យធ្វើការដោះស្រាយតាមរយៈមជ្ឈត្តការ ដោយភាគីទាមទារ។ ក្រោយដំណើរការមជ្ឈត្តការត្រូវបានចាប់ផ្ដើម ជំហានបន្ទាប់គឺភាគីវិវាទត្រូវធ្វើការតែងតាំងមជ្ឈត្តករ ជ្រើសរើសទីកន្លែងសម្រាប់ធ្វើមជ្ឈត្តការ វិធានច្បាប់ដែលត្រូវយកមកអនុវត្ត ភាសា និងនីតិវិធីសម្រាប់ដំណើរការមជ្ឈត្តការដើម្បីបង្កើតនូវវេទិកាមជ្ឈត្តការ ហើយរាល់ជ្រើសរើសនេះ គឺជាសេរីភាពកំណត់របស់ភាគី។ ក្រោយពេលដែលវេទិកាមជ្ឈត្តការត្រូវបានបង្កើត ភាគីវិវាទត្រូវដាក់នូវសេចក្ដីថ្លែងហេតុទាមទារ និងសេចក្ដីថ្លែងដោះសាររៀងខ្លួនទៅវេទិកាមជ្ឈត្តការ ដើម្បីធ្វើការទាមទារ ឬដោះសារនៃការទាមទារ។ សវនាការនឹងត្រូវបានចាប់ផ្ដើមនៅក្រោយពេលដែលភាគីវិវាទបានដាក់សេចក្ដីថ្លែងហេតុទាមទារ ឬសេចក្ដីថ្លែងដោះសាររួច។ នៅទីបញ្ចប់វេទិកាមជ្ឈត្តការនឹង

ចេញនូវសេចក្តីសម្រេចមជ្ឈត្តវិនិច្ឆ័យមួយ ដែលជាសេចក្តីសម្រេចចុងក្រោយ និងមានអនុភាពចាប់បង្ខំដល់ភាគីវិវាទ។

បើពិនិត្យមើលទៅលើភាពខុសគ្នា និងភាពដូចគ្នារវាងមជ្ឈត្តការ និងតុលាការវិញ នីតិវិធីនៃស្ថាប័នទាំងពីរគឺមានភាពដូចគ្នាមួយចំនួន។ ដោយឡែកភាពខុសគ្នានៃស្ថាប័នទាំងពីរមានច្រើន ហើយការដោះស្រាយតាមរយៈមជ្ឈត្តការក្នុងបញ្ហាវិវាទពាណិជ្ជកម្មគឺមានភាពងាយស្រួល មិនស្មុគស្មាញដូចប្រព័ន្ធតុលាការទេ។ អ្វីដែលពិសេសនោះគឺការដោះស្រាយវិវាទតាមរយៈមជ្ឈត្តការ ជាទូទៅមានរយៈពេលខ្លីជាង឴ឆាប់រហ័ស រក្សានូវការសម្ងាត់ និងចំណាយតិចជាងនីតិវិធីតាមប្រព័ន្ធតុលាការ។ ដូច្នេះក្នុងការដោះស្រាយវិវាទពាណិជ្ជកម្មភាគីវិវាទគួរតែធ្វើការជ្រើសរើសយកមជ្ឈត្តការមកធ្វើការដោះស្រាយវិវាទរបស់ខ្លួន ហើយនៅក្រោយពេលដែលចេញនូវសេចក្តីសម្រេចមជ្ឈត្តវិនិច្ឆ័យ ភាគីវិវាទអាចយកសេចក្តីសម្រេចនេះទៅអនុវត្តនៅបណ្តាប្រទេសផ្សេងៗ ដែលជាសមាជិកនៃអនុសញ្ញាទីក្រុងញូវយ៉ក។

ជាចុងបញ្ចប់ការដោះស្រាយវិវាទតាមរយៈមជ្ឈត្តការមានគុណសម្បត្តិដូចជា ការចំណាយតិចជាងការបណ្តឹងទៅតុលាការនៅកម្ពុជា ដោយសារតែវាមានភាពរលូន ហើយពុំមានការប្តឹងឧបាស្រ័យឡើយលើមជ្ឈត្តវិនិច្ឆ័យ។ ភាពឆាប់រហ័សនៃមជ្ឈត្តការ និងលក្ខណៈស្ថាពរនៃមជ្ឈត្តវិនិច្ឆ័យជាគុណសម្បត្តិមួយដ៏សំខាន់របស់មជ្ឈត្តការ ដោយសារដំណើរនៃមជ្ឈត្តការមានភាពងាយស្រួលដែលអាចបត់បែនបានតាមគូភាគី ហើយមជ្ឈត្តវិនិច្ឆ័យគឺជាសេចក្តីសម្រេចចុងក្រោយ ដូចបានរៀបរាប់ខាងលើគឺមិនអាចប្តឹងឧបាស្រ័យលើសេចក្តីសម្រេចនោះបាន នាំឲ្យសេចក្តីសម្រេចនាំមានលក្ខណៈស្ថាពរតែម្តងក្រោយពីការចេញនូចសេចក្តីសម្រេច។ ក្រៅពីការចេញសេចក្តីសម្រេច ការដាក់ឲ្យអនុវត្តក៏ជាគុណសម្បត្តិមួយដែរ គឺសេចក្តីសម្រេចមជ្ឈត្តការនេះ អាចយកទៅអនុវត្តជាអន្តរជាតិបាន។ ដោយសារកម្ពុជាបានផ្តល់សច្ចាប័នលើអនុសញ្ញាទីក្រុងញូវយ៉ក ដូច្នេះមជ្ឈត្តវិនិច្ឆ័យត្រូវបានទទួលស្គាល់ដោយប្រទេសហត្ថលេខីរបស់អនុសញ្ញានេះ។

នៅក្នុងវិស័យពាណិជ្ជកម្ម ភាគីវិវាទតែងតែចង់រក្សានូវទំនាក់ទំនងរវាងគ្នា ដោយសារមជ្ឈត្តការមានភាពសម្ងាត់ ដែលមិនឲ្យភាគីផ្សេងពីភាគីវិវាទដឹងពីចំណុចលម្អិតនៃវិវាទរបស់ពួកគេ ។ដូចនេះការចេញនូវសេចក្តីសម្រេចមជ្ឈត្តវិនិច្ឆ័យ មិនសូវប៉ះពាល់ដល់ទំនាក់ទំនងភាគីទាំងពីរនោះទេ។ ការដោះស្រាយតាមរយៈតុលាការ ភាគីវិវាទដែលមានសញ្ជាតិបរទេសតែងតែមានការព្រួយបារម្ភចំពោះចៅក្រម ដែលនៅក្នុងប្រទេសជាមួយភាគីម្ខាងទៀតជាជនជាតិដើមតែមួយ។ ប៉ុន្តែនៅក្នុងដំណើរការមជ្ឈត្តការ ភាគីអាចជ្រើសមជ្ឈត្តករបានដែលវាជៀសផុតពីបញ្ហានេះ ហើយវាជាគុណ

សម្បត្តិមួយដែលសំរាប់ភាគីវិវាទ។ គុណសម្បត្តិចុងក្រោយគឺនីតិវិធីនៃមជ្ឈត្តការអាចធ្វើការបត់បែនបាន ដែលការកំណត់នៃនីតិវិធីគឺជាជំរើស និងសេរីភាពរបស់ភាគីវិវាទ ហើយវាជៀសផុតពីនីតិវិធីស្មុគស្មាញដូចមានកំណត់នៃក្នុងច្បាប់។

ទោះបីជាមជ្ឈត្តការមានគុណសម្បត្តិច្រើនក៏ពិតមែន ប៉ុន្តែគុណវិបត្តិនៅតែមានដែលមិនអាចជៀសរួចដូចជា នៅក្នុងករណីដែលវិវាទនោះមានលក្ខណៈស្មុគស្មាញ នោះការចំណាយពេលក្នុងការដោះស្រាយមានរយៈពេលវែង ជាពិសេសការជ្រើសរើសយកមជ្ឈត្តករដែលមានជំនាញ ហើយកម្រៃនៃមជ្ឈត្តករនោះមានកំរិតខ្ពស់ ដែលជាហេតុនាំឲ្យថ្លៃចំណាយកើនឡើងជាងការប្តឹងទៅតុលាការ។ នៅពេលខ្លះក្រោយពេលដែលទទួលបានមជ្ឈត្តវិនិច្ឆ័យហើយក៏ដោយ ភាគីវិវាទត្រូវធ្វើការចំណាយបន្ថែមទៅលើមេធាវីដើម្បីបន្តសុំការអនុវត្តតាមប្រព័ន្ធតុលាការ។ ដូចបានរៀបរាប់ខាងលើ ដំណើរការមជ្ឈត្តការ គឺមានភាពឆាប់រហ័សក៏ពិតមែន ប៉ុន្តែបើធ្វើការប្រៀបធៀបទៅនឹងការចរចា និងសន្ធានកម្ម ការធ្វើមជ្ឈត្តការគឺមានការយឺតយ៉ាវជាង។ គុណវិប្បត្តិចម្បងនៃមជ្ឈត្តការ គឺទាល់តែមានការព្រមព្រៀងគ្នារវាងភាគីទាំងពីរ ទើបយន្តការមជ្ឈត្តការអាចត្រូវបានយកមកដោះស្រាយបាន។ ពេលខ្លះដោយសារការសម្រេចរបស់មជ្ឈត្តការ មិនស្របតាមការទាមទាររបស់ភាគីវិវាទ ដែលនាំឲ្យភាគីវិវាទមិនពេញចិត្តនៃសេចក្តីសម្រេចនេះ ភាគីដែលមិនពេញចិត្តមិនអាចធ្វើការប្តឹងឧបាស្រ័យបាននោះទេ។ ដូច្នេះទោះជាចង់ ឬមិនចង់ភាគីដែលមិនពេញចិត្តត្រូវតែទទួលយក និងគោរពតាមការសម្រេចនោះ។

# អនុសាសន៍

រាជរដ្ឋាភិបាល គួរតែជម្រុញឲ្យមានការបង្កើតឲ្យនូវវគ្គបណ្តុះបណ្តាលបន្ថែមលើដំណើរការមជ្ឈត្តការ ការចេញនូវសេចក្តីសម្រេច និងបញ្ហានានាដែលពាក់ព័ន្ធនឹងមជ្ឈត្តការដល់មជ្ឈត្តករ ក៏ដូចជាសមាជិកនៃមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ឲ្យមានការយល់ច្បាស់បន្ថែមទៀត ព្រោះថាមជ្ឈត្តការផ្នែកពាណិជ្ជកម្មនេះទើបតែបង្កើតឡើង។ ដូច្នេះភាពខ្វះចន្លោះ និងកំហុសឆ្គងគឺតែងតែមាន ដែលទាមទារឲ្យមានការបណ្តុះបណ្តាលបន្ថែម។ ម្យ៉ាងទៀតក្នុងនាងជាប្រទេសកំពុងអភិវឌ្ឍ កម្ពុជាចាំបាច់ត្រូវធ្វើការសិក្សា និងយកនូវបទពិសោធរបស់បណ្តាប្រទេសជឿនលឿនលើពិភពលោកផ្នែកពាណិជ្ជកម្មដូចជា ប្រទេសសឹង្ហបុរី ហុងកុង សហរដ្ឋអាមេរិក និងអង់គ្លេសជាដើម។ បន្ថែមពីលើនេះមជ្ឈត្តមណ្ឌលគួរតែរក្សាឲ្យបាននូវយុត្តិធម៌ ភាពមិនលម្អៀង និងឯករាជ្យភាពរបស់មជ្ឈត្តមណ្ឌលក៏ដូចជាមជ្ឈត្តករ ដើម្បីទាក់ទាញអ្នកវិនិយោគបរទេសមកធ្វើការវិនិយោគ និងជឿជាក់លើការដោះស្រាយវិវាទតាមរយៈមជ្ឈត្តការ។

ទន្ទឹមនឹងនេះ មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្មត្រូវធ្វើការគ្រប់គ្រងតម្លៃនៅក្នុងដំណើរការមជ្ឈត្តការឲ្យមានតម្លៃសមរម្យ ដែលអាចធានាថាពាណិជ្ជករទូទៅអាចមានលទ្ធភាពគ្រប់គ្រាន់ក្នុងការដោះស្រាយវិវាទរបស់ពួកគេបានតាមរយៈយន្តការនេះ។ បន្ថែមពីលើនេះមជ្ឈមណ្ឌលនេះ ក៏ដូចជារាជរដ្ឋាភិបាលត្រូវធានាថាការដោះស្រាយវិវាទតាមរយៈមជ្ឈត្តការគឺមានភាពឆាប់រហ័ស និងមានប្រសិទ្ធិដល់ភាគីវិវាទទាំងពីរក្នុងការយកទៅអនុវត្តន៍ទាំងក្នុងប្រទេស និងទៅអន្តរជាតិ។

## គន្ថនិទ្ទេស

### ក. បទដ្ឋានគតិយុត្តជាតិ

### ច្បាប់

១ ច្បាប់ ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ថ្ងៃទី០៦ ខែមិនា ឆ្នាំ២០០៦

២ ច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម ថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៩

៣ ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី ០៨ខែធ្នូ ឆ្នាំ២០០៧

៤ ច្បាប់ស្តីពីការយល់ព្រម និងការអនុវត្តអនុសញ្ញាអង្គការសហប្រជាជាតិ ចែងអំពីការទទួលស្គាល់ និងការប្រតិបត្តិសេចក្តីសម្រេចមជ្ឈត្តករបរទេស ថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០១

៥ ច្បាប់ស្តីពី សនវកម្មនៃព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី០៣ ខែមិនា ឆ្នាំ២០០០

៦ ក្រឹត្យច្បាប់លេខ៣៨ ស្តីពីកិច្ចសន្យា និងការទទួលខុសត្រូវក្រៅកិច្ចសន្យា ថ្ងៃទី២៨ ខែតុលា ឆ្នាំ១៩៨៨

៧ វិធានស្តីពី មជ្ឈត្តការរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ចូលជាធរមាននៅថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៤

### អនុក្រឹត្យ

៨ អនុក្រឹត្យ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ចូលជាធរមាននៅថ្ងៃទី១២ ខែសីហា ឆ្នាំ២០០៩

៩ អនុក្រឹត្យស្តីពី ការកែសម្រួលមាត្រា ៥២ នៃអនុក្រឹត្យស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ចូលជាធរមាននៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១០

**បទបញ្ជា**

១០ បទបញ្ជាផ្ទៃក្នុងរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម អនុម័តនៅថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៤

១១ បទបញ្ជាសម្រាប់ការប្រឡងបញ្ចប់វគ្គបណ្តុះបណ្តាលមជ្ឈត្តការផ្នែកពាណិជ្ជកម្មលេខ ៨៥៩ ព.ណ នតក ចុះថ្ងៃទី១១ ខែមិនា ឆ្នាំ២០១១

**សេចក្តីជូនដំណឹង**

១២ សេចក្តីជូនដំណឹងស្តីពីការជ្រើសរើសមជ្ឈត្តករដំបូង ដើម្បីបង្កើតមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម លេខ ២៧៤០ ព.ណ នតក ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០០៩ របស់ក្រសួងពាណិជ្ជកម្ម

១៣ សេចក្តីជូនដំណឹងស្តីពីការជ្រើសរើសមជ្ឈត្តករដំបូង ដើម្បីបង្កើតមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម លេខ ២៩០៥ ព.ណ នតក ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០០៩ របស់ក្រសួងពាណិជ្ជកម្ម

១៤ សេចក្តីជូនដំណឹងស្តីពី ការប្រលងបញ្ចប់វគ្គបណ្តុះបណ្តាលសំរាប់មជ្ឈត្តករដំបូង លេខ ៣៩៩៧ ព.ណ នតក ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ២០១០

**លិខិត**

១៥ លិខិតរបស់ក្រសួងពាណិជ្ជកម្ម ស្តីពីពិធីសម្ពោធវគ្គបណ្តុះបណ្តាលមជ្ឈត្តករក្រុមដំបូងនៃមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្មនៅថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១០

១៦ លិខិតលេខ ០០៧/ម.ជ.ម./២០១៤ ស្តីពីការជូនដំណឹងនៃការបើកមហាសន្និបាតលើទី១ របស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៤

១៧ លិខិតរបស់ព្រឹទ្ធសភាលេខ ១២៦/០៦០១/ពស/ន.វ ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០០១

១៨លិខិតរបស់ព្រឹទ្ធសភាលេខ ០១៧/០៣០៦/ពស/ន.វ ចុះថ្ងៃទី០៧ ខែមិនា ឆ្នាំ២០០៦

**ខ. បទដ្ឋានគតិយុត្តអន្តរជាតិ**

១ អនុសញ្ញាស្តីពី ការទទួលស្គាល់ និងអនុវត្តន៍សេចក្តីសម្រេចរបស់មជ្ឈត្តកបរទេស ថ្ងៃទី ១០ ខែមិថុនា ឆ្នាំ១៩៥៨

២ វិធានមជ្ឈត្តការ UNCITRAL

៣ ច្បាប់គំរូអំពីច្បាប់ពាណិជ្ជកម្មអន្តរជាតិ ដែលត្រូវបានអនុម័តដោយគណៈកម្មការអង្គការសហប្រជាជាតិ ស្តីពីច្បាប់ពាណិជ្ជកម្មអន្តរជាតិនៅថ្ងៃទី២១ ខែមិថុនា ឆ្នាំ១៩៨៥

៤ UNICITRAL Model Law

**គ. គេហទំព័រ**

១ http://chnchannel.com/?p=18197

២ http://www.cambodiadaily.com/archives/arbitration-center-elects-board-members-8188/

៣ http://www.moc.gov.kh/pdf/pdfnews/2010_06_15_Launching_of_Training_for_the_first_Group_of_NAC.pdf

៤ http://www.siac.org.sg/our-arbitrators/standards-for-admission-to-siac-panel

៥ http://www.moc.gov.kh/pdf/pdfnews/2013_03_04_00.pdf

៦ http://www.cambodiadaily.com/archives/arbitration-center-elects-board-members-8188/

៧ https://www.adr.org/aaa/faces/s/contact/us?_afrLoop=1571677032300980&_afrWindowMode=0&_afrWindowId=a29lt9ry3_319#%40%3F_afrWindowId%3Da29lt9ry3_319%26_afrLoop%3D1571677032300980%26_afrWindowMode%3D0%26_adf.ctrl-state%3Da29lt9ry3_355

៨ http://www.preservearticles.com/201104065087/arbitrator-his-appointment-powers-and-duties.html

៩ http://www.newyorkconvention.org/contracting-states/list-of-contracting-states

១០ http://www.newyorkconvention.org/contracting-states

១១ http://www.moc.gov.kh/pdf/pdfnews/2009%2008%2010th,%20Signing%20Ceremony%20of%20MOU%20Between%20MoC%20&%20IFC.pdf

## ឃ. បទសម្ភាសន៍

១ បទសម្ភាសន៍ជាមួយលោក រស់ មុនិន្ទ ជាប្រធាននៃក្រុមប្រឹក្សាប្រតិបត្តិ នៅថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៤

២ បទសម្ភាសន៍ជាមួយលោក ប៉ា ងួនគា ជាហិរញ្ញិកនៃក្រុមប្រឹក្សាប្រតិបត្តិ នៅថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៤

៣ បទសម្ភាសន៍ជាមួយលោកស្រី ស៊ីន គឹមស៊ាន ជាមជ្ឈត្តករនៃ ម.ជ.ម នៅថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៤

៤ បទសម្ភាសន៍ជាមួយលោកស្រី ស៊ីន គឹមស៊ាន ជាមជ្ឈត្តករនៃ ម.ជ.ម នៅថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១៤

## ខ. ឯកសារផ្សេងៗ

១ សៀវភៅដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ (មេធាវី ស៊ីវិន អ៊ែម អូស្ទើរមីឡឺរ) បោះពុម្ពលើកទី២ ឆ្នាំ២០១០

២ សៀវភៅការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ របស់ក្រសួងពាណិជ្ជកម្ម និងធនាគារអភិវឌ្ឍន៍អាស៊ី

៣ ការចូលរួមមហាសន្និបាតប្រចាំឆ្នាំលើកទី១ របស់ ម.ជ.ម នៅថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៤

៤ តារាងតម្លៃសេវារបស់មជ្ឈត្តមណ្ឌលជាតិមជ្ឈត្តការផ្នែកពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា

៥ សំណើថវិការបស់មជ្ឈមណ្ឌលមជ្ឈត្តការផ្នែកពាណិជ្ជកម្មសំរាប់រយៈពេលពីខែ តុលា ឆ្នាំ២០១៤ ដល់ខែមិនា ឆ្នាំ២០១៦

៦ បញ្ជីឈ្មោះប្រឡងដែលទទួលបានជោគជ័យក្នុងការប្រឡងបញ្ចប់វគ្គបណ្តុះបណ្តាលមជ្ឈត្តការផ្នែកពាណិជ្ជកម្មលើកទី១ លើមុខជំនាញមជ្ឈត្តការផ្នែកពាណិជ្ជកម្មលេខ ២៧២២ ព.ណ មតក ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១១

៧ បញ្ជីឈ្មោះប្រឡងដែលទទួលបានជោគជ័យក្នុងការប្រឡងបញ្ចប់វគ្គបណ្តុះបណ្តាលមជ្ឈត្តការផ្នែកពាណិជ្ជកម្មលើកទី១ លើមុខជំនាញច្បាប់ពាណិជ្ជកម្មលេខ ២៧២៣ ព.ណ មតក ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១១

៨ បញ្ជីឈ្មោះបេក្ខជនដែលត្រូវបានជ្រើសរើសជាមជ្ឈត្តករដំបូងលេខ ១៣១០ ព.ណ នតក របស់ក្រសួងពាណិជ្ជកម្ម ចុះថ្ងៃទី១២ ខែមេសា ឆ្នាំ២០១០